## *វគ្គទី ១ កុលាបប៉ៃលិន*

*គ្រានោះ ព្រះសុរិយទេវបុត្រ ទ្រង់គង់លើវិមាន កែវផលិក (ផ្ទេក) ដែលជារថព្រះទីនាំង ទឹមដោយសេះអាទេយ្យ ១ពាន់ ទ្រង់បរប្រទក្សិណភ្នំ ព្រះសិនេរុរាជ តាំងអំពីទិសបូព៌ា យាត្រាសំដៅទៅទិសបច្ចឹម តាមចក្ររាសីនៃសុរិយចក្រវាឡ លុះដល់ កំណត់បត់ព្រះរាជរថ ចូលបាំងជ្រ ងមហាបព្វតា រស្មីព្រះសុរិយា ក៏ជ្រេងជ្រេ ចូល កាន់សន្ធ្យារាត្រីនាវេលានោះ ជាខាងខ្នើត ១៥កើត ខែកត្តិក ឆ្នាំច បត្វាស័ក ព .ស ២៤៧០ ព្រះចន្ទទេវបុត្រយាងឡើងគង់លើវិមានប្រាក់ជារាជរថព្រះទីនាំងបរចេញមកពីទិសបូព៌ាឆ្ពុះពណ៌ប្រាក់ទៅសព្វផែនពសុធា ព្រះចន្ទ្រាហាក់ដូចជា មៀ ងមើលមកយ៉ាងស្រស់ញញឹមឆ្ពោះចំទៅលើដំបូលគេហដ្ឋានមួយ នៅខាងលិច ផ្សារស្វាយប៉ោ ដែល ជាផ្សារវិលក្នុងទីរួមខេត្តបាត់ដំបង។*

*ឯគេហដ្ឋាននោះ ជាផ្ទះចាស់ ប្រក់ក្បឿង ដំបូលពីរជាន់ ជញ្ជាំងក្តារ ក្រាលក្តារ សសរមូល នៅហោជាងមានរូបចម្លាក់ឈើធ្វើជារាហូលេបខែ នៅខាងក្រោម រូបនេះគេឆ្លាក់ជា អក្សរធំៗថា "សិរីពង្ស" ជាផ្ទះខ្មែរបែបបុរាណដែលនៅសេសសល់មកសម័យឥឡូវនេះ។*

*ក្នុងវេលារាត្រីនោះ ពន្លឺរស្មីនៃដួងចន្ទ្រា កំពុងចាំង ឆ្ពុះចូលមកតាមចន្លោះបង្អួច ហើយមានខ្យល់ត្រជាក់បក់មកផាយផាត់ចូលមកយ៉ាងរំភើយៗ ល្ហើយត្រសៀកល្មមត្រជាក់ស្រួល នៅខាងក្នុងគេហដ្ឋា ននោះមានកូនចង្កៀងប្រេងកាត១ ចងព្យួរនឹងជញ្ជាំង ក្តារ ល្មមតែឆ្ពុះ បន្ទី ឱ្យមើលមកឃើញបុរសជរាម្នាក់ មានរាងកាយ ស្គាំងស្គម ឥតសាច់ឈាម មានតែស្បែកដណ្តប់ឆ្អឹង ដេកស្តូកស្តឹង នាកណ្តាលល្វែងបន្ទប់ នៅក្បែរ ខាងបុរសជរានេះមានក្មេងប្រុសកម្លោះម្នាក់ មុខមាត់ស្រស់បស់ អង្គុយ ចាំបម្រើថែរក្សាជំងឺរបស់បុរសជរា ដោយកិរិយាឫកពាស្រពោនស្រពាប់ ស្រងូតស្រងាត់ឥត មាន រីករាយបន្តិចសោះ ដោយអ្នកខំអត់ងងុយទ្រាំជំងឺរបស់បុរសជរាដែលត្រូវជា ឪពុកបង្កើតរបស់ខ្លួន អស់វេលា៣រាត្រីមកហើយ។*

*ឯបុរសដែលមានជំងឺជាទម្ងន់ កំពុងដេកស្តូកស្តឹង នៅលើដំណេកនេះឈ្មោះ "ចឹម" កំពុង តែធ្លាក់ខ្លួនទៅជាចំណីអាហារនៃរោគជរា យូរៗគាត់ដកដង្ហើមធំវែងៗ ហើយ គាត់ខំ*

បើកភ្នែក ក្រឡេកមើលទៅពាសពេញទាំងល្វែងបន្ទប់ដេក រួចភ្នែកទាំង គូរបស់គាត់ សម្លឹងទៅចំមុខក្មេងកម្លោះម្នាក់ដែលអង្គុយនៅក្បែរខាងខ្លួនគាត់។ ឯ កម្លោះនោះឈ្មោះចៅ "ចិត្រ" ជាកូនបណ្តូលចិត្តរបស់គាត់ ហើ យជាអ្នកទទួលបន្ត វង្សត្រកូល របស់គាត់តទៅអនាគតផង ទើបគាត់ខំញញឹមទាំងក្រៀមក្រំ ប្រឹងនិយាយដោយសូរសម្លេងញ័រៗថា "ចិត្រ" កូនមាសឪពុក! យប់យន់ណាស់ហើយមិនទាន់ទៅដេកទេឬ? ទៅកូន! ទៅដេក ទៅ "តា ចឹម តឿនបង្ខំឱ្យកូនទៅដេក ក្រែងអត់ ងងុយទៅជាឈឺចាប់"។

ចៅចិត្រ គ្រវីក្បាលដោយការបដិសេធ ព្រមទាំងមានទឹកមុខប្រកបដោយ ចិត្តអាណិតអាសូរបិតា ទើបនិយាយ ជម្រាបទៅវិញថា "ខ្ញុំបាទមិនទាន់ងងុយទេលោកឪពុក! ប្រហែលជាលោកឪពុក មិនទាន់ពិសាថ្នាំយោងកម្លាំងទេដឹង ? លោកគ្រូពេទ្យបានផ្តាំខ្ញុំបាទថា សូមឱ្យលោកឪពុកពិសាកុំខាន"។

"ថ្នាំឬកូន" តាចឹម និយាយឮតែក្នុងបំពង់កទំនងចំអក ឱ្យថ្នាំនោះ ព្រោះជាថ្នាំគាត់ ដឹងថាឥតមានគុណវិសេសអ្វីបន្តិចឡើយ ហើយគាត់និយាយថា "ឱ!កូនអើយ ថ្នាំនេះឪពុកបានផឹកមកច្រើនលើកមកហើយ មិនឃើញមានគុណវិសេសអ្វីដែលអាចជួយបន្ធូរបន្ថយ ជំងឺឱ្យស្រាកស្រាន្តសោះឡើយ រោគជំពូកនេះឪស្គាល់ច្បាស់ថា ជារោគប្រចាំកាយរក្សាក៏ ស្លាប់មិនរក្សាក៏ស្លាប់ ឫទ្ធិអំណាចរបស់ថ្នាំក្នុងខណៈនេះ មិនវិសេសជាងទឹកទន្លេទេកូន"។

ចៅ ចិត្រ មិនទាន់តបទៅឪពុកវិញ ស្រាប់តែលេចបុរសកណ្តាលអាយុម្នាក់ ដើរចូលមកក្នុងបន្ទប់ ហើយដាក់គូថអង្គុយក្បែរខាងអ្នកជំងឺហើយសួរថា "ម៉េចទៅតា ថ្ងៃនេះអាការរោគបានធូរស្បើយខ្លះទេ?"។

ឱពុទ្ធោ! ពុទ្ធោ! តាចឹម លាន់មាត់ឡើងកាលបានឮលោកគ្រូពេទ្យសួរខ្លួន ដូច្នេះហើយគាត់និយាយទៅទៀតថា "ឱ! លោកគ្រូអើយ! វេលានេះភ្នែកខ្ញុំបាទ ស្ទែស្រវាំងងងឹតអស់ហើយ សូមអត់ទោសចុះ ខ្ញុំបាទមិនដឹងថាលោកគ្រូអង្គុយនៅត្រង់ណាទេ "។ ឯចៅចិត្រ កាលបើបានឮសម្តីឪពុកនិយាយត្អូញត្អែរដូច្នោះ ទឹកភ្នែកក៏ហៀរហូរសស្រាក់ ដោយ ចិត្តអាណិតឪពុកពន់ពេក ហើយក៏ សម្លឹងមើលគ្រូពេទ្យ និយាយអង្វរករសុំ ឱ្យជួយស្រោចស្រង់សង្គ្រោះបិតា ឱ្យមានជីវិត តែគ្រូពេទ្យដែល ស្ទាត់ជំនាញក្នុងវិធីមើល ជំងឺ ក៏គ្រវីក្បាលដោយអស់សង្ឃឹម ខ្សឹបប្រាប់ជិតត្រចៀក ចៅ ចិត្រថា "ច្បងមិនផុតពីយប់នេះទេ"។

តាចឹម និយាយមួយៗ ទាំងមា ត់ដង្ហក់បបូរមាត់ស្វាំងញ័រចំប្រប់ ខំនិយាយទៀតថា ខ្ញុំបាទ គង់មិនមានជីវិតរស់នៅទាល់តែបានឃើញពន្លឺព្រះអាទិត្យក្នុងព្រឹកស្អែកនេះទៀតទេ ខ្ញុំបាទ យល់ថាមិនមែនការចម្លែកខុសធម្មតាទេ ព្រោះមរណធម៌ ជាសភាវៈទៀងទាត់ ដែល មនុស្ស សត្វទូទៅត្រូវទទួលយក និង ចៀសវាង ឱ្យផុតពុំបានឡើយ ឯវិញ្ញា ណ និងរាង កាយ របស់ខ្ញុំបាទ ឥតមានស្រណោះអាឡោះអាល័យប៉ុន្មានទេ ស្លាប់ហើយត្រូវទៅកើត ជា អ្វីក៏តាមយថាកម្មចុះ ហើយបែរទៅនិយាយផ្តែផ្តាំកូនថា "ចិត្រ កូន សម្លាញ់ឪពុក! កាល បើឪពុកអស់អាយុទៅហើយ ជីវិតកូនមុខតែរសាត់អណ្តែតឥតបង្គោលជាបង្អែក ដូចជា សំណាត់ដែលអណ្តែតក្នុងទន្លេដូច្នោះ"។

ឯចៅចិត្រ អួលដើមកនិយាយអ្វីមិនរួចសោះ មានតែទឹកភ្នែកហូរសស្រាក់ ឱនមុខជ្រុប ក្រាបចុះជិតជើងឪពុក។ ចំណែកខាងគ្រូពេទ្យ ក៏ងាកមុខបែរទៅបង្ហួច ស្ទើរតែទ្រាំទប់ទឹក ភ្នែកពុំបាន។

តាចឹម និយាយទាំងហត់ថា "នែ ចិត្រ ! កូនសម្លាញ់ឪពុក កាលបើឪពុកស្លាប់ ទៅហើយ ចូរចាំបណ្តាំឪពុកចុះថា ធ ម្មជាតិគ្រប់យ៉ាងក្នុងលោកនេះ ដែលមនុស្សលោក សម្គាល់ថា ជាការរុងរឿងថ្លៃថ្លានោះ គឺជាការតាំងខ្លួនប្រាណ ឱ្យបានថ្លៃថ្នូរ ស្តុកស្តម្ភ "។ឯការដែល រស់នៅគោកយ៉ាកនោះ អ្នកផងទាំងពួងគេមិនយកភ្នែកមើលទេ ការរស់នៅ បែបនេះ មិនមែននាំឱ្យបានសុខសប្បាយទេ ប៉ុន្តែពេលនេះ កូនអើយ ! ឪពុកនឹងប្រាប់អ្នកឱ្យធ្វើ ដូចម្តេចទើបបានសេចក្តីចម្រើននោះពុំបានទេសុំឱ្យគ្រាន់តែលើកដល់ពុទ្ធភាសិត ១បទថា **"អត្តាហិ អត្តនោ នាថោ"** ខ្លួនត្រូវជាទីពឹងនៃខ្លួនឯងតែប៉ុណ្ណោះ ឱ្យរឿយៗចុះ។ កូនអើយ ពាក្យនេះមានន័យថា លោកមិនមែនទូន្មានយើង ឱ្យគិតតែប្រយោជន៍ផ្ទាល់ខ្លួន ឱ្យទៅជា មនុស្សទត្តភាពនោះទេ ឬលែង ឱ្យពឹងពាក់អ្នកដទៃ ឬលែ ងឱ្យអ្នកដទៃគេពឹងពាក់ លើ ខ្លួន យើងវិញក៏ទេដែរ។ ពុទ្ធភាសិតនេះ ទូន្មានយើង ឱ្យចេះខំប្រឹងប្រែងកសាងជីវភាព ខ្លួន ឱ្យ បានចម្រើន ឱ្យមានជំហររឹងប៉ឹងដោយវិជ្ជាសម្បត្តិ គុណសម្បត្តិ សមត្ថភាព ទ្រព្យសម្បត្តិ និង សុខភាព ទើបយើងអាចរស់នៅក្នុងសង្គមមនុស្សបានថ្លៃថ្នូរ ហើយយើងអាចផ្តល់ បាន នូវអត្ថប្រយោជន៍ ឬគុណប្រយោជន៍ដល់សង្គម ឱ្យបានចម្រើនឡើងទៀតផង។ កូន ដឹង ស្រាប់ហើយថា មនុស្សកើតមកក្នុងលោកនេះ មិនមានអ្នកណាមួយអាចរស់នៅ តែ

ម្នាក់ឯងបានទេ គឺត្រូវមានការពឹងពាក់ទាក់ទងគ្នាទៅវិញទៅមកជានិច្ច កូនត្រូវស្គាល់ ហើយត្រូវខំបំពេញករណីយកិច្ចរបស់ខ្លួន ចំពោះខ្លួនឯង ចំពោះសង្គម ចំពោះជាតិ សាសនា មហាក្សត្រ ដែលជាឧត្តមគតិ របស់ពលរដ្ឋជាតិយើង ហើយចំពោះមនុស្សជាតិ ទូទៅដែលជាឧត្តមគតិនៃព្រះពុទ្ធសាសនា។

ឯគ្រូពេទ្យ និយាយជ្រែកក្នុងខណៈនោះថា "តាកុំអាលអស់សង្ឃឹមរហ័សពេក ពាក្យរបស់តាដែលផ្ដាំដូច្នេះ ក៏មិនទាន់ទៅជាអ្វីទេ នៅមានសង្ឃឹមនឹងសះស្បើយវិញបាន"។

តាចឹម និយាយផ្ដើនលោកគ្រូពេទ្យ "សះជាឬ? លោកគ្រូគ្មានផ្លូវសះជាឡើង វិញប្រាកដ មានតែផ្លូវស្លាប់? មុខក្នុងព្រឹកស្អែកឬយប់នេះឬឥឡូវនេះ ក្នុងពេលណាមួយជាមិនខាន "។ តាចឹម ឈប់បង្អង់មួយស្របក់ ហើយចាប់និយាយតទៅទៀតថា "នែ! ចិត្រ កូនសម្លាញ់ឪពុក ឪពុកទីទ័លក្រណាស់ គ្មានកេរមត៌កបន្តិចបន្តួចបម្រុងទុក ឱ្យកូនឡើយ ដល់ឪពុកស្លាប់ទៅហើយ មានតែសព និង ពាក្យបណ្ដាំ ទុកឱ្យកូន"។ រីឯ វិញ្ញាណ-ក្ខន្ធរបស់ឪពុក ដែលនឹងបានទទួលសេចក្ដីសុខ ក្សេមក្សាន្ត ក្នុងលោកខាងមុខនោះ លុះតែកូនប្រតិបត្តិតាមបណ្ដាំឪពុកទាំងប៉ុន្មាន ម៉ាត់នេះ ដែលជាបណ្ដាំចុងក្រោយបំផុត របស់បិតា មួយទៀតវិជ្ជាដែលឪពុក ទុកដាក់ ឱ្យកូនរៀនសូត្រ ដរាប ទាល់តែប្រឡងជាប់ ប្រកាសនីយប័ត្រនោះ ទុកជាមត៌កដ៏មាន តម្លៃមួយ ឱ ! តាំងពីថ្ងៃនេះទៅ ឪពុក អស់បាន ជួយទំនុកបម្រុងកូនតទៅទៀតហើយ!

ចៅចិត្រ កាលបើស្ដាប់ពាក្យបណ្ដាំរបស់ឪពុកចប់សព្វគ្រប់ហើយក៏ ស្រក់ ទឹកភ្នែកច្រោក ៗ ដោយមានចិត្តអាល័យ និង អាណិតឪពុកជាទីបំផុត ហើយខំ និយាយទាំងខ្សឹកខ្សួល ជម្រាបឪពុកថា "លោកឪពុក! បណ្ដាំគ្រប់ម៉ាត់ ខ្ញុំបាទនឹងកត់ត្រាចាំទុកក្នុងចិត្ត ខិតខំប្រតិបត្តិតាមបណ្ដាំគ្រប់ប្រការ សូមលោកឪពុកកុំបីព្រួយបារម្ភឡើយ ខ្ញុំបាទបានជីវិតរស់នៅ ដរាបណានឹងខំតាំងខ្លួនប្រាណតម្កល់តម្កើងវង្សត្រកូលឱ្យបានចម្រើនដរាបនោះ"។

តអំពីពេលនោះ មក តាចឹម មានការដង្ហក់កាន់តែញឹកញាប់ខ្លាំងឡើងមានអាការៈ ក្រវល់ក្រវាយ ទំនងស្វាយាម ហើយទន់ពាប់ទៅ ពល់គ្រាមរណសង្គ្រាម កំពុងទន្ទ្រានចូលមក ជិតអ្នកជំងឺគ្រប់ដង្ហើម ទើបគាត់ខំប្រឹងនិយាយទៅរកគ្រូ ពេទ្យ ដែលមានចិត្តមេត្តាចំពោះខ្លួន ដោយសូរ សម្លេងខ្សាវៗ ជាទំនងសេចក្ដីថា "ទានប្រោស លោកគ្រូ ! ខ្ញុំបាទនឹងដាច់

ខ្យល់ស្លាប់ក្នុងពីរ បីនាទីនេះហើយ សូមអរព្រះគុណ និង សូមជូនបុណ្យលោកគ្រូ ដែល មានគុណលើខ្លួនខ្ញុំបាទជាអនេក ដោយបានខំថែរក្សា ទាំងបង់ខាតថ្លៃថ្នាំជាច្រើនផង ហើយមិនមានគិតថ្លៃរក្សា និង ថ្លៃថ្នាំបន្តិចឡើយ ខ្ញុំបាទឥតមានអ្វីតបស្នងសងគុណ លោកគ្រូទេ ឱ! ព្រះគុណអើយ ត្រចៀកខ្ញុំបាទលែងឮហើយ ឱ! ចិត្រកូន! ពុទ្ធោអរហំ!"។ ចៅចិត្រ ឱបឪពុកជាប់ហាក់ដូចជាមិនព្រម ឱ្យវិញ្ញាណក្ខន្ធរបស់ តាចឹម រត់ចេញពីរាង កាយទៅបាន តែបើទុកជាចៅ ចិត្រ ខំប្រឹងទប់ទល់យ៉ាង ណា ក៏គង់តែ មិន សម្រេចដូច បំណង ព្រោះជាតិ ជរា ព្យាធិ មរណៈ (កើត ចាស់ ឈឺ ស្លាប់ ) ជាមត៌ក របស់សត្វលោក ឥតមានសត្វណាមួយ គេចវេសចៀសវាង ឱ្យរួចផុតទៅបានឡើយ អម្បាលដូចយ៉ាងព្រះ អរហំសម្មាសម្ពុទ្ធម៉េចក៏គង់តែព្រះអង្គចូលបរិនិព្វានមិនខាន។

នៅទីបំផុតនេះ តា ចឹម ក៏ធ្លាក់ខ្លួនទៅជាចំ ណីអាហារនៃមច្ចុរាជ គឺដាច់ខ្យល់ ផុតដង្ហើម ក្នុងដៃរបស់ចៅ ចិត្រ ជាកូន។ តា ចឹម ក៏ទទួលមរណភាពក្នុងខណៈដែល ដួងចន្ទ្រ អស្តង្គតបាត់ពន្លឺរស្មី ព្រមជាមួយគ្នាក្នុងគ្រានោះឯង។

## វគ្គទី២ ជីវិតរបស់ក្មេងកំព្រា

កាលបានចាត់ចែងធ្វើបុណ្យបូជាសពរួចស្រេចហើយ ទើបចៅចិត្រ ដឹង ខ្លួនច្បាស់ ណាស់ថា "ឱ! ខ្លួនអញអើយ កណ្តោងកណ្តោច ខ្មោចផ្សាតែម្នាក់ឯងហើយ បើ ងាករេទៅពឹង បងប្អូនញាតិសាច់សាលោហិតជិតខាងឯណាក៏គ្មាន" ឈ្មោយចុះត្រូវតែតស៊ូនឹង សេចក្តី ទុក្ខលំបាកគ្រប់យ៉ាងចុះ ធ្វើម្តេចកើតមកជាប្រុស កំព្រាម្តាយឪពុក សម ដូចជាប្រសាសន៍ លោកឪពុកផ្តាំទុកថា "ចិត្រ កូន ! កាលបើអស់បុណ្យពីឪពុកហើយ ជីវិតរបស់អ្នកដូចកំណាត់ឈើ ដែលអណ្តែតក្នុងកណ្តាលទន្លេដូច្នោះ"។

ចៅចិត្រក៏គិតឃើញថា ពិភពលោកទាំងមូលនេះ ធំ ទូលាយស្រួលសប្បាយមែន សម្រាប់អ្នកដទៃៗ តែបែរជាទៅជាទីតូចចង្អៀត លំបាកពន់ពេកចំពោះខ្លួន ដែល កំព្រាម្តាយ ឪពុក និង បងប្អូនញាតិសាលោហិត និង ងា កមុខទៅជ្រកកោន ពឹងពាក់ អ្នកឯណាក៏ គេឥតត្រូវការសោះ ព្រោះមនុស្សទីទ័លក្រលំបាកដូចនេះ គេមិន ត្រូវការសេពគប់រាប់រក ហើយទុកជាសុំការគេធ្វើ ក៏ឥតមានអ្នកណាជួយសង្គ្រោះ រកការងារ ឱ្យធ្វើបានឡើយ។ ឱ ! ខ្លួនអញ អើយកើតមកក្នុងលោកនេះលំបាកអ្វីប្លែកជាងគេម៉្លេះ តែថា កើតជាអង្គបុរសហើយ

មិនត្រូវខ្លាចសេចក្តីទុក្ខព្រួយលំបាកទេ តោងតែតស៊ូនឹងសេចក្តីទុក្ខព្រួយលំបាកអស់នេះឱ្យឃើញសខ្មៅទៅចុះ!។

ចៅចិត្រ កំពុងតែឈរសញ្ជឹងរំពឹងគិតរកការធ្វើ តែម្នាក់ឯងយ៉ាងស្ងាត់ៗ នៅចំហៀងមុខផ្ទះ ក៏ងើយទៅមើលលើ ឃើញព្រះចន្ទអណ្តែតត្រសែតនៅកណ្តាលពពកបញ្ចាំងបន្ទឹធ្មុះសព្វទិសទី បរិវេណមានខ្យល់បក់ផាត់មកយ៉ាងត្រជាក់ស្រេង ឮសូរ សម្លេងព្រះសង្ឃសូត្រធម៌នៅវត្ត ព្រះពិតិធាពមយ៉ាងច្បា ស់លាស់ អណ្តែតលឿន លយមកតាមបណ្តោយខ្យល់ លុះចៅ ចិត្រ បានឮ សូរស័ព្ទព្រះសង្ឃសូត្រធម៌នោះ ក៏ជាហេតុ នាំផ្តួចឱ្យនឹករលឹកដល់ឪពុក ដែលទើបទទួលអនិច្ចកម្មទៅថ្មីៗ មិន ដឹងបើនឹងងាកបែរមុខទៅពឹងអ្នកឯណា ហើយក៏បែរមុខមើលទៅក្នុងបន្ទប់ឃើញមាន ចង្កៀងភ្លឺថ្មុងៗ នៅ ទីនោះហើយដែល ជាទីឪពុកធ្លាប់មូរថ្នាំសង្កែពិសាជានិច្ច តែឥឡូវនេះ មានតែចៅចិត្រម្នាក់ឯងចិត្រអាណិតខ្លួនណាស់ ទឹកនេត្រាក៏ហូរចេញសស្រាក់ដោយឥតដឹងខ្លួន។

ខណៈនោះ ចៅចិត្រ ក្រឡេកមើល ទៅខាងមុខស្រាប់តែឃើញមនុស្សម្នាក់ ស្មៀកពាក់សដើរចូលមក ទើបចៅ ចិត្រ ក្រោកឡើងស្រែកសួរថាៈ នរណានុះ ? គ្នាឯងទេ ចៅចិត្រឬអីនឹង? បុរសនោះសួរមកវិញ។ ចៅចិត្រ នឹកស្មានប្រហែលជាលោកគ្រូពេទ្យ ទើប ស្រែកអញ្ជើញថា "សូមអញ្ជើញលោកគ្រូ"។

គ្រូពេទ្យក៏ឈានជើងឡើងជណ្តើរទៅលើផ្ទះ ហើយដាក់គូទ អង្គុយលើកៅអី តាមសេចក្តីអញ្ជើញរបស់ម្ចាស់ផ្ទះ។

"សុខសប្បាយជាទេឬ ចៅចិត្រ?" គ្រូពេទ្យសួរដោយមេត្រីចិត្ត។

ចៅចិត្រ តបថា "ទានប្រោស! ចំណែកខាងរាងកាយសុខសប្បាយទេ ប៉ុន្តែ ចំណែកចិត្តវេទនាជាទីបំផុត ឥតសប្បាយមួយពេលឡើយ តាំងអំពីលោកឪពុកអនិច្ចកម្មទៅវិញ្ញាណរបស់ខ្ញុំបាទនេះ ហាក់ដូចជាងងឹតឈឹងពុំដឹងអ្វីឡើយ!"។

គ្រូពេទ្យងក់ក្បាលទំនងជឿតាមសម្តីចៅចិត្រ ទើបសួរថែមទៀតថា "ចុះសព្វថ្ងៃនេះ បានធ្វើការនៅកន្លែងណាហើយឬនៅឡើយទេ?"

ចៅចិត្រ និយាយតបដោយក្រៀមក្រំសោះកក្រោះថា "ទានប្រោស! នៅទីនេះ ខ្ញុំបាទរកការងារធ្វើមិនទាន់បានទេ ការងារគ្រប់ផ្នែកហាក់ដូចជាខ្ព ស់ជាង ចំណេះដឹង របស់ខ្ញុំបាទ

ដែលបានខំរៀនសូត្រមកដូចជាច្រើនណាស់ ហាក់ដូចគ្រាន់តែប្រើការបានត្រឹមតែមើលសំបុត្រស្នាមបន្តិចបន្តួច មើលឈ្មោះហាងពនផ្សេងៗ និង មើល ប្រូក្រាមតាម រោងកុនល្ខោនប៉ុណ្ណោះ!”។

គ្រូពេទ្យនិយាយដោយសេចក្ដីអាណិតយ៉ាងស្មោះត្រង់ថា “ខ្ញុំក៏នឹកអាណិតអ្នកច្រើន ណាស់ដែរ! ចិត្រ” ហើយនិយាយទូន្មានថា “ខ្លួនអ្នកជាកូនប្រុស ត្រូវតទល់ នឹងវិស័យ លោកិយទៅមុខទៀតច្រើនណាស់ បង្អង់ ឱ្យខ្ញុំគិតពីរ បីនាទីមើល ក្រែងខ្ញុំ គិតរកឧបាយជួយសង្គ្រោះខ្លួនអ្នកឯងបានខ្លះ”។

ចៅចិត្រ នៅតែស្ងៀម គ្រូពេទ្យសញ្ជឹងគិតមួយស្របក់ ក៏ញញឹមលាន់មាត់ ចេញ សម្ដីថា “នឹកឃើញហើយៗ! ខ្ញុំមានឪពុកមាម្នាក់ ជាអ្នកមានចិត្តសប្បុរស មានសម្បត្តិស្ដុកស្ដម្ភគ្រាន់បើ មើលទៅបើលោកជួយធុរៈ មុខជាអ្នកឯងបានការងារធ្វើមិនខាន តែតោងនឿយហត់បន្តិចមុនដំបូង”។

ចៅចិត្រ ញញឹមញញែម ហើយ ជម្រាបសួរទៅលោកគ្រូពេទ្យថា “ខ្ញុំបាទទទួល អត់ធន់សេចក្ដីលំបាកទាំងអស់ សុំ ឱ្យមានតែការធ្វើនឹងគេចុះ គ្រាន់នឹងបានចិញ្ចឹមជីវិត កុំ ឱ្យមានពាក្យគេតិះដៀលប៉ុណ្ណោះ ទុកជាជីកដីលីសែង រែក ពុនយ៉ាងណាក៏ដោយក៏ខ្ញុំបាទស្ម័គ្រធ្វើទាំងអស់”។

លោកគ្រូពេទ្យមានទឹកមុខរីករាយ ដោយ សេចក្ដីពេញចិត្តហើយថា “ ខ្ញុំគិតជានិច្ចថា អ្នកឯងជាកូនប្រុស អាចទទួលធ្វើការគ្រប់ជំពូកបាន គំនិតអ្នកឯងគួរឱ្យសរសើរណាស់ ប៉ុន្តែចៅចិត្រ! ការដែលអ្នកឯងត្រូវធ្វើនោះ មិនមែននៅទីនេះទេ គឺ នៅឯស្រុកបប៉ៃលិនឯណោះ”។

“បប៉ៃលិន ឬ ទានប្រោស !” ចៅចិត្រ ឆ្លើយជូនពាក្យបាត់ទឹកមុខញញឹម រីករាយមួយរំពេច ហើយនិយាយតួញត្អែថា “ទានប្រោស! គេថាស្រុកនោះ ចាញ់ណាស់ មានតែពួក ភូមា កូឡាទើបទ្រាំទៅរកស៊ីក្នុងទីនោះបាន ខ្ញុំបាទនឹកក្រែងតែទ្រាំទ្រនឹង ធាតុអាកាសទឹកដីនោះមិនបានទេដឹង?” គ្រូពេទ្យទូន្មាន “អ្នកឯងនិយាយដូច្នេះក៏ត្រូវដែរ ប៉ុន្តែអ្នកដែលទៅហើយឈឺចាញ់នៅទីនោះ ច្រើនធ្វេសប្រហែស មិនចេះរក្សា ខ្លួន ឱ្យផុតពីជំងឺគ្រុនចាញ់ចុះចំណែកអ្នកឯងក៏បានរៀនសូត្រចេះក្បួនអនាម័យមកខ្លះ ក៏ល្មមនឹងការពារខ្លួនបាន

មួយវិញទៀត ជំងឺគ្រុនចាញ់នេះ មិនចំពោះតែជាតិ យើងទេ ទុកជាជាតិណាក៏ដោយ តែខ្វះវិធីការពាររោគតាមក្បួនអនាម័យហើយ មុខ ជាឈឺចាប់ដូចគ្នាទាំងអស់”។ គ្រូពេទ្យនិយាយទូន្មានចៅចិត្រ ឱ្យមានភាពក្លាហានឡើង ហើយពោលទៅទៀតថា “ឪពុកមាខ្ញុំនោះ ពីដើមបានធ្វើមន្ត្រីមួយហៅតាម បណ្ដាសក្តិថា ហ្លួងរតនសម្បត្តិ ” វេលានេះ អាយុលោក ៥០ប្លាយឆ្នាំហើយ លោកមានអធ្យាស្រ័យល្អ ពួកកូឡា ភូមា នៅទីនោះរាប់អានលោកណាស់ កាលពី ២ទៅ៣អាទិត្យមុននេះ លោកមានសំបុត្រមកដល់ខ្ញុំ សុំ ឱ្យរើសរកមនុស្សម្នាក់ទៅធ្វើការលោក ចំពោះរូបអ្នក ឯងមួយនេះខ្ញុំទុកចិត្តណាស់ ត្បិតការជីកត្បូងនីមួយៗ គេត្រូវការតែមនុស្សសុចរិតស្មោះត្រង់។

ចៅចិត្រ និយាយថា “ការនេះ ជាការថ្មោងថ្មីក្នុ ងជីវិតរបស់ខ្ញុំបាទ”។ គ្រូពេទ្យ ថា “គ្រាន់បើជាងនៅទំនេរ មិនទាន់មានការអ្វីធ្វើមែនទេ ? បើព្រមទទួល ខ្ញុំនឹងចាត់ បញ្ជូនអ្នកឯងនៅវេលាឆាប់ៗនេះ ដោយខ្ញុំមានសេច ក្ដីសង្ឃឹមទុកចិត្តថា អ្នកនឹងខិត ខំធ្វើការយ៉ាងម៉ឺងម៉ាត់ជាទីពេញចិត្តរបស់គេពុំខាន”។

ចៅចិត្រលើកដៃសំពះ ថ្លែងអំណរគុណដោយសេចក្ដីគោរព ចំពោះលោក គ្រូពេទ្យៗក៏សរសេរសំបុត្រមួយច្បាប់ ឱ្យចៅចិត្រហើយលាចុះដើរចេញពីផ្ទះនោះទៅ។

## វគ្គទី ២ ការធ្វើដំណើរទៅប៉ៃលិន

លុះចៅចិត្រ បានទទួលសំបុត្រគ្រូពេ ទ្យហើយ ក៏ចាត់ចែងសំពត់អាវដាក់វ៉ា លីសផ្ដៅនិង អីវ៉ាន់សម្រាប់ធ្វើដំណើរទៅរួចស្រេចហើយ ក៏ប្រុះដេក សម្រាកដោយសេចក្ដីត្រេកអរជំលើសលប់ក្នុងយប់នោះ ស្ទើរតែដេកមិនលក់ទល់ភ្លឺ។ ដល់ម៉ោង ៥ជិតភ្លឺ នាឡិកាឯផ្សារ រំលងវាយឮសូរម៉ឺងៗ យ៉ាងច្បាស់លាស់រហូត ដល់ផ្ទះ ចៅចិត្រៗ ក្រោកឡើងលុបលាងមុខមាត់រួច ក៏ស្ពា យ ក ពាក់ យួរវ៉ាលីសចុះពីផ្ទះ ដើរសំ ដៅទៅផ្សាររំលបម្រុងទៅឡើងរថយន្ត ដែលដើរទៅផ្លូវបាត់ដំបងប៉ៃលិន។ ចៅចិត្រ ទិញសំបុត្រកន្លែងរួចស្រេចហើយ ក៏អង្គុយចាំដរាបដល់ពេលរថយន្តចេញពីផ្សារ ក្រុងបាត់ដំបងទៅ។ វេលាម៉ោង ៦ និង ១៥ នាទី រថយន្តក៏បើកចេញសំដៅទៅទិស ខាងត្បូង ដល់ ទៅផ្សារកាស៊ីស្រាក៏បត់ត្រង់ទៅលិច តាមផ្លូវបប៉ៃលិន។ ចៅចិត្រ អង្គុយមើលភូមិប្រទេសសងខាងមាគ៌ានោះមុខគួរឱ្យស្រងេះ ស្រងោច អណ្ដែត អណ្ដូងក្នុងចិត្តជា ចម្ងៃកណាស់ នឹក ដល់ឪពុកដែល

ទើបអនិច្ចកម្មទៅ ថ្មីៗកាលណា ទឹកភ្នែកក៏ដោរជន់ចេញមក តែខំទប់ទល់មិនឱ្យទឹកភ្នែកស្រក់ចុះទាល់តែបាន ដើម្បីការពារកុំឱ្យអ្នកជិះរថយន្តជាមួយគ្នា មានសេចក្តីសង្ស័យមន្ទិលមកលើខ្លួន ហើយបន្ទំនិយាយសើចលេង កម្សាន្ត ជាមួយនឹងអ្នកជិះទាំងអស់គ្នារៀងៗទៅ។

ឯផ្លូវដែលឡើងទៅស្រុកបប៉ៃលិន មិនសូវឆ្ងាយប៉ុន្មាន ពីក្រុងបាត់ដំបង ក៏ ពិតមែនតែជាផ្លូវលំបាកបន្តិច ត្បិតត្រូវបររថយន្តឡើងកាត់ភ្នំនិងសសៀរតាមជើងភ្នំខ្ពស់ឡើងៗ ហើយកោងបរបត់បែនដរាបដល់ស្រុកបប៉ៃលិន ទុកជាបង្ខំយ៉ាងណា ក៏គង់តែរថយន្តរត់មិនលឿនរហ័សដូចផ្លូវរាបទេ។ ចៅ ចិត្រ ក្រឡេកមើលទេសភាពតាមសងខាងផ្លូវ សង់ដេរដាសទៅដោយស្រែចំការច្បារដំណាំ និង ភូមិស្រុកដោយ អន្ទើៗ ឃ្លាតឆ្ងាយដាច់ៗ ពីគ្នា លុះជិតទៅដល់បប៉ៃលិន ក៏ឃើញតែព្រៃព្រឹក្សា លតាវល្លិ៍ និង ភ្នំតូចធំ ច្រើនអនេក ព្រមទាំងសត្វបក្សាបក្សីនិងសត្វចតុបាទ ក៏មានកុះករច្រើននៅតាមដងព្រៃព្រឹក្សាអស់នោះ។ ចៅចិត្រ បានឃើញសត្វអស់នោះ ក៏កើតមានចិត្តសង្វេគនឹករលឹកដល់ឪពុកកាន់តែខ្លាំងឡើងៗ ស្ទើរតែទប់ទឹកភ្នែកពុំបាន។

លុះដល់រថយន្ត បរបើកកាត់ព្រៃភ្នំក្រំថ្មជាច្រើនអន្ទើ វេលាម៉ោង ១១ថ្ងៃត្រង់ រថយន្តក៏បាន ទៅដល់ផ្សារបប៉ៃលិនដោយស្រួល។ ចៅចិត្រ ចុះពីរថយន្ត ដើរទៅសុើបសួររកផ្ទះហ្លួង រតនសម្បត្តិ។ មានភូមាម្នាក់នៅទីផ្សារនោះ ចង្អុលប្រាប់ថាផ្ទះ ហ្លួងរតន -សម្បត្តិ នៅឯណោះចម្ងាយពីទីផ្សារនេះទៅប្រហែល៥០០ម៉ែត្រ ក្បែរមាត់ ផ្លូវសងខាងជើងនៅក្លោងទ្វារផ្ទះនោះ មានសរសេរយីហោ "គ្រឹះស្ថានរតនសម្បត្តិ" អញ្ជើញទៅចុះគង់នឹងឃើញមិនខាន។ ចៅចិត្រ ក៏ចេញដើរទៅតាមពាក្យភូមានោះ ហើយទៅឈររេរានៅមុខផ្ទះដូច មាន យីហោខាងលើនេះមួយស្របក់ ក៏មានកម្មករ ម្នាក់ ចេញពីក្នុងភូមិនោះមកសួរថា "អញ្ជើញមករកអ្នកណា?"

ចៅចិត្រ ភ្ញាក់ព្រើត ព្រោះពេលនោះ កំពុងឈរមើលភូមិប្រទេសយ៉ាងភ្លើតភ្លើនស្រាប់តែ ក្រឡេកឃើញបុរសខ្មៅម្នាក់ឈរស្លូវក្បែរខ្លួន ទើបប្រាប់ទៅថា "ខ្ញុំមករកហ្លួងរតនសម្បត្តិ វេលានេះ លោកនៅឬទេ?"

បុរសនោះឆ្លើយតប "លោក នៅខាងលើផ្ទះ បើចង់ជួបនឹងលោក អញ្ជើញ មកតាមខ្ញុំ" ហើយបុរសនោះក៏ដើរនាំមុខ ចៅ ចិត្រ ឡើងទៅលើផ្ទះ។

គេប្រាប់ឱ្យ ចៅចិត្រ អង្គុយលើកៅអីមួយនៅក្នុងបន្ទប់ទទួលភ្ញៀវ ហើយដើរ ចូល ទៅក្នុងបាត់មួយស្របក់ ក៏លេចមនុស្សចាស់សក់ស្កូវម្នាក់ ដើរចេញមកដោយ ឫកពា អង់អាចស្លៀកសារុងសូត្រ ពាក់អាវទ្រនាប់ តាមទំនៀមអ្នកនៅផ្ទះ ពាក្យដំបូង ដែល និយាយនឹង ចៅចិត្រ នោះដូច្នេះថា "ក្មួយមកពីណា? ត្រូវការជួបនឹងខ្ញុំមានការអ្វី?"

ចៅចិត្រ សង្កេតដឹងច្បាស់ថា លោកនេះហើយដែលហៅថា ហ្លួងរតនសម្បត្តិ ដែលខ្លួនត្រូវការជួប ទើបរំកិលខ្លួនចុះពីកៅអី បន្ទន់ខ្លួនសំពះដោយសេចក្តីគោរពគួរ សម។

ឯ ហ្លួងរតនសម្បត្តិ ជាអ្នកជំនួញលក់ត្បូង ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ក្នុងស្រុកបប៉ៃលិន ក៏អង្គុយលើកៅអីមួយ ចៅចិត្រ សង្កេតតាមឫកពារបស់លោក នេះ យល់ថាជាអ្នកមានអធ្យាស្រ័យល្អ ចិត្តសប្បុរស គួរជាទីគោរពរាប់អានមែន។

-"ទានប្រោស មាន !" ចៅ ចិត្រ ឆ្លើយដោយឱនលំទោនហើយថា "លោកគ្រូ ពេទ្យ ស្អាត បានផ្ញើសំបុត្រ១ច្បាប់ មកជួបព្រះតេជព្រះគុណ"។

-"អើ! ពេទ្យ ស្អាត ក្មួយខ្ញុំនោះឬ?" លោកនិយាយទាំងញញឹមតាមដោយលោកជាអ្នកមានអធ្យាស្រ័យរីករាយជានិច្ច ហើយ សួរថា "សំបុត្រនោះ នៅឯណា?"

ចៅចិត្រ លូក ដៃទៅក្នុងហោប៉ៅយកសំបុត្រនោះជូនទៅលោក ហ្លួង ទទួល យកទៅអាន ដោយសេចក្តីត្រេកអរ លុះមើលចប់ហើយ ក៏បែរមកពិចារណាមើល លក្ខណៈ ចៅចិត្រម្តងទៀត។

-ហ្លួង "ក្មួយ ឯងមែនទេ ឈ្មោះ ចៅចិត្រ ដែលពេទ្យស្អាត បានបញ្ជូនខ្លួនមកឱ្យខ្ញុំ?"

-ចិត្រ "ទានប្រោស ខ្ញុំបាទនេះហើយ"

-ហ្លួង "ចុះក្មួយធ្វើការយ៉ាងនេះបានដែរឬ? ការរបស់ខ្ញុំនេះ វាធ្ងន់ណាស់ គោងទ្រាំជីកដី ក្នុង ១ថ្ងៃ ៥ ទៅ ៦ ម៉ោង ទើបស្មុះរូច រូបរាងស្អាតបាតដូចជាក្មួយនេះ ខ្ញុំ យល់ថាទ្រាំទ្រ ការងារមិនបានយូរប៉ុន្មានទេ មុខជារត់ទៅផ្ទះវិញហើយ!"។

-"មនុស្សដទៃទៀត គេទ្រាំធ្វើយ៉ាងណា ឯខ្ញុំបាទគង់តែធ្វើបានដូ ចជាគេដែរ សូម ព្រះតេជ ព្រះគុណ កុំព្រួយឱ្យសោះ!"

ចៅចិត្តពោលរ៉ាប់រងយ៉ាងម៉ឺងម៉ាត់។ ពាក្យនេះហើយ ដែល ធ្វើឱ្យ ហ្លួងរតនសម្បត្តិ មានសេចក្តីពេញចិត្តណាស់ ហើយចៅចិត្រ និយាយតទៅទៀត ថា "ទានប្រោស! មនុស្ស ដែលកើតមកក្នុងលោកសន្និវាសនេះ មិនប្រកាន់ការស្រាលៗ ស្រួលៗទេ ខ្ញុំបាទ មិនដែលគិត ដូច្នេះទេ កាលបើខ្ញុំបាទមាន កម្លាំងពលំដរាបណាខ្ញុំបាទ នឹងខិតខំធ្វើការដរាបនោះ ទោះបីធ្ងន់ក្តីស្រាលក្តី"។

-"អ្នកឯងនិយាយនេះត្រូវណាស់"

លោក ហ្លួង និយាយសរសើរ ហើយថា "ណ្ហើយចុះ!

-ឯខ្ញុំ តែង មានការសម្រាប់មនុស្សដែលចង់ធ្វើជានិច្ច វេលានេះអណ្តូង ត្បូងទិស ខាងកើត ខ្ញុំ កំពុង ឱ្យចាប់ផ្តើមជីកត្បូងមានតម្លៃមួយអន្ទើ ព្រឹកស្អែក នេះខ្ញុំនឹងបញ្ជូនអ្នកឯង ឱ្យទៅធ្វើ ការនៅទីនោះ ធ្វើការក្នុងគ្រាដំបូងនេះ ខ្ញុំនឹងតាំងប្រាក់ខែ ឱ្យអ្នកឯងត្រឹម ៣០រៀលសិន ប៉ុន្តែអ្នកឯងអាចមានប្រាក់ខែច្រើនជាងនេះទៅទៀត បើខំយកចិត្តទុ កដាក់ ធ្វើការដោយ ម៉ឺងម៉ាត់ហើយម៉ត់ចត់ផង"។ ចៅចិត្រ ឱនក្បាល ទទួលយល់ ព្រមដោយ សេចក្តីគោរពម្តងទៀត។ ក្នុងខណៈ នោះមានសូរស្បែកជើង លាន់ឮពី ខាងក្រោមឡើង មកលើផ្ទះ ព្រមទាំងមាន សម្លេងយ៉ាងថ្នារតូច លាន់រំពងមកពីខាងក្រោយ ចៅចិត្រ ។ ចៅចិត្រ ក៏ចោលភ្នែកក្រ ឡេកមើលទៅប្រទះនឹងភ្នែកទាំងគូ កំពុងតែ សម្លឹងត្រង់ចំមក ជាដួងភ្នែកប្រកបដោយ ទឹកដមគួរជាទីចាប់ចិត្តស្នេហា គេមានឫកពាឆ្មើងឆ្មៃបន្តិច មាន កិរិយាក្និកក្នក់ ញ៉ែងញ៉ង លូវសលូន់ល្អណាស់ សម្បុរស្បែកសស្អាត មុខមូលក្រឡង់ ដូចវង់ព្រះចន្ទ្រា សូរសម្លេង ស្រួយស្រស់ដូចសូររគាំងប្រាក់ ដំនើរល្វាសល្វន់ ដូច ផ្កា-កុលាប ដែលត្រូវខ្យល់បកលិ្វចៗ នៅកណ្តាលសួនច្បារដូច្នោះ ឱ ! ល្អអីល្អម្ល៉េះ! នេះ ប្រហែល ជាអញយល់សប្តិឃើញទេដឹង?

ចៅចិត្រ ភ្ញាក់ស្មារតី លែង សម្លឹង ស្រឡាំងកាំងក្នុងពេលដែលលោក ហ្លួង ស្រែកហៅ កូនស្រីនោះ ឱ្យឡើងមកខាងលើផ្ទះ "មកឯណេះនារី! ថ្ងៃនេះ ប៉ា បាន មនុស្សចូលមក ធ្វើការថ្មីម្នាក់ទៀតហើយ"។ នាងក្រមុំនារី ឈានជើងឡើងជណ្តើរមួយៗ ភ្នែក សម្លឹងមើល ចៅចិត្រ ដោយកិរិយាឆ្មើង ឆ្មៃបន្តិច ដែលជាទំនៀមទំលាប់របស់ស្រីក្រមុំរូបស្រស់ ហើយសួរ ទៅឪពុកថា "ប៉ា! នេះ ជាអ្នកចូលមកធ្វើការថ្មីរបស់យើង ?" លោក ហ្លួង ញាក់មុខ

ទទួលហើយងាកទៅនិយាយនឹង ចៅចិត្រថា "ចៅចិត្រ នេះនារី កូន ស្រីតែមួយរបស់ខ្ញុំ"។ ចៅចិត្រ លើកដៃសំពះសួរ នាង នារី ងក់ក្បាលទទួលគំនាប់ដោយកិរិយា ឆ្មើងៗតាម និស្ស័យរបស់នាង។ នាងនារី សម្លឹងមើលកម្មករថ្មីរបស់ឪពុក តាំងពីក្បាល រហូតដល់ចុងជើង មើលហើយ មើលទៀត នៅទីបំផុត ក៏លាន់មាត់ថា "កម្មករនេះ ស្គមដូចអ្នកញៀនអាភៀន នឹងមាន កម្លាំងជីកដីបានឬប៉ា?" ចៅចិត្រ កាល ត្រូវស្រីក្រមុំស្ដីដាក់មុខដូច្នេះ ក៏នឹកអៀនខ្មាស់ណាស់ ក្រឡេកចោល កន្ទុយភ្នែកទៅខាងមួយភ្លែត ហើយ តបទៅថា "មនុស្សត្រង់ គេមិនដែល សម្គាល់ថា ជា មនុស្សល្ងង់ទេ ឯមនុស្សស្គម ក៏គេ មិនសម្គាល់ថាជាមនុស្សខ្សោយដែរ ស្គមយ៉ាងខ្ញុំបាទ នេះ មានកម្លាំង ខ្លាំងដូចមនុស្សធាត់មាំដែរ គ្រាន់តែមិនសូវមានសាច់ឈាមជាត់បរិបូណ៌ ប៉ុណ្ណោះទេតើ!"

នាងនារី ធ្វើមុខក្រញូវទំនងខឹងបន្តិចៗផង ដោយនាងមិននឹកថា ចៅចិត្រ ហ៊ានឆ្លើយដូច្នេះសោះ ព្រោះមិនធ្លាប់មានមនុស្សណាមួយក្នុងផ្ទះ ហ៊ាននិយាយ លេង សម្ដីរោហារនឹងនាងឡើយ។

លោកហ្លួង ឃើញកូ នខឹងដូច្នេះ ក៏បញ្ឈប់ថា "ចៅចិត្រ! ឈ្មើយឈប់ស្វេះ ប៉ុណ្ណឹងសិនចុះ ឯងកំពុងនឿយហត់អស់កម្លាំង ទៅរកសម្រាកខ្លួនឱ្យបាត់នឿយ ហត់សិនទៅ"។

### វគ្គទី៣ ចៅចិត្រកើតគំនិតថ្មី

តាំងពីថ្ងៃនោះមក ចៅចិត្រ ក៏បានធ្វើជាកម្មករជីកត្បូងនៅគេហដ្ឋានរបស់ លោកហ្លួង រតនសម្បត្តិ ទោះបីការនោះជាការធ្ង ន់ក៏ដោយ ចៅចិត្រ ក៏ឥតមានចិត្ត ធុញទ្រាន់តែងតែ ខំធ្វើការនោះដោយខ្មីឃ្មាតអស់ពីចិត្តពីថ្លើម មិនមាន នឹកនាដល់សេចក្ដីនឿយហត់ឡើយ ។ ភាសិត ១បទថា "ខ្លួនទីពឹងរបស់ខ្លួន" ដែលជាពាក្យបណ្ដាំ របស់បិតា ចុងក្រោយបង្អស់នោះនៅឮសូរកងរំពងក្នុងត្រចៀករបស់ចៅចិត្រ ហាក់ដូចជា មានទេវតានៅចាំខ្សឹបប្រាប់ នឹងត្រចៀកជានិច្ច។ ការខំប្រឹងប្រែងធ្វើការយ៉ាង ម៉ឺងម៉ាត់ឥតមានទម្រន់ និងអធ្យាស្រ័យ ល្អរបស់ចៅចិត្រ នោះជាហេតុធ្វើ ឱ្យពួក កម្មករ ធ្វើការផងគ្នាស្រឡាញ់រាប់អានជាច្រើន រហូតដល់ ហ្លួងរតនសម្បត្តិ ក៏មានចិត្តមេត្តាក្មេងកម្លោះនោះជាច្រើនដែរ។

ចៅចិត្រ ចូលមកធ្វើការនៅផ្ទះលោកហ្លួង អស់វេលា ៦ខែកន្លះមកហើយនោះ តែងបាន ជួបប្រទះនឹងធម្មជាតិថ្មីៗ ដូចជាព្រៃភ្នំ ក្រំថ្ម ព្រឹក្សាលតាវល្លិ៍ និង អកាស ស្រស់

បរិសុទ្ធ ដែលជារបស់ ចម្លែកក្នុងជីវិតចៅចិត្រ តែដែល ចម្លែកយ៉ាងពន្លឹកជាងនេះទៅទៀត នោះ គឺឃុននារី ចៅហ្វាយក្រមុំរបស់ ចៅចិត្រ ដែល ជាស្ត្រីប្រកាន់ខ្លួនមានឫកពាឆ្មើងឆ្មៃ ហើយ ជានារី មានរូបឆោមយ៉ាងល្អឯកក្នុងស្រុកបប៉ៃលិន ហាក់ដូច ផ្កាកុលាបកំពុងរីកផ្សាយក្លិន ក្រអូបឈ្ងុយឈ្ងប់ក្នុងវស្សានរដូវ។ វេលាដែល ចៅចិត្រ អង្គុយក្នុងផ្ទះស្ងាត់ៗ តែម្នាក់ឯង ច្រើនប្រមូលយករឿងអស់នេះ មកគិតនឹកជានិ ច្ច ហើយ នឹកឆ្ងល់តែម្នាក់ឯងថា ចុះហេតុ ដូចម្តេច បានជាអញ ចេះតែរំពឹងនឹកដល់នាង ក្រមុំនេះអីម្ល៉េះ ចុះអញ ជាប់ចិត្តប្រតិព័ទ្ធ នាងក្រមុំនេះឬអី ? អ៎ា មិនបានទេ នាងនេះរូប ឆោមល្អមែនហើយ ប៉ុន្តែឫកពាឆ្មើងឆ្មៃ ប្រកាន់ខ្លួនហួសពេក ថែមទាំង មានសម្បត្តិស្តុកស្តម្ភណាស់ហួសវិស័យ ឈោងតោងបេះ ប្រលេះយកបាន ចុះអ្នកមានប្រយោជន៍អ្វី ដែល អ្នកនៅខំនឹកដល់គេ ទុកជាខំទប់ចិត្តមិន ឱ្យគិតដូចម្តច ក៏នៅតែ មាន កូនចិត្តរិះរេទៅរករូបបារម្មណ៍នោះទាល់តែបាន! នៅទីបំផុត ចៅចិត្រ ភាវនាថា "ខ្លួនទាបកុំតោង ដៃខ្លីកុំឈោង ស្រវាឱបភ្នំ!"។

ចំណែកនាង នារី ក៏ធ្លា ប់គិតថា កម្មករថ្មីរបស់នាងនេះ ជាមនុស្សចម្លែកជាងគេ មិនចេះ ប្រចុបប្រចែងចៅហ្វាយនាយ និយាយត្រង់ទៅត្រង់មក ឥតចេះក្រែងចិត្តគេសោះ ថែម ទាំងចេះនិយាយ សម្តីទាន់សម័យទៀតផង បានជានាងនឹកជឿថា កម្មករ កម្លោះនោះ បានរៀនសូត្រចេះដឹងច្រើនគួរសមដែរ។ ជួនកាលនាងបា នឮសូរបុរសកម្លោះនោះ ស្រែ ក ច្រៀងរាយទំនុកតាមការកំសត់របស់ខ្លួនក៏មាន ច្រៀងទំនុកជាយុវាភិរម្យ ជាពាក្យរំលឹកយុវជនក៏មាន ទើបនា ងយល់ថា កម្មករកម្លោះនេះ ច្បាស់ជា ចេញមកពីសាលាមធ្យមសិក្សាណាមួយជាប្រាកដ។ នៅវេលាព្រលប់ថ្ងៃនោះ ជាខាងរនោច ព្រះចន្ទ្រ ក៏រះឡើងព្រាងៗ មើលឃើញធែបមួយចំហៀងផ្ទុះពន្លឺពណ៌ប្រផេះ គងចុងព្រឹក្សាយ៉ាងត្រចះត្រចង់ នារី ចុះមកដើរលេង កម្សាន្តចិត្តជាមួយនឹងស្រីបំរើម្នាក់នៅទីធ្លាសួនច្បារមុខផ្ទះដែលមានស្មៅរាបស្អាតដូចកម្រាលព្រំ នាងតែង តែចោលភ្នែក ក្រឡេកទៅកូនផ្ទះមួយ ដែលចៅ ចិត្រ ស្នាក់នៅនោះជារឿយៗ។ ពេលនោះនាងបានឃើញផ្ទះនោះងងឹតឥតពន្លឺភ្លើងទើប នាងនាំក្មេងស្រីបំរើ ហើយ លបដើរឆៀងចូលទៅឈរនៅគុម្ព ផ្កាដកខឹម ខាងមុខបង្អួច ស្រាប់តែឮសូរសម្លេង មនុស្សច្រៀងទំនុកយុវាភិរម្យយ៉ាងពិរោះចាប់ចិត្តថា:

ពួកយើងជាគណៈយុវជន ស្រុះស្រួលលើសលន់ ទាំងប្រុសទាំងស្រី ចូល យុវសាលា ដែលទើបកើតថ្មី ប្រយោជន៍ដើម្បីជួយជ្រោមជ្រែងគ្នា។

ឱ្យបានចងបាច់ជាក្រុមមិត្តភក្តិ ស្រលាញ់រួមរ័ក្សជាសាមគ្គា សាមគ្គី ទាំងជាតិយើង ផងនានា មេត្រីគ្រប់គ្នាជាសុខក្សេមក្សាន្ត។

គួរជួយអ្នកខ្សត់ឱ្យបានចេញទៅ ដើរមើលលំនៅសព្វទីភូមិឋាន មើលស្រែ ចម្ការនឹងច្បារឧទ្យាន កិច្ចការប៉ុន្មានគោងចោងចាំទុក ។ល។

វេលានោះ រស្មីចន្ទ្រកំពុងតែចូលមកតាមចន្លោះ បង្អួច និងចន្លោះទ្វារ ទើប នាងមើលទៅ ឃើញរាងកាយ ចៅចិត្រ ដេកលក់ស្ពកស្ពឹងនៅទីនោះយ៉ាងច្បាស់លាស់ នាងក៏ស្រែក ដាស់ចៅចិត្រ ពីរបីម៉ាត់ ចៅចិត្រ ក៏ប្រែខ្លួនស្ទុះក្រោកឡើងទាំងងុយដេក កាលឃើញ អ្នកដែល ចូលមកដាស់ច្បាស់ក៏ម្ទីម្ទានិយាយអញ្ជើញឱ្យអង្គុយដោយកិរិយាឱន លំទោន។

"អញ្ជើញអង្គុយ យុនទារី " ចៅចិត្រ និយាយ ព្រមទាំងលើកកៅអីមួយមកជូន អង្គុយហើយ និយាយថា "ការដែលយុន អញ្ជើញមកលេងផ្ទះខ្ញុំបាទ ខ្ញុំបាទមានសេចក្តី ត្រេកអរណាស់ ទុកដូចជាបានទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់!"

នាងនារីធ្វើមុខក្រញូវបន្តិច ហើយស្តីទៅថា"អ្នកណានិយាយថាខ្ញុំមកលេងនឹងអ្នកឯង ?" ចៅចិត្រ សង្ស័យក៏សួរទៅវិញថា "ចុះយុនអញ្ជើញមកមានការអ្វី?" នាងតបទៅវិញយ៉ាង កំបុតថា "ខ្ញុំមកស្តាប់មនុស្សច្រៀងទេតើ ចុះអម្បាញ់ មិញនេះ អ្នកណា ច្រៀងទំនុកយុវា ភិរម្យក្តែងៗក្នុងទីនេះ?"

ចៅចិត្រធ្វើឡីងឡង់និយាយសួរនាងថា "ទានប្រោស យុវាភិរម្យជាអ្វី ជាសត្វឬ ជា មនុស្ស ខ្ញុំបាទមិនដែលឮឈ្មោះសោះឡើយ!"

នាងនារី ខឹងឡើងមុខក្រហម ហើយប្រាប់ទៅថា "នែ! អ្នកភ្លើ យុវាភិរម្យ ជា ទំនុកច្រៀង ខ្ញុំចង់ដឹងថា តើអម្បាញ់មិញនេះ នរណាច្រៀង?"

ចិត្រ "អេ!ទេ នរណាច្រៀងខ្ញុំបាទឥតដឹងសោះឡើយ តែខ្ញុំ បាទមិនមែនច្រៀងទេ ឯខ្ញុំ បាទនេះកុំថាដល់ទៅភ្លេងយុវាភិរម្យជាទំនុកទំនើបថ្មីអ្វីនោះឡើយ តែ បទសកវាទីចុះផែអុំ ទូករាល់ឆ្នាំនោះ ខ្ញុំបាទក៏ឥតចេះនឹងគេសោះឡើយ"។

នារី "កុំកួត ខ្ញុំបានឮសូរ សម្លេងច្រៀងអំពីខាងលើផ្ទះនេះឯង ហើយនៅលើផ្ទះនោះក៏មានតែអ្នកឯងម្នាក់ឯងមែនទេ?"

ចិត្រ "បាទ! មានតែខ្ញុំបាទម្នាក់ឯងមែន តែខ្ញុំបាទមិនមែនជាអ្នកច្រៀងទេ"។

"អ្នកឯងច្រៀងក្តែងៗ នៅតែប្រកែកនឹងគេទៀត" នារី ផ្ទួនពាក្យ។

ចៅចិត្រ សើចហើយថា "ខ្ញុំបាទជម្រាបហើយថា ខ្ញុំបាទមិនចេះច្រៀងទេ ក៏នៅតែបង្ខំឱ្យច្រៀងទៀត។ យុននារី បើខ្ញុំបាទចេះច្រៀង នឹងច្រៀងជូន យុន ស្តាប់ ឥឡូវនេះឯង"។

នាងនារី នឹកខឹងក្រោកឡើងឈរ ហើយថា "មនុស្សបែបនេះនិយាយខ្មែរមិនចេះស្តាប់ទេ"។

ចិត្រ "បើមិនចេះស្តាប់ភាសាខ្មែរ ហេតុអ្វីក៏និយាយឆ្លើយឆ្លងគ្នាបាន?"

នារី "ឈប់ៗចិត្រ កុំនិយាយថ្វ ង់ណាស់" នាងលើកដៃហាម ហើយប្រុងនឹង ចុះពីផ្ទះនោះ ទៅដោយរួសរាន់ តែចៅចិត្រអង្វរឃាត់ថា "ពុទ្ធោ! យុននារី យុនប្រញាប់ទៅណាក្មាម?"

នាងឆ្លើយយ៉ាងសោះកក្រោះថា "ទៅគេង"។

ចិត្រ "យុន កុំអាលអញ្ជើញទៅ យុន មិនគួរលះបង់ធម្មជាតិល្អៗដ៏ត្រកាលដែលគួរពិតពិលរមិលមើលក្នុងវេលានេះទៅទេ!"

នារី "ខ្ញុំក៏ចូលចិត្តធម្មជាតិល្អដូច្នេះដែរ តែស្អប់មនុស្សឆ្កួតព្រើលៗ"។

"នៅទីនេះ ឥតមានមនុស្សឆ្កួតទេ យុន" ចៅចិត្រខ្ចិលនិយាយជជែកតទៅទៀត បែរជាបបួលដោយស្រួលថា "ណ្ហើយ យុន មិនបាច់និយាយជជែកគ្នាច្រើនទេ សូមអញ្ជើញទៅសន្ទនាលេងក្នុងសួនច្បារឯណោះ មើលធម្មជាតិល្អៗ ដ៏ត្រកាល កម្រមានណាស់!"

មិនដឹងជាអំណាចអ្វី មកគ្របសង្កត់ ឱ្យនាងនារីធ្វើតាមពាក្យអញ្ជើញរបស់ចៅចិត្រស្រាប់ តែចុះដើរនាំមុខទៅដោយស្រួល ទៅអង្គុយលើដើងម៉ាវែង ក្បែរដើម ចំប៉ីមួយដើមជាមួយ នឹងស្ត្រីបំរើរបស់នាង។ ឯចៅចិត្រក៏អង្គុយលើស្មៅក្បែរជើង ម៉ាវែងនុះដែរតែភ្នែករំពៃងើបមើលទៅព្រះចន្ទ្រាឆែបពាក់កណ្តាលដួង ដ៏ដេរដាសទៅ ដោយពួកផ្កាយមានចំនួន

ច្រើនលើសលន់គណនា ហើយចៅចិត្រនិយាយឡើងថា "ឃុន គាប់ចិត្តពន្លឺរស្មីដួងព្រះចន្ទ្រ ឬ ទេ?"

នារី "ខ្ញុំចូលចិត្តដែរចិត្រ"។

ចៅចិត្រនិយាយដោយសម្តីទន់ភ្លន់ថា "មែនហើយ! ឃុននារី ធម្មជាតិជា របស់ចម្លែក នេះ អាចប្រលោមលួងលោមអារម្មណ៍របស់មនុស្សយើង ឱ្យបានសុខស្រួល ពន្លឺរស្មីព្រះចន្ទ្រ ខ្យល់រំភើយផាត់ និងក្លិនក្រអូបឈ្ងុយឈ្ងប់របស់ផ្កានានា អាចធ្វើចិត្តគំនិតរបស់យើង ឱ្យមានអារម្មណ៍រីករាយទៅបានយ៉ាងចម្លែក"។

នាងអង្គុយស្តាប់សម្តី ចៅចិត្រ និយាយដោយអារម្មណ៍អណ្តែតអណ្តូង នាងគិតថា "កម្មករកម្លោះនេះ ជាមនុស្សចម្លែកជាងកម្មករឯទៀតៗរបស់នាង សម្តីគ្រប់ម៉ាត់របស់កម្មករនេះ ពេញទៅដោយសំនួនវោហារមុខគួរ ឱ្យចង់ស្តាប់ មិនសមជា មនុស្សខ្សោយចំណេះចេះដឹងទេ"។

នាងនារី ស្ងាត់ទៅមួយស្របក់ ចៅចិត្ត ក៏ផ្តើមនិយាយឡើងមុនថា "បើឃុននៅតែម្នាក់ឯងអង្គុយជាមួយនឹងធម្មជាតិបែបនេះ តើឃុនធ្លាប់នឹកប្រវត្តិដល់ញាតិមិត្ត សម្លាញ់ដែលនៅឆ្ងាយៗខ្លះដែរឬ?"

នាងនារី "ខ្ញុំធ្លាប់នឹកដែរចិត្រ"។

ចិត្រ "ខ្ញុំបាទ ក៏ធ្លាប់នឹកដែរ ហើយច្រើនតែជាប់នៅនឹងចិត្តជានិច្ចផង ឱ ! ឃុននារី តាំងពីខ្ញុំបាទមកអាស្រ័យនឹងផ្ទះ ឃុន នេះ ខ្ញុំបាទ មិនដែលឃើញអ្នកម្តាយរបស់ឃុនដល់ម្តង សោះ!"

នារី "ខ្ញុំគ្មានម៉ែទេ ចិត្រ"។

ចិត្រ "អេ! ចម្លែកដែរបើ ឃុន គ្មានម្តាយ ចុះឃុនកើតមកដូចម្តេចបាន?"

នារី "យីអើ! នែ គាត់ឯងកុំនាំអុចអាល បណ្តាល ឱ្យកើតទោសាណ៎ា ពាក្យដែលថាគ្មានម្តាយនោះ គឺថាម្តាយនោះគាត់អនិច្ចកម្មទៅហើយយល់ទេ?"

ចិត្រ "ឱ! ដូច្នេះទេឬ? យល់ហើយទានប្រោស តែឃុនកាន់តែគ្រាន់បើជាង ខ្ញុំបានច្រើន! "

នារី "អើ! ម្តាយគាត់ខូចទៅហើយដែរឬ?"

ចៅចិត្រ ធ្វើមុខស្រពោនហើយថា "យុន នៅ គ្រាន់បើជាងខ្ញុំបានច្រើន ព្រោះ មានឪពុក បីបាច់រក្សា ចំណែកខាងខ្ញុំបាទគ្មានទាំងឪពុកទាំងម្ដាយ"។

ត្រង់នេះ នាង នារី សង្កេតមើល ទឹកមុខ ចៅចិត្រ ឃើញស្ងួតស្រពោនទៅ ច្រើន ចៅចិត្រ សន្សឹមៗ ងើបមុខមើលទៅមុខនាង ហើយនិយាយថា "ប្រសិនបើ ធៀបខ្លួនយុនមកខ្ញុំបាទវិញ ហើយថែមទាំងជាស្ត្រីផង យុន គោងគិតថា ការតស៊ូនឹង ជីវិតដែលក្រីក្រលំបាកគោកយ៉ាកទៅតាមទំនើងតែម្នាក់ឯងនុះ តើវាមានរសជាតិដូចម្ដេចខ្លះ ? តែខ្ញុំបាទជាប្រុស ល្មមអត់ធ្មត់សេចក្ដីលំបាកគ្រប់ៗយ៉ាង ហើ យធ្លាប់តទល់នឹងសេចក្ដីក្រីក្រគោកយ៉ាកមកច្រើន ហើយជួនកាលខ្ញុំបាទអត់បាយពេញមួយថ្ងៃក៏មាន"។

នាងនារី អង្គុយសម្ងំស្ងៀមចាំស្ដាប់ចៅចិត្រនិយាយតែក្នុងចិ ត្តនឹកអាណិតអាសូរចៅចិត្រ ជាពន្លឹកហើយនឹកដល់ខ្លួនឯង ថា បើអញត្រូវទទួលគ្រោះថ្នាក់យ៉ាង នេះឯង តើនឹងមាន សេចក្ដីលំបាកយ៉ាងណាទៅ?

នារី "ចុះ ចិត្រមកនៅទីនេះ បានស្រួលខ្លះហើយឬនៅឡើយទេ ?" នាងនិយាយតិចៗ ហើយមានសម្លេងទន់ជាងមុនច្រើន

ចៅចិត្រ សម្លឹងមើលភ្នែកនាងនារី ហើយញញឹមយ៉ាងពេះរា យឆ្លើយថា! បាទ បានស្រួលច្រើន យុននារី តាំងអំពីខ្ញុំបានទទួលមកអាស្រ័យនៅក្នុងផ្ទះយុននេះ បានស្រួល ឡើងច្រើន មិនបាច់នឹកព្រួយក្រែងអត់បាយស្លាប់ទេ បើបប៉ៃលិននៅតែ មានមេត្តាខ្ញុំបាទ យ៉ាងនេះជានិច្ចទៅ ខ្ញុំបាទមុខជាសូមធ្វើធ្មឹងនៅតំបន់នេះជាប្រាកដ។

អាកាសនៅបប៉ៃលិន តាមធម្មតា ត្រជាក់ជាងស្រុកសង្កែបាត់ដំបងច្រើន បើជួនជាត្រូវរដូវរងា ដូចក្នុងវេលានេះ ក៏កាន់តែត្រ ជាក់ខ្លាំងឡើងទៀតច្រើន លុះព្ធសូរ ទឹកសន្សើមធ្លាក់ចុះពីស្លឹកឈើមិនដាច់រយៈ ដូងចន្ទ្រមួយចំហៀងនោះក៏លិចបាត់បាំងដងភ្នំទៅខ្យល់ត្រជាក់កាន់តែបក់ផាត់ខ្លាំងឡើង ជាហេតុនាំឱ្យត្រជាក់ញាក់ដល់បេះដូងកម្លោះក្រមុំ ទាំងពីរនាក់។ ទើបចៅចិត្រ សន្សឹមក្រោក ឡើងមើលទៅ ផ្ទៃមេឃដោយកិរិយាស្រពោន ស្រពន់ហើយនិយាយឡើងថា "យប់ជ្រៅហើយ យុននារី ! អញ្ជើញឡើងទៅផ្ទះវិញចុះ អំណាចទឹកសន្សើម និងខ្យល់រងាបែបនេះ អាចធ្វើឱ្យ យុន ផ្ដាសាយ ឬទៅជាគ្រុនក៏សឹងបាន"។

ឯ នារី ក្រោកឡើងទៅលើផ្ទះដោយស្រួល ដូចកូនក្មេងដែលប្រដៅបានបែបបទល្អ តែ នាងមកនឹកឆ្ងល់ក្នុងចិត្តថាកម្មករកម្មោះនេះ មានអំណាចអ្វីហ្នំ ! អាចហ៊ាន បង្គាប់អញឱ្យធ្វើតាមបង្គាប់ខ្លួនបានដោយងាយដូច្នេះ តែនាងក៏គិតយល់ថា "ប្រសិនបើអញនៅហាលសន្សើមយូរពេក អាចធ្វើឱ្យគ្រុនរងាឬផ្ដាសាយបានមែន"។

លុះដល់ព្រឹកឡើង ចៅចិត្រ ក៏លីចបដើរចេញទៅធ្វើការជីកត្បូងនាអណ្ដូងត្បូងត្រង់ទិសខាងកើត ដូចសព្វដងដែលធ្លាប់ធ្វើមករាល់ៗថ្ងៃ បានដើរកាត់មុខផ្ទះធំនោះទៅស្រាប់តែ ឃើញនាងនារី និងលោក ហួងរតនសម្បត្តិ អង្គុយក្នុងរថយន្ត យីហោ វីល្លាត់ ដែលជា រថយន្តសម្រាប់ប្រើទៅទិញឥវ៉ាន់នៅផ្សារសង្កែ។ ឯតា សុន ជាអ្នកបររ ថយន្តនោះខំប្រឹងរវៃដៃទាល់តែបែកញើសក៏នៅមិនឆេះសោះ ដល់យូរពេលណាស់ ទើបហួង ស្រែកសួរទៅថា "តាសុន រថយន្តមិនឆេះទេឬ?"។

តាសុន គ្រវីក្បាលយកកន្សែងជូតញើសមុខ ហើយ ជម្រាបទៅលោកថា "មិនឆេះទេទាន ប្រោស! ខ្ញុំបាទបានដោះលាងសំអាតគ្រឿងអំពីយប់មិញនេះឯង ស្រាប់ តែព្រឹកឡើងវាគៀចដូច្នេះទៅ!"។

ចៅចិត្រ ដើរចូលមកជិតលើកដៃសំពះ ហួងរតនសម្បត្តិ ហើយ ជម្រាបសួរថា "ទានប្រោស ព្រះតេជព្រះគុណនឹងអញ្ជើញទៅឯណា?"

លោកតបទៅថា "ខ្ញុំទៅទទួលលោកបាឡាត់ស្រុកសង្កែបន្តិច តែរថវាមិន ព្រមឱ្យទៅសោះ ចៅចិត្រ!"

នាងនារី សម្លឹងមើលចៅចិត្រមួយភ្លែតឃើញទឹកមុខដូចជាស្រស់បស់ជាងសព្វថ្ងៃមាន កិរិយាអង់អាចខុសពីកម្មករឯទៀតៗ។

នារី "ប៉ា យើងទៅមិនរួចទេឬអ្វី?" នាងសួរដោយសេចក្ដីព្រួយ។

ចិត្រ "សុំឱ្យខ្ញុំបាទរវៃមើលបន្តិច ក្រែលោឆេះឡើងបាន" ហើយចៅចិត្រ បើកគ្របបាំងគ្រឿងយន្ត ពិនិត្យមើលមួយស្របក់ ក៏ញញឹម ហើយនិយាយថា "ទាន ប្រោស ទាស់ត្រង់ណោះ រវៃម្ដងទៀតឆេះជាប្រាកដ" ហើយប្រាប់តាសុន ឱ្យរវៃម្ដងទៀត។

តាសុន ចាប់វៃម្តងទៀត គ្រឿងយន្តក៏គ្រហឹមគឹកកងមួយរំពេចឡើង អ្នកទាំងអស់គ្នាក៏ញញឹម តាសុនក៏ឡើងទៅទះស្មាចៅចិត្រ ហើយលាន់មាត់ថា "ពូកែគ្រាន់បើអ្នកក្មួយអញ!"។

ហ្លួងរតនសម្បត្តិ ក៏លាន់មាត់ដោយសេចក្តីត្រេកអរ ហើយសួរចៅចិត្រថា "ចៅចិត្រពូកែ មែន រៀនចេះពីណាប្រសប់លាក់ចំណេះណាស់?"

ចៅចិត្រ នឹកត្រេកអរបង្អោនជម្រាបទៅលោកថា "ទានប្រោស មិនបានរៀនឯណាទេ គ្រាន់តែធ្លាប់បររថយន្តមកដែរ ក៏ល្មមធ្វើកើត ចំពោះតែគ្រឿងដែលខូចខាតតែបន្តិចបន្តួចប៉ុណ្ណោះ" ហើយចាប់ចបលើកលីលើស្មាប្រុងដើរចេញទៅ។

ឯតាសុន បានឮ សម្តីដែលចៅចិត្រថា "ធ្លាប់បររថយន្តមកដែរ" ក៏នឹកដល់ប្រពន្ធដែលទើបមកដល់ផ្ទះពីព្រឹកមិញនេះ គាត់មិនទាន់បានសាកសួរសុខទុក្ខសោះ ស្រាប់តែជាប់រវល់មកបររថយន្តជូនលោកហ្លួងទៅស្រុកសង្កែទើបគាត់ជម្រាបសុំច្បាប់លោកថា "ទានប្រោស ថ្ងៃនេះខ្ញុំបាទមានធុរៈ ដ្បិតប្រពន្ធខ្ញុំបាទ ទើបមកដល់ផ្ទះព្រឹកមិញនេះ ខ្ញុំបាទមិនទាន់បានសាកសួរសុខទុក្ខ វាថាប្រញាប់វិលទៅស្រុក វិញក្នុងពេលវេលាថ្ងៃត្រង់នេះផង ដូច្នេះសូមព្រះតេជព្រះគុណាមេត្តា ឱ្យចៅចិត្រ បររថយន្តជំនួសខ្ញុំបាទមួយពេលសិនចុះ"។

ហ្លួងរតនសម្បត្តិ ស្ងៀមមួយស្របក់ បែរទៅសួរចៅចិត្រថា "ចិត្រ ឯងបររថយន្តជំនួសតាសុន មួយថ្ងៃបានទេ?"

ចៅចិត្រ បែរទៅមើលមុខតាសុន ឃើញ សម្តែងអាការៈអង្វរទើបចៅចិត្រជម្រាបទៅលោកថា "ខ្ញុំបាទបរជូនបានទានប្រោស!"។

តាសុន ត្រេ កអរណាស់ ស្ទុះទៅចាប់ដៃចៅចិត្រ អង្រួនថា "អរគុណអ្នកក្មួយណាស់ សូម អ្នកក្មួយ សម្វាញ់ជួយយកតែបុណ្យទៅចុះ" ហើយគាត់ងាកមកលើកដៃសំពះលា ហ្លួងរតនសម្បត្តិ ដើរចេញទៅ។

ចៅចិត្រ យកគ្រឿងប្រដាប់ធ្វើការទៅទុកស្រេចហើយ ក៏ផ្លាស់ សំពត់អាវកម្មករជាអ្នកបររថយន្ត ឡើងកាច់ចង្កូតបរចេញពីទីនោះទៅ ទំនងជាអ្នកឆ្វាតប៉ិនប្រសប់ ដោយមិនមានឧបសគ្គរវាងពាក់កណ្តាលផ្លូវ ដរាបមកដល់ស្រុកសង្កែ ដែលជាទីក្រុងបាត់ដំបង។

ឪពុកនិងកូន ក៏ចុះពីរថយន្តដើរសំដៅទៅ កាន់ផ្ទះមួយក្បែរសាលាស្រុកប្រហែល កន្ទះម៉ោងទើបឃើញនាងនារីចុះពីផ្ទះនោះមក។ ចៅចិ ត្រូវសួរដោយកិរិយាសុភាពថា "ត្រឡប់ទៅឥឡូវឬនៅទេ ឃុន?"

"នៅទេ" នាងតបកំបុតៗ ហើយថា "ចិត្រ តោងទៅទិញអីវ៉ាន់ឯផ្សារជាមួយនឹងខ្ញុំឥឡូវ នុះកញ្ច្រែង! ចិត្រ កាន់យកទៅផងណ៎ា"។

ចៅចិត្រ នឹកភាំងបន្តិច ដ្បិត តាំងអំពីកើតមកមិនដែលកាន់កញ្ច្រែងដើរតាម ក្រោយស្រីណាម្ដងសោះ តែគ្រានេះត្រូវតែធ្វើតាម ដ្បិតគេជាចៅហ្វាយខ្លួន ឱ្យប្រាក់ខែខ្លួន គេ ឱ្យផ្ទះនៅ ទុកជាការធ្វើដូច្នេះនាំ ឱ្យអាម៉ាស់មុខយ៉ាងណា ក៏ត្រូវតែប្រតិបត្តិតាមបង្គាប់ទៅសិន ចុះទើបនាយចិត្រតស៊ូកាត់កេរ្តិ៍ខ្មាស់ចាប់កញ្ច្រែងត្រីដើរ៉ុយតាមក្រោយចៅហ្វាយក្រមុំមានរូបឆោមស្រស់ប្រិមប្រិយនោះទៅ។

នារីបង្គាប់ "ចិត្រ ទៅសួរទិញត្រីរ៉ស់ធំ ៗ ពីរយកទៅស្ងោរជ្រក់ តើគេលក់មួយ ថ្លៃប៉ុន្មាន? រើសយកឱ្យជាត់ៗបន្តិច"។

ចៅចិត្រ និយាយសុំខ្លួនថា "សូមកុំប្រើឱ្យខ្ញុំបាទទិញឡើយ ឃុន ! និយាយឆ្លើយតបទៅទៀតថា តាំងពីកើតមកខ្ញុំបាទមិនដែលទិញត្រីសាច់បន្លែបង្កាអ្វីទេ ក្រែងឃុនបន្ទោសថាទិញថ្លៃពេក ដ្បិតខ្ញុំបាទមិនចេះតថ្លៃទិញត្រីទេ ទានប្រោស!"

នារី "មិនអីទេ ទៅសួរទិញចុះ ចាំខ្ញុំតថ្លៃឱ្យ"។

ចិត្រ "សុំឱ្យ ឃុន តថ្លៃទិញខ្លួនឯងចុះ"។

នាងនារីឡើងមុខក្រហមបន្តិចក៏ដើររ៉ុយទៅទិញដោយខ្លួនឯង។ ឯចៅចិត្រក៏កាន់កញ្ច្រែងដើរតាមក្រោយ កាលទិញបានត្រីរ៉ស់ពីរ ដើរវិលទៅទិញរានឯទៀតៗ នាងនៅ នឹកខ្ញាញ់នឹងការចចេសរឹងរូសរបស់ចៅចិត្រណាស់ក៏ក្លែងដើរចេញពីរាន មួយទៅរានមួយទៀត ដើររវីរក់ចុះឡើងជាច្រើនបកច្រើនសាទិញអីវ៉ាន់ច្រើនស្កេះស្កះ ទាល់តែចៅចិត្រ យកទៅស្ទើរតែមិនរួច នាងនឹកក្នាញ់ក៏ ក្នាញ់ណាស់ តែនឹកចង់សើចក៏ចង់សើចណាស់ដោយបានឃើញចៅចិត្រ កាន់ពេញដៃទាំងពីរយួរផង គៀតក្លៀកផង រណែរណោងហើយ នាងធ្វើជាដើរវិលជាច្រើនបក ច្រើនត្រឡប់ទើបបត់ ចូលទៅរថយន្ត។ ចៅចិត្រ ក៏ចេះតែដើរប្រកិតតាមក្រោយដរាបដល់រថយន្ត ហើយ ទំលាក់អីវ៉ាន់ទៅក្នុងរថយន្តនោះទៅ។

នាងនារី ឃើញកិរិយា ចៅចិត្រធ្វើដូច្នេះ ក៏ ប្រឡោតឡើងថា "យី! គាត់នេះ ក្លែងទំលាក់ឥវ៉ាន់លើក្បាលអញឬ?"

ចៅចិត្រ ឆ្លើយឡើងថា "សូមអត់ទោសទានប្រោស ធូន់ពេក តែខ្ញុំបាទទំលាក់ លើក្ដាររថយន្តទេតើ"។

នារី "ប្រយ័ត្ន គាត់ឯងកុំដើរកិរិយាថោកទាបពេក!"។

នាយ ចិត្រ ឮហើយគ្រាន់តែញញឹមហ៊ឹះៗ ហាក់ដូចជាមិន យកចិត្តទុកដាក់ នឹង ការខឹងសម្បាររបស់ចៅហ្វាយក្រមុំនោះសោះ។

អ្នកទាំងពីរ ក៏អង្គុយនៅស្ងៀមទាំងអស់គ្នា ឥតនិយាយរកគ្នាមួយម៉ាត់សោះ មួយស្របក់ក្រោយមក ទើបឃើញ ហ្លួងរតនសម្បត្តិ មកដល់ទីចតរថយន្តជាមួយ បុរសកម្លោះម្នាក់ មុខវែង ពាក់មួកស ពាក់អាវបើកក ចងក្រវ៉ាត់ស្លៀកខោកាគី ពាក់ស្បែកជើងពណ៌-ក្រហម ស្រោមជើងស។ នាយចិត្រ គ្រាន់តែក្រឡេកមើលទៅឃើញបុរសនោះ ក៏មានសេចក្ដីទាស់ចិត្តឥតត្រេកអរបន្តិចបន្តួចឡើយ។

ហ្លួងរតនសម្បត្តិ និយាយថា "យើងតោងប្រញាប់ទៅឥឡូវទើបបាន បង្អង់ យូរពេកមិនបានទេ ដ្បិតយើងឥតដាក់កាំភ្លើងមកផងសោះ ក្រែងចោរប្លន់កណ្ដាលផ្លូវ"។

នាងនារី បែរទៅញញឹមយ៉ាងផ្អែម ខណៈដែលបុរសកម្លោះនោះ ឡើងមកលើរថយន្ត ហើយសួរថា "លោក បាឡាត់ ដាក់កាំភ្លើងមកដែរឬ?"

ចៅចិត្រ ត្អូញរង៉ូវនៅតែក្នុងបំពង់ក "បុរសកម្លោះនេះជាបាឡាត់ស្រុកសង្កែ រូបរាងបែបនេះមិនគួរសេពគប់សោះឡើយ កន្ទែងអង្គុយវាលល្វឹងមិនអង្គុយ នៅតែទៅប្រជ្រៀតអង្គុយក្បែរ ឃុននារី ក្រអើត!"

ចំណែកខាងលោក បាឡាត់ ទះគូថហើយប្រាប់ថា "ឃុន នារី កុំព្រួយ មាន កាំភ្លើងខ្លីជាប់មកជាមួយដែរ"។

ហ្លួងរតនសម្បត្តិ ក៏សើចថា "មានមួយប៉ុណ្ណឹង ក៏ល្មមហើយ លោកបាឡាត់ " ហើយងាកទៅប្រាប់ចៅចិត្រថា "ចេញទៅឥឡូវនេះចុះចៅចិត្រ បើចេញរថយន្តទៅវេលានេះប្រហែលជាម៉ោង ៤រសៀលទើបដល់ផ្ទះយើង"។

ចៅចិត្រក៏ចុះទៅរវៃតាមបង្គាប់ហើយឡើងបររថយន្តចេញទៅសំដៅទៅតាមផ្លូវបប៉ៃលិន សឹងដេរដាសទៅដោយស្រែចំការ ច្បារដំណាំ លុះផុតពីភូមិភ្នំសំពៅ ភូមិស្ទឹងកាលណាមានតែព្រៃព្រឹក្សា លតាវល្លិ៍ និងភ្នំក្រំថ្មដេរដាស ផ្លូវកាន់តែ លំបាកឡើង ផ្ទៃផែនដីខ្ពស់ទាបៗ បត់បែនជាច្រើនជាន់ កាល ចៅចិត្រក្រឡេកមើលមកក្រោយ ស្រាប់តែឃើញ បាឡាត់ស្រុកនោះនិយាយក្អាកក្អាយសប្បាយចិត្តជាមួយនឹងនាងនារី ចៅចិត្រ ក៏កើត មោហាខ្លាំងឡើងថែមលើសសេចក្តីមួម៉ៅកាលដែលទៅផ្សារទិញត្រីនោះមួយជាន់ទៀត ក្វេងកាច់ចង្កូតឱ្យបត់ក្បាលធ្លាក់ទៅជង្ហុករាក់ៗ មួ យអន្ទើនៅក្បែរផ្លូវ ម៉ាស៊ី នរោទិ៍រំពងព្រៃ ហើយទប់ង៉ក់ស្ងៀមនៅនឹងកន្លែងនោះឯង។

ចៅចិត្រ ក្រឡេកមើលក្រោយ ស្រាប់តែឃើញភ្នែកគ្រប់គូ សម្លឹងមើលមកចំខ្លួន។ បាឡាត់ស្រុក ភ្ញាត់ធ្លាក់ពីទីអង្គុយ ហួងរតនសម្បត្តិ កំពុងយកដៃស្ទាបក្បាល ដែលប៉ះ ទង្គិចនឹងដំបូលរថយន្ត នាងនារី ផ្អៀងទ្រេតរិះតែធ្លាក់ តែជួនជាចាប់បង្អែកបាន។

លោកបាឡាត់ បន្ទោស "សូហ្វ័រចង្រៃ បររថយន្តអីយ៉ាងអីចេះ"។

នាងនារី ងាកដងខ្លួន ហើយបន្ទោសថា "ចិត្រ គាត់ឯងមិនចេះបរឡានទេឬអី"

ចៅចិត្របែរទៅ ហួងរតនសម្បត្តិ ហើយ ជម្រាបថា "សូមអត់ទោស ទានប្រោសប្រសិនបើ ខ្ញុំបាទមិនកាច់ចង្កូត ឱ្យងាកទៅជង្ហុកទេ កង់មុខខាងស្តាំមុខជា ប៉ះនឹងដង្គត់នោះជាប្រាកដ ហើយធ្វើឱ្យខូចពេលយូរជាងធ្លាក់ជង្ហុកនេះទៅទៀត"

លោកញាក់មុខទទួល ទំនងជាយល់ ដូច្នោះដែរ ហើយចៅចិត្រ បែរមកមើល ខាងក្រោយ ក៏ប្រទះនឹងភ្នែកដែលសម្លឹងសម្ងក់ដាក់ជាច្រើនដង ច្រើនគ្រា ច្រើនត្រឡប់។ រថយន្តទៅទៀតដូចធម្មតា តែនាង នារី ស ង្កេតយល់ដឹងដល់ជម្រៅចិត្តគំនិតរបស់ចៅចិត្រ តែកាលណានាងធ្វើជាស្និទ្ធស្នាលនឹង បាឡាត់ស្រុក នោះរថយន្តក៏ក្រលែងឃ្វេងឃ្វោង រកកល់ធ្លាក់ជ ង្ហុក ឬដើរខុសផ្លូវទៅ ស្ទើរតែមិន ហ៊ាននិយាយអ្វីនឹង លោកបាឡាត់ទៀត។ តាំងពីនោះមក នាងក៏ដឹងខ្លួនថា ចៅចិត្រ មានបំណងអ្វីក្នុងខ្លួននាង?

លុះរថបរផុតភូមិព្រៃផ្តៅទៅឆ្ងាយបន្តិច ក៏ទុកង៉ក់រលត់ម៉ាស៊ីនទើបចៅចិត្រ លោត ចុះទៅ លើកគ្រឿងម៉ាស៊ីនមើល ស្រាប់តែធ្វើមាត់រៀចក្រវែវៗ អ្នកជិះទាំងអស់ គ្រប់ៗគ្នាមាន

សេចក្តីព្រួយជាច្រើន ទើបហ្វូងរតនសម្បត្តិ ដែលមានសេចក្តីព្រួយ ច្រើនជាងគេ ក៏ចុះពីរថយន្តទៅសួរ ចៅចិត្រ ថា "ម្តេចទៅ ទៅទៀតបានឬទេ? ល្មម កែកុនបានឬទេ?"

ចៅចិត្រ គ្រវីក្បាលដោយអស់សង្ឃឹម ហើយ ជម្រាបទៅថា "ទានប្រោស បរទៅទៀតមិនបានទេ ខូចត្រង់កន្លែងសំខាន់ ដែលខ្ញុំបាទធ្វើមិនកើត តោងទៅជួលចិនក្រឡឹងដាក់ជាថ្មី ទើបបាន"។

នារី "ម្តងនេះស្រេច" ហើយនាងផ្តេកខ្លួនលើពូករថយន្តដោយអាការៈអស់កម្លាំងជាច្រើន។

លោក បាឡាត់ ចុះពីរថយន្ត ដើរមកឈរចំពីមុខ ចៅចិត្រ ហើយថា "គាត់ឯងបររថយ៉ាងម៉េចហ្នឹងទាល់តែខូចរថអស់?"

ចៅចិត្រឆ្លើយខ្ញីៗថា "ខ្ញុំបាទបរដូចយ៉ាងមនុស្សធម្មតា លោកក៏បានឃើញនឹង ភ្នែកស្រាប់ហើយ"។

លោកបាឡាត់ ខាំមាត់ហើយថា "បើគាត់ឯងមិនបរឱ្យធ្លាក់ជង្ហុកអម្បាញ់មិញនេះ ក៏គង់មិនខូចដល់ម្លឹងដែរ!"

ចិត្រ "លោកគិតថាខ្ញុំបាទ ក្លែងបរឱ្យធ្លាក់ជង្ហុកឬអ្វី"

បាឡាត់ "ផ្លូវមានតគោកម៉េចក៏គាត់ឯងមិនបរឱ្យត្រង់ទៅតាមផ្លូវ មានតែគាត់ឯងក្លែងធ្វើឱ្យធ្លាក់ជង្ហុក?"

ចិត្រ "លោកថាដូចម្តេចក៏បាន តែខ្ញុំបាទមិនបានក្លែងធ្វើឱ្យវាធ្លាក់ជង្ហុកទេ"

បាឡាត់ "តោងប្រយ័ត្នសម្តីបន្តិចគាត់ឯង"។

ចិត្រ "ខ្ញុំបាទ បាននិយាយដោយសម្តីគួរសមណាស់ហើយទានប្រោស"។

បាឡាត់ "ម៉េចគាត់ឯងព្រហើនម៉្លេះ ក្រែងគាត់ឯងគ្រាន់តែជាអ្នកស៊ីឈ្នួលគេទេ?"

ចៅ ចិត្រ សើចចំអកបន្តិចហើយថា "ខ្ញុំបាទ ជាអ្នកស៊ីឈ្នួលគេមែន តែមិនមែនស៊ីឈ្នួល លោកបាឡាត់ទេ"។

ហ្វូងរតនសម្បត្តិ នឹករំខាននឹង សម្តីនិយាយជជែកគ្នានោះ ក៏ហាមប្រាមទៅថា "ឈប់និយាយប៉ុណ្ណឹងហើយ លោក បាឡាត់ ការនិយាយជជែកគ្នានៅគ្រានេះ វាមិន មានប្រយោជន៍អ្វីឡើយ បុរាណលោកថា សាបមួយដៃ ប្រៃមួយចិប មែនទេ?"

នារី "ចុះយើងគិតធ្វើដូចម្ដេចទើបទៅដល់ផ្ទះ?" នាងសួរដោយសេចក្ដីព្រួយបារម្ភជាច្រើន ។

ហ្វង់ "ហ្នឹងហើយ ប៉ាក៏មិនដឹងគិតដូចម្ដេចដែរ"។

ចៅចិត្រ ដើរចូលទៅរក ហ្វង់រតនសម្បត្តិ ហើយនិយាយ ជម្រាបថា យើងតោងរង់ចាំនៅទីនេះ ទំរាំមានរថយន្តណាមួយមកដ ល់ទីនេះ ប្រសិនបើគ្មានទេ ក៏តោងតែ ស្នាក់នៅទីនេះមួយយប់ បើនឹងដើរជើងទៅ ក្រែងតែពាក់កណ្ដាលអធ្រាតទើបដល់ ផ្ទះ។

លោកហ្វង់ ដកដង្ហើមធំ នាងនារី សួ រលោកឪពុកដោយសេចក្ដីវិតក្កថា " យើងតោងតែដេកស្នាក់ក្នុងព្រៃនេះមួយយប់ទៅឬប៉ា?"

ហ្វង់រតនសម្បត្តិ ញាក់មុខហើយថា "កូនឃើញទេ វេលានេះម៉ោង ៤រសៀលហើយ ឬមួយ កូនចង់ដើរលមើលក៏តាមចិត្ត"។

នាងនារី គ្រវីក្បាល ហើយថា "ទេប៉ា ទម្រាំដើរដល់កូនមុខជាស្លាប់ពាក់កណ្ដាលផ្លូវមិនខានឡើយ"។

ចៅចិត្រ សើចឡើង នាង នារី បែរទៅសម្លឹងចំមុខ ហើយសួរថា "គាត់ឯង សើចអី!"

ចៅចិត្រ ញញឹមញញែមតាមធម្មតា ហើយថា "ខ្ញុំបាទ សើចនឹងកំប្រុកមួយនោះទេតើ វាហក់លោតពីដើមស្រម៉ ទៅដើមកន្ទួតព្រៃ វាភ្ញាត់ចំណាប់ធ្លាក់មកដល់ដី ជិតប្រកាច់ បានខ្ញុំបាទសើចនឹងវា!"

នាងនារី "គេភ័យគេព្រួយរាល់គ្នា ឯងគិតតែពីសើចសប្បាយ"។

ចិត្រ "បានជាខ្ញុំសើច ពីព្រោះសត្វនោះ មានជើងដល់ទៅ ៤ នៅតែភ្ញាត់ចំណាប់ធ្លាក់ដល់ដីទាល់តែបានដូច្នេះទេតើ!"

នាងមិនឆ្លើយតបទៅវិញទេ គ្រាន់តែ សម្ដែងអាការមិនគាប់ចិត្ត ប៉ុន្តែនាងធ្លាប់ សម្ដែងកិរិយាដូច្នេះជានិច្ច។ ចៅចិត្រ ថ្មីកនឹងនិស្ស័យបែបនេះមកច្រើ នគ្រាហើយ ទើបមិនមានចិត្តព្រួយ បារម្ភអ្វីថែមទាំងយល់ថា ស្ត្រីកាលមិន សម្ដែងកិរិយាក្ងិកក្ងក់ខ្លះទេ ក៏មិនល្អមើលដែរ គ្រាន់តែកុំឱ្យជ្រុលហួសពេកប៉ុណ្ណោះ។

ឯនាង នារី នឹកប្រារព្ធនឹងខ្លួនឯងថា "កូនឈ្នួលកម្លោះនេះ ចម្លែកជាងឈ្នួល ដទៃទៀត ជាអ្នកមានអំនួតបន្តិច ថែមទាំងប្រើ សម្ដីមិនចេះក្រែងចិត្តនរណាទេ តែវាចេះនិយាយសមហេតុសមផល ទើបនាងចូលចិត្តនិយាយឬជជែកពីរឿងអ្វីៗលេង"។

លោកបាឡាត់ ដើរតៀងមកក្បែរ នាងនារី ហើយ សួរថា "ចុះហេតុអី ក៏ឃុននារី ចូលចិត្តទៅនិយាយឆ្លើយឆ្លងនឹងអាក្មេងកម្លោះនោះម្ល៉េះ!"

នារី "នរណាប្រាប់លោកថា ខ្ញុំចូលចិត្តទៅនិយាយឆ្លើយឆ្លងនឹងវា!"

បាឡាត់ "ខ្ញុំបាទឃើញនឹងភ្នែក បានឃើញវា និយាយជជែកនឹង ឃុន ទាល់តែឃុនទាល់ច្រករបស់វា ម្ដីងៗហើយនៅ ឃុនទៅនិយាយជជែកនឹងវាទៀត វាក្មេង ព្រហើនមិនចេះគួរសមទេ ឃុន ពិនិត្យមើលវាឱ្យមែនទែនចុះ!"។

នាងនារី ញាក់មុខទំនងយល់ដូច្នេះ ដែរហើយឆ្លើយថា "ចាំ កម្មករនេះ ព្រហើនបន្តិចមែន តែឧស្សាហ៍ធ្វើការណាស់"។

លោកបាឡាត់ "ប្រហែលជាវាទើបមកនៅទេ បានជាពីដើមមិនដែលឃើញសោះ"។

នារី "ចាំ វាទើបនឹងមកនៅមែនប្រហែល ជាង៦ខែប៉ុណ្ណឹង ឪពុកខ្ញុំគាត់មាន ចិត្តអាណិត មេត្តា ដោយឃើញថាជាមនុស្សកំព្រាឪពុកម្ដាយ ហើយបានប្រគល់ ឱ្យជីកអណ្ដូងត្បូង នៅទិសខាងកើត ដែលទើបនឹងបើកថ្មី"។

និយាយគ្នាបានត្រឹមប៉ុណ្ណោះ ក៏ស្រាប់តែឮ សម្លេង ហ្លួងរតនសម្បត្តិ ស្រែក ហៅនាងនារី ហើយប្រាប់ថា "នារីកូន ចាត់ ចែងដាំបាយទឹកទៅ ឪពុកនឹកឃ្លានបាយ ណាស់ហើយឱ្យ ចៅចិត្រ រកអុសភ្លើងផង"។

ចៅចិត្រ ចូលមកជិតហើយសួរថា "ឃុន នឹង ឱ្យខ្ញុំបាទជួយធ្វើការអ្វីខ្លះ ចូរ ប្រាប់មកចុះ!"

នារី "ទៅរកថ្មបីដុំមក ហើយរកអុសបង្កាត់ភ្លើងឡើងផង" នាងបង្គាប់ទៅ លោកបាឡាត់ថា "លោកបាឡាត់ អាណិតយកសាច់ដាក់កំប៉ុងមក ឱ្យខ្ញុំពីរកំប៉ុង និង សណ្ដែកហូឡាន់ តៅផង"។

កម្លោះទាំងពីរនាក់ ក៏ធ្វើការផ្គាប់ផ្គុននាងក្រមុំយ៉ាងម៉ឺងម៉ាត់ ឯចៅចិត្រ បានដុំថ្មតូចៗបីដុំ ហើយដាក់តម្រៀបគ្នាជាមុំជើងក្រាន ហើយទៅរកកាច់អុសមកបង្កាត់ ភ្លើងឆេះដង្គោលឡើង។

"យុន នឹងឱ្យខ្ញុំបាទធ្វើអ្វីទៀត" ចៅចិត្រសួរនាងខណៈដែលបង្កាត់ភ្លើងរួចហើយ។

នារី "ចៀនត្រី ឆាសាច់គោនឹងសណ្តែកទ្រើង អើ ! យើងគ្មានខ្ទះទេ ចៅចិត្រ តោង រកខ្ទះមក"។

ចិត្រ "អេ ទានប្រោស ទីនេះមិនមែនផ្សារសង្កែទេ ចុះ ឱ្យខ្ញុំបាទ ទៅរកឯណា មកជូនយុនបាន?"

នាងដកដង្ហើមធំ ហើយប្រាប់ថា "អើ! នេះប្រុសត្រឡាំង ម្តេចក៏មិនយល់ការ អ្វីសោះ ខ្ញុំគ្រាន់តែឱ្យទៅរកភាជន៍អ្វីមួយសំប៉ែតៗក៏បាន ហើយសម្រាប់យកមកចៀន ឆាប៉ុណ្ណោះ"។

ចៅចិត្រញញឹមហើយថា "ប៉ុណ្ណឹងទេឬ!" ហើយស្ទុះក្រោកទៅឯរថយន្ត លើក ពូកកម្រាល អន្ទុយឡើង មើល ឃើញចានស្ពាន់សំប៉ែតៗ កាន់លើកបង្ហាញទៅនាង នារីថា "បែបនេះ បានឬទេ?"

តាំងអំពី ចៅចិត្រ ចូលមកនៅជ្រកកោននឹងនារី នាងមិនដែលញញឹមម្តងសោះ ទើបតែ ពេលនេះ នាងក៏ញញឹមជំនួសពាក្យតបគ្រាដំបូង។

លុះលាងចានស្ពាន់រួចហើយ ចៅចិត្រ ក៏ដាក់លើជើងក្រានបណ្តោះអាសន្ន នោះឯង។

នារី ក៏យកខ្លាញ់ជ្រូកដាក់ចៀនក្នុងចាននោះ ចៅចិត្រក៏យកស្លឹកត្នោតបក់ភ្លើងឱ្យឆេះឡើង ទាល់តែផេះហុយទ្រូបឡើង ទាល់តែនាងប្រាប់ឱ្យឈប់បក់។

ចិត្រ "ហ្នឹង យុន គិតពិសាតែសាច់ទទេ មិនដាំបាយទេឬ ?" ចៅចិត្រ សួរនាងដោយហេតុ មិនឃើញនាងដាំបាយសោះ។

នារី "អើ មែនហើយ ! ចិត្រខ្ញុំភ្លេចឈឹង ចុះយើងដាក់ឆ្នាំងឯ ណាដាំបាយហ្ន៎!" នាងនិយាយ ហើយសម្លឹងមុខ ចៅចិត្រ ទំនងសូមឱ្យជួយគិតគូរផង។

ចៅចិត្រដឹងទំនងក៏រត់ទៅឯរថយន្តម្តងទៀត រកបានកំប៉ុងបៀរមួយធំ បើកដួសយកសាច់បៀរចេញខ្ចប់អស់ហើយ ក៏វិលមករកនារីសួរថា "បែបនេះប្រើបាន ទេយុន?"

នាងនារី ញញឹមទទួលម្ដងទៀត ចិត្រម្ដងនេះ ញញឹមចេញមកដោយសុទ្ធចិត្ត ឥតក្លែងបន្តិចឡើយ គ្រានេះដែលចៅចិត្រ ឃើញថា ឃុននារីចៅហ្វាយក្រមុំរបស់ គេនេះមានកិរិយាទន់ភ្លន់ផ្អែមល្ហែមចម្លែកណាស់!

នារី "ប្រហែលជាប្រើការបានចិត្រ" នាងតបទៅដោយសម្ដីធម្មតា។

នារី "អើ! ចុះយើងបានទឹកមកពីណាដាំបាយហ៎!"

ចិត្រ "មិនអីទេ ទុកភ្នាក់ងារខ្ញុំបាទរកជូន ឃុន ទាល់តែបា ន" ថាហើយ ក៏បើក បំពង់ទឹកក្នុងរថយន្ត ទឹកក៏ហូរចេញមកទាល់តែពេញកំប៉ុង ហើយយកមកឱ្យនាងនារី

លោកហ្លួង លាន់ សម្ដីពីក្នុងរថយន្តមកថា "ធ្វាតគ្រាន់បើ បើមិនបានចៅចិត្រប្រហែលជា អត់បាយក្នុងពេលនេះទាំងអស់គ្នាមិនខាន"។

ឯលោកបាឡាត់ ទទួលយកអាសាជាអ្នកដាំបាយ ដោយដឹងខ្លួនថាខ្លួនដូចជា ចាញ់ប្រៀបចៅចិត្រច្រើនណាស់ ការដែលនៅស្ងៀមមិនជួយខ្វល់ខ្វាយនឹងគេ ស្រាប់តែបាយឆ្អិនបរិភោគនោះ ដូចជាមិនសមសោះ។

ឯចៅចិត្រតអំពីនោះមិនបានជួយធ្វើអ្វីទៀតទេ ទាល់តែបាយឆ្អិនទើបដួសបាយ ដាក់ចាន ត្រីចៀន ឆាសាច់គោ យកទៅជូន ហ្លួងរតនសម្បត្តិខ្លួនឯង និងនារីបរិភោគនឹងស្ទឹកឈើ ឯលោកបាឡាត់ស្រុកបរិភោគនឹងក្រដាសកាសែត ដែលខ្ចប់ ឥវ៉ាន់មកពីផ្សារសង្កែ។

## វគ្គទី៤ ចោរកម្មកើតឡើងនាកណ្ដាលព្រៃស្ងាត់

លុះព្រះអាទិត្យជិតអស្ដង្គតទៅ នៅតែមានរស្មីព្រឿងៗឆ្លុះនៅចុងព្រឹក្សា បន្តិច ក៏ដល់ពេលព្រលប់យប់ងងឹត ចៅចិត្រ ក៏បង្កាត់ភ្លើង ឱ្យឆេះដង្កោល មានពន្លឺភ្លឺ ប្រាលរន្ទាល ដើម្បីឱ្យមានពន្លឺផង ដើម្បីការពារសត្វ សាហាវយង់ឃ្នងផង។ ឯនាង នារីអង្គុយ និយាយសន្ទនាចប្រាប់នឹង លោ កបាឡាត់ លើកំណាត់ឈើមួយដុំ មិនចេះ អស់មិនចេះហើយ។ ចំណែកខាងលោក ហ្លួ ងរតនសម្បត្តិ ដោយសេចក្ដីនឿយហត់ អស់កម្លាំងពេកក្រោយពេលដែលលោកពិសាក្រយាហើយ ក៏ប្រះសម្រាន្តលក់ក្នុង រថយន្តនោះទៅ។

មុខគួរឱ្យអនិច្ចាដល់ ចៅចិត្រ អុជបារីជក់អង្គុ យសំកុកមើលពន្លឺភ្លើងភ្លឺះៗ តែ ម្នាក់ឯងដែលលើភ្លើងភ្នក់ កំពុងឆេះប្រាលរន្ទា ល ឯគំនិតចេះតែគិតផ្សេងៗ អណ្ដែត អណ្ដូងទៅតាម

អារម្មណ៍របស់ចិត្តយូរៗដកដង្ហើមធំម្តង ប្រហែលជាចង់ជម្រុះទុក្ខធំ ដែល កប់នៅក្នុងទ្រូងឱ្យជ្រុះធ្លាក់ទៅខ្លះ។ ការធ្វើយ៉ាងនេះ ជាកិរិយារបស់មនុស្ស ដែលមាន ទុក្ខធ្ងន់ក្នុងទ្រូង តែទុក្ខសោកក្រហល់ក្រហាយរបស់បុរសកម្លោះៗ ដូច ជាចៅចិត្រ នេះគង់ មិនមានអ្វីក្រៅពីសេចក្តីស្នេហាប្រតិព័ទ្ធចំពោះរូបស្ត្រីក្រមុំណាមួយប៉ុណ្ណោះ ប៉ុន្តែសេចក្តី ស្រឡាញ់របស់ចៅចិត្រ នេះខុ សខ្ពង់ខ្ពស់គ្នាឆ្ងាយណាស់ ហាក់ដូចឈោងដៃចាប់បេះផ្កាយលើមេឃ ឥឡូវ នេះ ចៅចិត្រ ទទួលលន់តួថាខ្លួន ចាប់ចិត្តស្នេហាលើរូប នាងនារី ដែលជា ចៅហ្វាយក្រមុំរបស់ខ្លួនទុកជាមិនសមសក្តិ គ្នាយ៉ាងណាក៏ដោយ ក៏ចៅចិត្រ យល់ថាសេចក្តី ស្រឡាញ់ស្នេហារបស់បុរសស្ត្រីក្នុងលោកនេះ មិនមាន កម្រិតកំណត់ព្រំប្រទល់ដូចម្តេចឡើយ ដូច្នេះហើយបានជា ចៅចិត្រ ចង់ឈោងបេះផ្កាកុលាបបប៉ៃលិននេះ តែមក នឹកគិតថា ខ្លួនដៃខ្លីមិនគួរគប្បីប្រវាឱបភ្នំសោះ នឹងនាំឱ្យកើតទុក្ខទោមនស្ស ក្រៀមក្រំ ទៅជា ស្រឡាញ់បង់ចិត្តឥតប្រយោជន៍ នឹកមកដល់ត្រឹមនេះ ចៅចិត្រ ដកដង្ហើមធំម្តងៗ បារីមួ យក៏ឆេះអស់ទៅ ហូតបារីមួយទៀតមកជក់ជិតអស់ពាក់កណ្តាល ឯគំនិត ចេះតែគិតទៅៗ យ៉ាង លន្លង់លន្លោចតែម្នាក់ឯង ចំណែកខាង នាងនារី និយាយ សន្ទនាជាមួយនឹងបាឡាត់ស្រុក នោះហាក់ដូចជាត្រូវចិត្តគំនិតគ្នាណាស់។

ចៅចិត្រ បានឃើញកិរិយាដូច្នេះ គំនិតឥច្ឆាឈ្នានីសលោកបាឡាត់យ៉ាងលើសលន់ មើលទៅគេទាំងពីរនាក់ស្រុះស្រួលគ្នាល្អណាស់ ដូចជាគេវេញធ្នុងមួយ ប្រហែល ជាគេស្រឡាញ់គ្នារួចទៅហើយទេដឹង! មែនហើយ! បាឡាត់ នេះគាត់នៅ លីវ ថែម ទាំងមានទ្រព្យធនគ្រាន់បើផង ហើយរូបឆោមសោតទៀ តក៏មិនជាអាក្រក់ ប៉ុន្មាននាងនារី គង់ប្រថុយស្រឡាញ់គេរួចទៅហើយ ចុះចំណែកខាងអញ អញមានភាពដូចម្តេចទៅ? នាង នារី មានសភាពដូចម្តេចនៅខ្ពង់ខ្ពស់ទាបជាងគ្នាឆ្ងាយណាស់ បើទុកជានាងនារី នឹក ស្រឡាញ់អញដែរ ក៏គង់មិនហ៊ានប្រថុយទេ ក្រែងខូច កេរ្តិ៍ ឈ្មោះវង្សត្រកូលរបស់នាង ព្រោះអញមានឋានៈត្រឹមកម្មករ ហើយជាកម្មករ របស់នាងទៀតផង គឺអាត្មា អញតូចទាបទាំងបុណ្យសក្តិទាំងទ្រព្យធន ទាំងរបររកស៊ី ដូច្នេះអាត្មាអញមិនគួរ ជាប់ចិត្តស្រឡាញ់នាងទេ ដូចមានពាក្យបុរាណចងក្រងទុកថា "ខ្លួនទាប កុំតោង ដៃខ្លីកុំឈោងប្រវាឱបភ្នំ ឬ ដៃតូច ខ្លួនទាបចង់ឈោងចាប់ផ្កាយ" ចៅចិត្រ គិតមកដល់ត្រង់ណោះ ស្រាប់តែកើត គំនិតមួយជជែកនឹងគំនិត

មុនថា ធម្មតាសេចក្ដីស្នេហា ស្រឡាញ់ នេះមិនមានកម្រិតជាន់ថ្នាក់អ្វីឡើយ ប្រុស ស្រី គ្រប់រូបគេអាចស្រឡាញ់គ្នាបានតាមចិត្តស្ម័គ្ររបស់ខ្លួន សេចក្ដី សំខាន់បំផុតស្រេចទៅ លើម្ចាស់ខ្លួនខាងស្រីទេតើ! លុះចៅចិត្រ គិតដូច្នេះ ហើយក៏ដកដង្ហើមវែងម្ដងដើម្បីឱ្យធូរទ្រូង បន្តិច។

សូរស្បែកជើងតន្ទើនចូលមកជិត ចៅចិត្រក៏ក្រឡេកមើលឃើញនាងនារី កាន់កាំភ្លើងខ្លីមួយនៅក្នុងដៃមកផង ហើយសួរថា "មិនទាន់ងងុយដេកទេឬចិត្រ?"

ចៅចិត្រ ញញឹមហើយថា "ខ្ញុំបាទ មិនទាន់ងងុយទេយុន! នៅវេលានេះមិន ទាន់ ជាយប់ជ្រៅប៉ុន្មានទេតែនៅកណ្ដាលព្រៃ មើលទៅឃើញហាក់ដូចជាយប់ អាធ្រាតណាស់ទៅហើយ!"

នារី "ស្រួលហើយចិត្រ! បើមិនទាន់ងងុយនៅចាំយាមទៅសិនចុះ ហ៎! យកកាំភ្លើងនេះទុកបង្ការខ្លួន បើងងុយដេកវេលាណា ទៅដាស់លោកបាឡាត់ ឱ្យមកចាំយាមជំនួសវិញ"។

ចៅចិត្រ ទទួលយកកាំភ្លើងមក ហើយក៏សួរទៅនាងវិញថា "ចុះ យុន នឹង អញ្ជើញទៅសម្រាន្តឥឡូវនេះឬ?"។

នារី ញាក់ មុខហើយថា "ខ្ញុំគិតដេកពីព្រលប់បន្តិច ត្បិតអស់កម្លាំងតាំងពីថ្ងៃ មកហើយ"។

ចិត្រ "យុននឹកខ្លាចទេ ការដែលមកស្នាក់ក្នុងព្រៃស្ងាត់ដូច្នេះ?"។

នាងញាក់ស្មាម្ខាងថា "ខ្ញុំក៏នឹកខ្លាចខ្លះដែរ តែមិនសូវជាច្រើនប៉ុន្មានទេ"។

ចិត្រ "បើដូច្នេះ សូម យុន មេត្តានៅកំដរខ្ញុំបានបន្តិចសិនចុះ"។

នារី "អ្នកឯងខ្លាចណាស់ឬចិត្រ?"

ចិត្រ "សូមទោស ខ្ញុំបាទមិនជាខ្លាចណាស់ណាទេ ប៉ុន្តែខ្លាចក្រែងងក់ជ្រុល ដេកលក់ទៅ នាំឱ្យខូចការធំ!"

នាងនារី នៅតែស្ងៀមទើបចៅចិត្រ រកឧបាយផ្ដើមនិយាយឡើងមុនថា "ចុះ យុន នឹកទៅផ្ទះដែរឬទេ?"

នារី "ខ្ញុំនឹកដល់ផ្ទះច្រើនចិត្រ! ព្រោះមិនមានចាស់ទុំ នៅចាំផ្ទះសោះឡើយ"។

ចិត្រ "ព្រឹកស្អែកនេះ គង់តែបានទៅដល់ផ្ទះទាំងអស់គ្នា" ចៅចិត្រ និយាយ បន្តិច ស្ទើរតែមិនឮហើយថា "បើយប់នេះមិនមានរថឬរទេះមកតាមផ្លូវនេះទេ ខ្ញុំបាទ នឹង ក្រោកពីយប់ចេញដើរទៅប្រហែលជាថ្ងៃរសៀល គង់វិលមកទទួល យុន ត្រឡប់ ទៅដល់ ផ្ទះទាំងអស់គ្នាមិនខាន"។

នារី "ដើរតទៅរួចឬចិត្រ? ត្បិតផ្លូវពីនេះទៅផ្ទះយើងវាឆ្ងាយក្រៃលដែរ មិនមែន ជិតទេ"។

ចិត្រ "ទុកជារួចមិនរួចក៏ខ្ញុំបាទត្រូវតែទៅ បើខ្ញុំបាទមិនទៅទេ មុខតែនាំ គ្នា ដេកផ្លូវនៅទីព្រៃនេះជាច្រើនយប់ទៅទៀតមិនខានទេ ឱ! នុះហ្ន៎ យុន ព្រះចន្ទ្រនិង ផ្កាយតូចៗ នៅ ខាងគ្នានោះល្អមើលណាស់យុន គាប់ចិត្តនឹងធម្មជាតិនោះដែរឬទេ? ឯខ្ញុំបាទចូលចិត្តណាស់!"

នាង នារី សម្លឹងមើលទៅតាមដៃដែលចៅចិត្រ ចង្អុលប្រាប់ ព្រមទាំងចិត្ត គំនិត ក៏រីករាយទៅជាមួយផង ឥឡូវនេះនាងបាត់ស្អប់ខ្ពើមចិត្រ ហើយបែរជាមាន សេចក្ដី ពេញចិត្តថែមទៀតផង។ ចៅចិត្រ ជាប្រុសកម្លោះ ដំបូងដែលធ្វើឱ្យនាងមានចិត្តគំនិតយ៉ាងចម្លែកប្លែកជាងពីមុនមក ឯកម្លាំងរឹបុឹ ងរឹងរូសរបស់នាង ក៏ថយខ្សោយ ចុះទៅជាលំដាប់ ឥឡូវ ចិត្តនាងបែរជាទន់ភ្លន់ល្ងន់ល្ងៃដូចជាក្រមួនត្រូវកម្ដៅថ្ងៃ។

ចៅចិត្រ សម្លឹងមើលដួងចន្ទ្រដោយអាការស្ងាត់ស្ងៀម តែខាងក្នុងចិត្តដូចជា អណ្ដែតអណ្ដូងយ៉ាងចម្លែក ភ្នែកក៏មើលធម្មជាតិដ៏ល្អល្អះនៅខាងមុខ ហាក់ដូចជា មិនដឹង ខ្លួនថានាង នារី ដែលជាកូលាបក្រពុំព្រហ្មចារីនៅក្បែរខ្លួនឡើយ។

កាលនាងឃើញចៅចិត្រ នៅសម្ងំស្ងៀ មដូច្នេះហើយឮ សូរដកដង្ហើមវែងម្ដង ៗ ទើបសួរខ្សឹបៗថា "កើតទុក្ខអីចិត្រ?"

ចិត្រ "បាទ ខ្ញុំបាទកើតសេចក្ដីអផ្សុកយ៉ាងចម្លែក!" នាងនារី ញញឹមបន្តិចៗ ហើយ សួរថា "ម៉េចក៏អផ្សុកនឹកក្រមុំស្រុកសង្កែឬ?"

ចៅចិត្រ សើចយ៉ាងសោះកក្រោះហើយសួរថា "ស្រុកសង្កែ ឬ យុន ខ្ញុំបាទ ឥតនឹកនាបន្តិចឡើយ តាមដោយពិតនោះវា ជាស្រុកស្រណុកសប្បាយសម្រាប់អ្នកមានធនធាន ឯអ្នកទីទ័លក្រដូចរូបខ្ញុំបាទនេះ មិនបានអ្វីនាំឱ្យជាប់ចិត្តបន្តិចឡើយ"។

នារី សើចហើយសួរទៀតថា "ចុះស្រុកបប៉ៃលិននេះ តាំងពីចិត្រមកនៅ តើនាំ ឱ្យបាន សប្បាយចិត្តជាងនៅស្រុកសង្កែឬ?"

ចិត្រ "បាទ បប៉ៃលិន ឱ្យសេចក្តីសុខដល់ខ្ញុំបាទច្រើនណាស់ ដល់ទៅនឹកចង់ ផ្ញើឆ្អឹង នៅនឹងស្រុកនេះតែម្តង!"

នារី "ចុះខណៈនេះ អ្នកឯងនឹកនរណា បានជាមានទឹកមុខក្រៀមក្រំខ្លាំងម៉្លេះ"

កាលនាងនារីផ្លាស់សព្ទថ្មីពី "ចៅចិត្រ" មកជា "អ្នក" ដូច្នេះ ធ្វើ ឱ្យចៅចិត្រ មើល មុខនាង នារី សម្លឹងទាល់តែនាងនារីងាកមុខចេញ បែរមើលស្មៅនៅចិញ្ចើមថ្នល់ៗ

ចិត្រ "ឃុន ប្រើពាក្យថា "អ្នក" ជំនួស "ចិត្រ" នោះដូចជាខ្ពស់ពេកសម្រាប់ខ្ញុំ បាទ សូមឱ្យឃុន មានប្រសាសន៍ដូចមុនល្អជាង!"

នារី ស្ញៀមមួយស្របក់ ហើយពោលថា "ខ្ញុំគាប់ចិត្តប្រើពាក្យនេះជាង វាមិន ខ្ពស់ហួសទេ ជាពាក្យសុភាពគួរសមហើយ!"ៗ

ចៅចិត្រ នៅស្ញៀមទើបនាងនិយាយទៅទៀតថា "អ្នកឯងមិនទាន់ឆ្លើយពាក្យ សួររបស់ខ្ញុំនៅឡើយ ខ្ញុំសួរថា នៅបប៉ៃលិនឱ្យសេចក្តីសុខអ្វីដល់អ្នកឯងខ្លះ?"

ចិត្រ "ឱ្យច្រើនយ៉ាងណាស់ឃុន!"

នារី "អើ! អ្វីខ្លះ?"

ចិត្រ "ឱ្យមានរបរធ្វើការរកស៊ីដោយសុចរិត ធម្មជាតិដ៏ស្រស់បស់គួរជាទី ត្រេកត្រអាល ខ្យល់អាកាសក៏ល្អ សេចក្តីសុខ ឥស្សរភាព និង..."

នារី "និងអ្វីទៀត?" (នាងឈ្ងោចសួរ)ៗ

ចៅចិត្រ សម្លឹងមើលមុខនាងដោយសេចក្តីប៉ុនប៉ងអ្វីមួយនៅខាងក្នុងចិត្ត ហើយនិយាយខ្សាវៗ ស្ទើរជាខ្សឹបថា "នឹងសេចក្តីស្នេហា!"

នារី "សេចក្តីស្នេហា!" នាងផ្ទួនពាក្យឡើងទឹកមុខក្រហមព្រឿងៗ

ចិត្រ "ទានប្រោស សេចក្តីស្នេហារបស់ខ្ញុំបាទជាសេចក្តីស្នេហាដ៏បរិសុទ្ធពិត ប្រាកដណាស់ ហើយជាស្នេហាដែលផ្តើមកើតឡើងជាដំបូងបង្អស់ក្នុងជីវិតរបស់ខ្ញុំ បាទនេះផង"ៗ

នាង នារី ហាក់ដូចជាដឹងដល់ដួងចិត្តរបស់ចៅចិត្រ ដែរតែធ្វើជាឥតដឹងឥត យល់អ្វីដល់តិចឡើយ ហើយសួរតទៅទៀតថា "អ្នកឯងស្រឡាញ់អ្នកណា?"

ចិត្រ "ខ្ញុំស្រឡាញ់ស្រីម្នាក់"

នារី "ខ្ញុំដឹងហើយថាស្រឡាញ់ស្រី តែស្រីនោះនៅឯណា ? ឈ្មោះអ្វី? ឬមួយ នា ង ម៉ាយ៉ុង កូនក្រមុំតា ម៉ង់យ៉ុក មេអណ្តូងត្បូងមួយនៅខាងជើងផ្ទះយើងឬ ?" នាង ថាហើយ សើចយ៉ាងស្រួល។

ចិត្រ "គ្រវីក្បាលជំនួសពាក្យតប"។

នារី "អើ យ៉ាងចឹងនាងណាអះ ឬមួយនាង ព្រហ្ម កូនក្រមុំ តាសុន?"

ចៅចិត្រ ក៏គ្រវីក្បាលទៀត ជាសេចក្តីបដិសេធថាមិនមែនទាំងអស់។

នាង នារី ញញឹមស្រួលដោ យអស់សំណើចនឹងចៅចិត្រ ហើយថា "អេះ ប្រហែលជា អាមួយ កូន ចឹកសេង លក់ទឹកកក នៅមុខផ្ទះយើងទេដឹង?"

ចៅចិត្រ គ្រវីក្បាលទៀតហើយ "ខុសទាំងអស់ ស្ត្រីដែលខ្ញុំបាទស្រឡាញ់ នោះ មានថ្នាក់ជាន់ដោយឡែកពីគ្នានឹងខ្ញុំបាទ នាងមានឋានៈខ្ពស់ខ្ពង់ជាងខ្ញុំបាទច្រើន ទាំង កិត្តិយស ទាំងទ្រព្យសម្ប ត្តិ វង្សត្រកូលខ្ពស់ ទាល់តែខ្ញុំបាទឈោងតោង ទៅមិនដល់ឡើយ ហេតុនេះហើយ បានជាខ្ញុំ ជម្រាបថា សេចក្តីស្នេហារបស់ខ្ញុំបាទនេះ ប្រហែលនឹងការយល់ សប្តិនឹងត្រឡប់ទៅជារឿងពិតមិនបានឡើយ"។

កាលបើនាងបានឮសម្តី ចៅចិត្រ និយាយយ៉ាងក្រៀមក្រំខ្លោចផ្សា ដោយអស់សង្ឃឹម ក្នុងចិត្តដូច្នេះហើយ បេះដូងនាង ក៏ណែនតានតឹងក្នុងឱរជាខ្លាំង នាង ចង់តែសុំលន់តួប្រាប់ ដោយត្រង់ៗថា "នាងក៏ស្រឡាញ់ចៅចិត្រជាខ្លាំងដែរ" តែអនិច្ចាខ្លួនជាស្ត្រីនិយាយសម្តីដូច្នេះ សមគួរហើយឬ? ឯសម្តីចៅចិត្រ គ្រប់ម៉ាត់នាងស្តាប់ បានទាំងអស់ ឥតមាន ខ្វះកន្ទះ ត្រង់ណាមួយម៉ាត់ ត្បិតខ្លួ ននាងមានវ័យចម្រើនធំហើយ មិនមែនកូនក្មេងតូចទើបនឹងលែង បៅដោះកាលណា ប៉ុន្តែនេះវារហ័សពេកណាស់។ ឱ ! ចិត្រអើយ! នឹងបញ្ចេញប្រាប់រួសរាន់ ដូចម្តេចបាន ក្នុងថ្ងៃណាមួយ ចិត្រគង់ បាន ដឹងថា នារី ឥតស្អប់ខ្ពើមទេ ថែម ទាំងមាន ចិត្តស្នេហាស្រឡាញ់ទៀតផង មិនឥឡូវ ឥឡាទេ ជាវេលាយូរថ្ងៃខែមកហើយ។

ឯភ្លើងក្នក់ក៏រលត់សូន្យឈឹងទៅ សូរសព្ទវៃយំឮលាន់រំពងព្រៃ មាន់ក៏មមើល រងាវក្នុង រាត្រីស្ងាត់ ទឹកសន្សើមក៏ជ្រុះស្រ ក់ចុះពីស្លឹកឈើមិនដាច់សូរ ហើយមើល ឃើញសក្បុស នៅចុងស្មៅ ខ្យល់ត្រជាក់បក់មកត្រូវរាងកាយ នាំ ឱ្យរងាខ្លាំងឡើង ភ្នំខ្ពស់ត្រដែតនៅខាងមុខ

ត្រង់កណ្តាលពន្លឺដួងចន្ទ្រានោះ ហាក់ដូចអសុរកាយ ចាំឃ្លាំ រក្សាព្រៃព្រឹក្សាដ៏ស្ងាត់ច្រៀបនោះ។ ចៅ ចិត្រ ស្ទុះក្រោកឡើងលត់ខ្លួនប្រាណ ឱ្យបាត់ពោយស្រពន់ ដែល ទ្រាំអង្គុយនិយាយមកជាវេលាយូរហើយដកដង្ហើមធំ។

ចិត្រ "យប់ជ្រៅណាស់ហើយ អញ្ជើញ ឃុន ទៅសម្រាន្តឯរថយន្តជាមួយ លោកឪពុកចុះ ខ្ញុំបាទនៅចាំយាមសូមកុំព្រួយឱ្យសោះ!"

នារី "ចុះអ្នកឯងមិនទាន់ងងុយដេកទេឬ?" នាងក្រោកដើរទៅ ហើយងាកមក ញញឹមបន្តិច។

ចិត្រ "ខ្ញុំបាទមិនទាន់ងងុយទេ អញ្ជើញ ឃុ ន ទៅសម្រាន្តចុះ កុំបីមានសេចក្តី ព្រួយខ្លាចឱ្យសោះ អ្នកដែលចូលមកធ្វើអន្តរាយដល់ ឃុន បាននោះ លុះត្រាតែខ្ញុំ បាទ ស្លាប់ទៅជាខ្មោចមុនស្រេចហើយ ខណៈនោះខ្ញុំបាទនឹងយកជីវិតរក្សាការពារ អន្តរាយ គ្រប់ទិសសូមឱ្យឃុន សម្រាន្តជាសុខចុះ"។

នាងនារី ងាកបែរទៅរកចៅ ចិត្រ ម្តងទៀតព្រោះបានឮ សម្លេងស្រែកហៅ ដោយសម្លេងភិតភ័យតក្កមា។

"ឃើញទេ ឃុន! នុះហ្ន៎! ពន្លឺភ្លើងចម្លែកណាស់!"

នាង នារី សម្លឹងមើលតាមដៃដែលគេចង្អុលប្រាប់ ក៏បានឃើញពន្លឺភ្លើង ដូច្នេះមែននៅចម្ងាយជាង១គីឡូម៉ែត្រ នាងខំសង្កេតមើលទៅកាន់តែ ឃើញពន្លឺគប់ភ្លើងច្រើនឡើងៗ ហើយដើរសំដៅចូលមកកាន់តែជិតឡើងៗ នាងមានសេចក្តីភ័យខ្លាច យ៉ាងខ្លាំង ញាប់ ញ័រអស់សារពាង្គកាយ ព្រោះមិនដឹងជាមានហេតុល្អឬអាក្រក់ ដូចម្តេច នាងស្ទុះ ទៅចាប់ដៃចិត្រជាប់ដោយមិនដឹងខ្លួនប្រាណបន្តិចសោះ។

ចៅចិត្រ ប្រុកគ្រាប់កាំភ្លើងរួចស្រេច ប្រាប់នាងនារី ឱ្យទៅដាស់លោកហ្លួង និង លោកបាឡាត់ ឯរថយន្តមួយស្របក់ជនទាំង៣នាក់ ត្រឡប់មកវិញព្រមគ្នា។

លោកហ្លួង សួរយ៉ាងសស្ញើកស្ញក់ថា "កើតអីហ៎ា! ចៅចិត្ត?" ចៅចិត្រ ចង្អុល ទៅ ពន្លឺដែលកំពុងតែចូលជិតមកៗ ហើយថា "ទានប្រោស! សូមពិនិត្យមើលគប់ភ្លើង នុះ មិនទាន់ដឹងជាអ្វីទេ!"

"ប្រហែលជាពួកចោរទេដឹង?" លោកបាឡាត់និយាយឡើងមុនគេ។

"ប្រហែលជាពួកចោរមែន!" ចៅចិត្រ ថាផ្ទួនៗ កាលចៅចិត្រនិយាយដូច្នោះ ហើយ ហ្លួងរតនសម្បត្តិ និង លោក បាឡាត់ ក៏នាំគ្នារត់ទៅរថយន្ត រកបា នដៃករវៃ រថយន្តមួយម្នាក់ សម្រាប់ប្រើជាអាវុធបង្ការខ្លួនៗ

ឯងនាង នារី ញ័រខ្លួនចំប្រប់ដូចកូនសត្វ ឈរនៅក្បែរចៅចិត្រ ចៅចិត្រចាប់ដៃ នាងជាប់ ហើយប្រាប់ថា "យុន កុំតក់ស្លុតឱ្យសោះ ធ្វើចិត្តឱ្យក្លាហានឡើង យុន ភ្លេច ពាក្យដែលខ្ញុំបាទបានសន្យានឹងយុនហើយឬ?"

នាងមិនតបដូចម្ដេចឡើយ គ្រាន់តែចាប់ដៃជាប់ដោយភ័យស្ងន់ ចៅចិត្រ ប្រុង ខ្លួនយ៉ាងអង់អាច រង់ចាំពេលវេលាដែលនឹងមា នមកដល់ឥឡូវនេះ ជាពេលវេ លាដែលមិនទាន់ដឹងជាមានហេតុភេទដូចម្ដេចកើតឡើងនៅខណៈនោះទេៗ

នៅទីបំផុតស្រាប់តែឮសម្លេងស្រែកហ៊ោកងរំពងនាកណ្ដាលព្រៃស្ងាត់ នាំ ឱ្យដឹងថាពួកចោរនោះមានចំនួនច្រើននាក់ ហើយឮសូរកាំភ្លើងច្រើនណាត់បាញ់តម្រង់មក មានគ្រាប់កាំភ្លើងខ្លះធ្លាក់នៅខាងមុខចៅចិត្រក៏មានៗ

អ្នកទាំងពីរ គឺលោកហ្លួង និង លោកបាឡាត់ថយក្រោយ ទៅយករថយន្តជា គ្រឿងកំបាំងអន្តរាយ ហ្លួងរតនសម្បត្តិទុកជាចាស់ហើយក៏ពិតមែន តែនៅមានស្មារតី រហ័សរវាងវៃណាស់សមជាបុរសៗ ឯលោកបាឡាត់ សស្ញើតសស្លក់ ខំលូនចូលទៅ នៅខាងក្រោមរថយន្ត ឯងនាងនារី មិនព្រមឃ្លាតឆ្ងាយពី ចៅចិត្រឡើយ នៅតែចាប់ដៃជាប់ស្អិត ក្នុង ខណៈនោះ ចៅចិត្រ អែបបំបាំងខ្លួននឹងដើមស្រឡៅធំៗ

សូរសម្លេងហ៊ោគឹកកងរំពងនោះកាន់តែជិតមកៗ ចៅចិត្រខាំធ្មេញយ៉ាង ណែន ផ្គង់កាំភ្លើង ប្រុងស្មារតីយ៉ា ងអង់អាច ត្រៀម ខ្លួនចាំតទល់នឹងសត្រូវ ដើម្បីការ ពារស្រីជាទីស្រឡាញ់ពេញចិត្តរបស់ខ្លួនជីវិតខ្លួន និង អ្នកទាំងអស់គ្នាៗ

ពួកមហាចោរ ក៏បាញ់កាំភ្លើងគ្រាប់ប្រាយមកបាចសាចដូចជាគ្រាប់ភ្លៀងតែ ឥតត្រូវរាងកាយនរណាមួយឡើយ ព្រោះទីនោះជាទីងងឹតឈ្ងុបចាក់ភ្នែកពុំយល់ ចំណែក ខាងពួកចោរមានគប់ភ្លើងភ្លឺសន្ធោសន្ធៅពេញទាំងព្រៃ ដូច្នេះបានជាគ្រាប់ កាំភ្លើងដែលចៅចិត្របាញ់ទៅគ្មានខុសមួយគ្រាប់ ចោរខ្លះបាក់ដៃ ខ្លះបាក់ជើង ខ្លះ ដួលបង្គ្រាំងទៅក៏មាន

តែគ្រាប់កាំភ្លើងមានតិចពេក បានជាមិនអាចនឹងប្រហារចោរ ដែលមានចំនួនច្រើននោះ ឱ្យមានជ័យជំនះបានឡើយ។

ចៅចិត្រ ខំតស៊ូ យ៉ាងក្លាហាន ដើម្បីការពារជីវិតខ្លួន និង ជីវិតស្ត្រី សម្លាញ់ របស់ខ្លួន ដោយអង់អាចឥតខ្លាចស្លាប់បន្តិចឡើយ។

ហេតុភេទដែលមុខគួរឱ្យស្លប់ស្លែងនេះ នៅមិនទាន់ដឹងជាខាងណាចាញ់ឬ ឈ្នះឡើយ ពួកចោរទុកជាត្រូវគ្រាប់ដួលទៅជាច្រើននាក់ហើយក៏ដោយ ក៏ឥតរួញ ថយ ក្រោយ ហើយមានតែរុកចូលមកថែមកាន់តែច្រើនឡើងៗ ហើយចូលមកជិតទៅៗ ឥតឈប់ឈរ កាន់តែជិតខ្លួនគ្រប់ៗខណៈ។

ចៅចិត្រ បែរមកអោបនារីជាប់ ហើយនិយាយខ្សឹបប្រាប់នឹងត្រចៀកថា "គ្រាប់កាំភ្លើង នៅសល់តែមួយគ្រាប់ទេ យុននារី! ខ្ញុំបាទសូមលន់តួជម្រាប យុន ដោយ ស្មោះត្រង់ថា ខ្ញុំបាទ មានចិត្តស្រឡាញ់យុន ក្រៃលែងជាងជីវិតរបស់ខ្ញុំ បាទទៅទៀត ត្បិតក្នុងខណៈនេះ ពេល វេលាកាន់តែជិតដល់ទីបំផុតហើយ ខ្ញុំបាទនឹងទ្រាំលាក់យូរ ទៅទៀតពុំបាន ព្រោះ អវសាន នៃជីវិតខ្ញុំបាទកាន់តែចូលទៅជិតដល់ស្រុកខ្មោចហើយ យុននារី ខ្ញុំបាទ ត្រូវតែស្លាប់ ក្នុងគ្រានេះហើយ! ហើយចុះពួកវាគ្នាច្រើនណាស់ វាគង់ មិនទុកជីវិតខ្ញុំបាទឱ្យរស់នៅទេ ឯគ្រាប់កាំភ្លើងមួយគ្រាប់នេះ ខ្ញុំបាទនឹងចេញតទល់ការពារយុន ដោយយកជីវិតខ្ញុំបាទចេញ រងជំនួស សូមឱ្យយុន រត់ទៅពួនចុះ ខ្ញុំបាទនៅតស៊ូនឹងពួកវា"។

ចៅចិត្រ សម្តែងកិរិយាសោកស្តាយស្រណោះអាឡោះអាល័យយ៉ាងពន្លឹក ហើយ សួរ បញ្ជាក់ថែមទៀតថា "ស្រឡាញ់បងទេ នារី"

នារី "ចា៎! ស្រឡាញ់ចិត្រ ខ្ញុំស្រឡាញ់ ចិត្ររបស់នារីតែមួយនេះ ជាបណ្តូល ចិត្តរបស់ នារី!" នាងនិយាយទាំងទឹកមុខដោយក្តីរីករាយ ភិតភ័យលាយឡំគ្នាស្ទើរ និយាយមិនចេញ។

ចិត្រ "ស្រឡាញ់ខ្ញុំ! ឱបណ្តូលជីវិតរបស់បង! តែប៉ុណ្ណោះបងធ្មេចភ្នែកស្លាប់ជាសុខ ហើយ ប្អូនមាសព្រលឹង!"

នៅវេលាដែលនារីងាកទៅពួននឹងគល់ស្រឡៅវិញ ចៅចិត្រ ក៏តម្រង់កាំភ្លើង បាញ់ ទល់ នឹងពួកចោរ ស្រាប់តែឮសូរស្រែកយ៉ូយឡើង ដោយឈឺចាប់យ៉ាងខ្លាំង ចៅចិត្រយកដៃ ឱបដើមទ្រូងនារី ឃើញដូច្នេះក៏ញ័ររន្ធត់ទាំងខ្លួនប្រាណ។

ចៅចិត្រស្រែកប្រាប់ នារីថា "ខ្ញុំត្រូវគ្រាប់របស់ចោរហើយ ឃុននារី ! ស្រែកថ្ងូរតែក្នុងបំពង់ក ហើយមានឈាមហូរចេញពីខ្លួនក្រហមច្រាល ហើយប្រាប់ថា "ឃុននារី កុំនៅ រត់ ! រត់ទៅជាប្រញាប់ ទើបផុតអំពីកណ្ដាប់ដៃពួកចោរ " នាងទើបតែ ងើបពីគល់ស្រឡៅ ស្រាប់តែឮសូរប៉ុង! ប៉ុង! ជាច្រើនណាត់បាញ់មកទៀត ទើបនាង មុជក្បាលពួននៅគល់ស្រឡៅទៅវិញ ឯចៅចិត្រក៏ដួលសន្ធប់លើផ្ទៃផែនដីនៅត្រង់នោះឯង"។

## វគ្គទី៥ សេចក្ដីស្នេហាកើតក្រោយឧប្បត្តិហេតុ

មានពន្លឺផ្ទះចាំងមកស្រទន់ៗ នៃអរុណដែលទើបរះឡើងពីទិសបូព៌ានោះ មានពណ៌ភ្លឺប្រាលផ្ទៅ ជាម្បុរមាសយ៉ាងល្អហើយចាំងចូលតាមចន្លោះបង្អួចនិងចន្លោះទ្វារ វេលានោះ មានសត្វចាបតូចៗ ពីរបីហើរធៀលធ្លាត់ទទះស្លាបលេងយ៉ាង ក្បេ មក្សាន្តឥតមានព្រួយ អំពល់រវល់នឹងសេចក្ដីទុក្ខសោករបស់អ្នកឯណាឡើយ វាហើរ កម្សាន្តចិត្តនៅកណ្ដាលខ្យល់ ដែលកំពុងបក់មករំភើយៗក្នុងពេលព្រឹកព្រហាមហើយ ស្រែកហ៊ោកញៀវទៅតាមភាសាសត្វ។

ឯចៅចិត្រ ប្រែខ្លួនភ្ញាក់ស្មារតីឡើង ហើយស្រែកថ្ងូរដោយសេចក្ដីឈឺចាប់យ៉ាងខ្លាំង ហើយបើកភ្នែកក្រឡេកមើលទៅជុំវិញបន្ទប់ដេក រួច សម្លឹងទ្រឹងនៅនឹង រូបស្រីក្រមុំដ៏ មានរូបឆោមស្រស់បស់ម្នាក់ ដែលអង្គុយនៅបន្ទប់ របស់ខ្លួន ទើបចៅ ចិត្រ ហាមាត់ឡើង ប្រុងនឹងនិយាយទៅ តែនាងដណ្ដើមនិយាយឡើងមុន ថា "ចិត្រ! ចិត្រ រលឹកហើយឬ ?"

នាងសួរដោយសម្ដីទន់ផ្អែមល្ហែម!

ចៅចិត្រសួរនាងថា "ខ្ញុំបាទនៅឯណាឃុននារី ចុះហេតុដូចម្ដេចបានជា ខ្ញុំបាទមិនស្លាប់?"

នាងតបថា "ចិត្រ មិនស្លាប់ ចិត្រ ចាំមិនបានទេឬ ?" ទីនេះជាបន្ទប់របស់ ចិត្រ ឯងតែគេបានកែប្រែឱ្យបានស្រួល ដើម្បីឱ្យមានអាកាសល្អឡើង។

ផ្ការំចេកនៅនឹងដប ចោលក្លិនក្រអូបឈ្ងុយឈ្ងប់ពេញល្វែងបន្ទប់ នារីរឹកិលចូល មកជិត អ្នកជំងឺ ហើយសួរ "ពិសាបបរឬទេចិត្រ?"

នាយចិត្រ គ្រវីមុខយ៉ាងសន្សឹមៗហើយថា "អរគុណច្រើន យុននារី ខ្ញុំចង់ដឹងថា ខ្ញុំបាន ត្រឡប់មកដល់ទីនេះបានដោយហេតុយ៉ាងណា ? ហើយពួកចោរទៅឯណា អស់ទៅ?"

នាង នារី ញញឹមប៉ប្រែហើយថា "គឺយ៉ាងនេះ នៅ ពេលវេលាដែល ចិត្រ ត្រូវចោរបាញ់ដួលសន្ធប់ នៅពេលនោះ ស្រាប់តែ តាសុន បររថយន្តមួយធំមកតាមយើង ហើយមានគ្នាច្រើនផង គាត់ប្រាប់ថាឃើញពួកយើងបាត់ទៅយូរពេក គាត់មានសេចក្ដីព្រួយបារម្ភក្រែងមានគ្រោះថ្នាក់តាមផ្លូវ ទើបគាត់សុំខ្ចីរថយន្ត ម៉ុងថោងយ៉ុក ទៅទទួលយើង ស្រាប់តែប្រទះនឹងពួកយើងកំពុងច្បាំងនឹងពួកចោរ ហើយគាត់ជួយ ស្រែកហ៊ោបង្អើលពួកចោរ ទា ល់តែពួកចោររត់ខ្ចាត់ខ្ចាយចូលព្រៃអស់ទៅ ទើបពួក យើងនាំគ្នាលើកចិត្រដាក់រថយន្តមកផ្ទះនេះ ហើយលោកឪពុក ឱ្យមនុស្សទៅអញ្ជើញគ្រូពេទ្យមកពិនិត្យរក្សាអាការរបួសរបស់ចិត្រស្ដាប់បានទេ!"ៗ

នាយចិត្រ ដកដង្ហើមធំដោយអាការធូរក្នុងទ្រូងជាច្រើន សម្លឹងមើលទៅវង់ភក្ត្ររបស់នារី ហើយពោលថា "ខ្ញុំបាទគួរតែស្លាប់នៅក្នុងព្រៃនោះប្រសើរជាង មិនគួរនាំខ្ញុំបាទ មកទីនេះទេ ត្បិតនៅទីនេះ ខ្ញុំបាទមុខជាស្លាប់ដោយអាការក្រំចិត្តមិនខាន"

នារី "ចុះហេតុដូចម្ដេចបានជាចិត្រ និ យាយយ៉ាងហ្នឹង?" គ្មាននរណាចិត្តអាក្រក់ដល់បណ្ដោយឱ្យស្លាប់ដូច្នេះទេ ចិត្រ ដឹងទេ ឥឡូវនេះ អ្នកណាៗ ក៏គេស្រឡាញ់ ចិត្រទាំងអស់គ្នា លោកឪពុកមានប្រសាសន៍បើ ចិត្រ សះជាហើយ លោកនឹងតាំង ឱ្យ ជាអ្នកត្រួតត្រាមើលអណ្ដូងត្បូងទាំងអស់ជំនួសខ្លួនលោក មើលទៅដូចជាលោក ពេញចិត្តនឹង ចិត្រកាន់តែច្រើនឡើងៗ!

ចៅចិត្រ ស្ងៀមទៅមួយស្របក់ ទើបមើលមុខ នារី ដោយអាការសោ កៗថា " យុននារី យុន នៅចាំសម្ដីខ្ញុំបាទបានឬទេ កាលគ្រានិ យាយគ្នានៅក្រោមដើមស្រឡៅក្នុងយប់នោះ?" នារីញញឹមយ៉ាងស្រស់ ទន់ភ្លន់ហើយថា "ចាំ! ចាំបានទាំងអស់ ឥតភ្លេចមួយម៉ាត់ ណា សោះ ចុះហេតុអ្វីក៏សួរដូច្នេះ?"

ចៅចិត្រ ងាកប្រែខ្លួនផ្អៀងបន្តិចហើយថា "ទេ យុន តាមដោយពិត ខ្ញុំបាទមិនគួរនិយាយ ចេញមកសោះ តែដែលហ៊ាននិយាយដូច្នោះក្នុងវេលានោះ ព្រោះគិតជា ស្រេច

ថាមុខជាគ្មានជីវិតរស់នៅក្នុងលោកតទៅទៀតទេ តែឥឡូវនេះបែរជាមិនស្លាប់ នេះ ហើយ ដែលធ្វើ ឱ្យខ្ញុំបាទក្រៀមក្រំក្នុងឱរាត្រាតែអស់ជីវិតមិនខាន"។

នារី យកដៃបិទមាត់ថៅចិត្រ ជាប្រញាប់ហើយថា "គ្មាននរណាចិត្តអាក្រក់ធ្វើបាប ចិត្ររ ឱ្យបានសេចក្តីវេទនាដូច្នោះទេ មនុស្សល្អយ៉ាងនេះ តើនរណាស្អប់ ចិត្រ មិនជឿទៀតឬ ថា នារី ស្រឡាញ់ចិត្ររបស់ នារី យ៉ាងអស់ពីចិត្ត!"។

ថៅ ចិត្រ ញញឹមហើយថា "ជឿ ជឿអស់ពីពោះ ប៉ុន្តែនឹងមានប្រយោជន៍អ្វី កាល បើ ឋានៈ របស់យើងខុសគ្នាឆ្ងាយណាស់ ហាក់ដូចជាមេឃនិងដី!"។

នាង នារី នៅតែស្ងៀម

ថៅចិត្រ និយាយតទៅទៀតថា "ខ្ញុំជាមនុស្សភ្លើទេ យុន ដូចពាក្យទំនៀមថា "ធ្មុះ កញ្ចក់មិនមើលស្រមោលប្រាណ ដាំជើងក្រានមិនប្រមាណជើងថ្នាំង" ហេតុតែ អន្ទះ អន្ទែង ដែងបុណ្យក័ព្វសំណាងនេះហើយ នឹងនាំឱ្យគ្រោះថ្នាក់ដល់ខ្លួនមិនខាន ដូចបុរាណថា "ដៃខ្លី ខំប្រវាឱបភ្នំ" មានតែនាំឱ្យក្រៀមក្រំចិត្តឥតប្រយោជន៍ដរាបដល់ក្ស័យជីវិត មកតែអំពី មាន គំនិតឥតកំណើតដូចខ្លួនខ្ញុំបាទនេះឯង" ថាហើយក៏ដក ដង្ហើមធំដោយអាការអស់សង្ឃឹម។

នាង នារី សម្លឹងមើលមុខដោយចិត្តអាណិតអាសូរហើយនិយាយថា "គិត ច្រើនហួស ប្រមាណដោយខ្លួនឯង នារី ប្រាប់ហើយ ថាស្រឡាញ់យ៉ាងអស់ពីចិត្ត ក៏នៅតែមិនជឿ ទៀត ចុះឱ្យនារីធ្វើដូចម្តេច? នារីព្រមតាមគ្រប់យ៉ាង មិនមានអ្វីក្នុងលោកនេះមកកម្ចាត់ សេចក្តី តាំងចិត្តរបស់ នារី បានឡើយ នារីស្រឡាញ់ ចិត្រ តែម្នាក់នេះឯងមិនមានបុរស គម្រប់ ពីរទៀតទេ នារី មិ នត្រូវការអ្វីដទៃទៀតទាំងអស់ ក្រៅ អំពីសេចក្តីស្រឡាញ់ដ៏ស្មោះត្រង់ បរិសុទ្ធរបស់ចិត្រប៉ុណ្ណោះ"។

ចិត្រ "មែនឬនារី?" ញញឹមយ៉ាងរួសរាយ។

នារី "ពុទ្ធោ! នៅតែមិនជឿទេឬ?" នាងនិយាយដោយទោមនស្សអន់ចិត្ត។

ថៅចិត្រចាប់ទាញដៃនាង នារី មកថើបយ៉ា ងស្នេហាអស់ពីចិត្ត នារី ក៏ជ្រប់ មុខនឹង ដើមទ្រូងរបស់ប្រុសកម្លោះសម្ងាញ់ សេចក្តីស្នេហាដែលកប់ទុកក្នុងចិត្តមកជាវេលាយូរ ក៏ ខ្ចាយផ្សាយប្រាប់គ្នាទៅវិញទៅមក ដោយពិតត្រង់ទាំងអស់ ពីដើមមក នារីធ្លាប់មើល ងាយប្រមាថថៅចិត្រ ហើយស្អប់ថៅចិត្រ តែនៅទីបំផុតនេះ ប្រែជាស្រឡាញ់គេវិញ

ហើយជាសេចក្តីស្នេហាស្រឡាញ់យ៉ាងបរិសុទ្ធ ស្មោះត្រង់ ទន់ផ្អែម ត្រជាក់ចេញមកពីបេះដូងដែលថ្វាផ្ទរផង់ខ្ជាប់ខ្ជួនឥតមានចាស់ទុំបង្ខំចិត្តឡើយ។

នៅឱកាសដែល កម្លោះក្រមុំកំពុងនិយាយចរចាសាស័ព្ទយ៉ាងក្តីតក្តីនោះ ស្រាប់តែ ឮសូរជើងមនុស្សឡើងជណ្តើរមក ទើបនាងនារី បើកទ្វារចេញទៅទទួល លោកហ្លួងរតនសម្បត្តិ និងគ្រូពេទ្យ ជនទាំងពីរក៏ដើរចូលទៅក្នុងបន្ទប់ចៅចិត្រ។ ចៅចិត្រធ្វើអាការហាក់ដូចជានឹងក្រោកឡើង តែលោកហ្លួង លើក ដៃហាមថា "កុំក្រោក ដេកតាមសប្បាយចុះ" ហើយងាកទៅសួរគ្រូពេទ្យថា "ថ្ងៃនេះ អាការរោគ ដូចម្តេចខ្លះ លោកគ្រូ?"

លោកគ្រូពេទ្យ ចាប់ដៃអ្នក ជំងឺត្រួតសព្វគ្រប់ហើយ ទើបនិយាយថា "គ្រាន់បើឡើងច្រើន ព្រោះគ្រាប់កាំភ្លើងដែលចោរបាញ់ត្រូវគេចផុតពីកន្លែងសំខាន់ៗ ទាំងអស់"។

លោកហ្លួងនិយាយថា "គ្រោះល្អណាស់! ខ្លួនខ្ញុំនិងកូនខ្ញុំ ប្រសិនបើមិនបាន ចៅចិត្រជួយ ការពារក្នុងគ្រានោះទេ មិនដឹងជាដូចម្តេចទេ ចុះប៉ុន្មានថ្ងៃទៀត ទើបបានជាសះស្បើយ លោកគ្រូ?"

លោកគ្រូពេទ្យ សម្លឹងមើលនាងនារី ហើយញញឹមនិយាយថា "ខ្ញុំបាទគិតថា បើមានអ្នក ថែរក្សាជំងឺចំណាប់ចំនួនបែបនេះ គង់សះ ជាឆាប់រហ័សមិនខាន តែវេលា នេះតោងឱ្យអ្នក ជំងឺដេកឱ្យស្ងៀម ទម្រាំឱ្យរបួសសះល្អសិន"។

ឯនាយចិត្រ សម្តែងសេចក្តីអរគុណដល់លោកហ្លួង និង គ្រូពេទ្យ ហើយ លោកទាំងពីរក៏ នាំគ្នាដើរចេញទៅ ឯហ្លួងរតនសម្បត្តិ ងាកមកប្រាប់ចៅចិត្រថា "តាំង ពីថ្ងៃនេះតទៅទុក ជាចៅចិត្រ សះជាខ្លួនហើយ ក៏មិ នបាច់ធ្វើការនៅអណ្តូងត្បូងដូចមុនៗទៀតទេ ខ្ញុំតាំងឱ្យអ្នកឯងជាជំនួសខ្ញុំ ត្រួតមើលអស់ទាំងអណ្តូងដែលពួកកម្មករ ជីកមកទាំងប៉ុន្មាន រៀបចំតាមប្រភេទរបស់ត្បូង មិនបាច់ទៅធ្វើការធ្ងន់ដូចសព្វដងទេ ក្រែងនាំឱ្យជំងឺរើឡើងវិញ" រួចលោកគ្រូពេទ្យ និង ហ្លួងរតនសម្បត្តិ នាំគ្នាដើរចុះពីផ្ទះទៅ។

ដោយហេតុនោះនាងនារី យកចិត្តទុកដាក់ថែរក្សាព្យាបាលជំងឺដោយផ្ចិតផ្ចង់ជំងឺចៅចិត្រ ទើបមានអាការគ្រាន់បើឡើងជាលំដាប់ ហើយនៅទីបំផុត ក៏បានសះជា ដូចប្រក្រតីវិញ ទាំងឥឡូវនេះ មិនបាច់ ចេញទៅជីកត្បូងបែកញើសតាងទឹក ដូចពី មុនទៀតផង គ្រាន់តែ ជួយចាត់ចែងធ្វើបញ្ជីត្បូ ង ដែលពួកក ម្មករជីកបានមកពីអណ្តូងផ្សេងៗ

ព្រមទាំងបើក ប្រាក់ខែ ឱ្យពួកកម្មករ ទើបនាំ ឱ្យចៅចិត្របានសេចក្ដីសុខឡើងទៀតជាច្រើន សុខទាំងកាយ សុខទាំងចិត្ត គឺថាស្រុកបប៉ៃលិន ទុកជាស្ថានសួគ៌របស់ចៅចិត្រ តែម្ដង ហើយគេតែងគិតជានិច្ចថា នឹងតាំងខ្លួនប្រាណ ឱ្យបានខ្ជាប់ខ្ជួន ត្រាតែដល់នូវវារៈ បំផុតនៃជីវិត តិន្ទ្រីយ៍។

ថ្ងៃនេះ អាកាសភ្លឺស្រឡះល្អមានខ្យល់បក់រំភើយៗ ល្មមតែត្រជាក់ស្រួល នារីបបួលចៅចិត្រ ចុះទៅអង្គុយនិយាយគ្នាលេងនៅក្នុ ងសួនច្បារក្រោមផ្ទះ ស្ដាប់សូរ ស័ព្ទបក្សាបក្សី ស្រែកយំ តាមភាសារបស់វា ជាទីកម្សាន្តចិត្តរបស់អ្នកដែលមានមេត្រីស្នេហាដល់គ្នា។

ចៅចិត្រ និយាយតិចៗ កាលឃើញនាង នារី នៅស្ងៀមថា "យុននារី"។

នារី "ចាំ!" នាងញញឹមយ៉ាងទន់ភ្លន់ហើយថា "នៅជាមួយចិត្រ យ៉ាងនេះ នារី មានសេចក្ដី សុខយ៉ាងលើសលន់តែម្ដង!"។

គេញញឹមប៉ប្រែ ហើយថា "មិននឹកសោះឡើយថា ទេវតាប៉ៃលិនប្រោស ប្រាណបង ដល់ ម្ល៉េះទេ" នាងធ្វើជាសម្ងក់តាមមាយាស្ត្រី ហើយស្រដី ថា "ដឹងថាគេស្រឡាញ់ខ្លួនបន្តិច ក៏តាំងអួតយ៉ាងសម្បើមតែម្ដងហ្ន៎!"

ចិត្រ "ចុះស្អប់បងណាស់ឬអី!"។

នារី "ស្អប់ណាស់" នាងតបចាក់បណ្ដោយ។

ចៅចិត្រ ញញឹមប៉ប្រឹមហើយថា "បើស្អប់បងណាស់ ម៉េចក៏មិនទុកចោល ឱ្យស្លាប់នៅក្នុង ព្រៃនោះទៅ"។

នាងបែរមកសម្ងក់ហើយថា "ដោយគេអាណិតបន្តិចទេតើ កុំអី ត្មាតផ្ដុំខ្ទុយក្នុងព្រៃនោះ ទៅហើយ"។

ស្ងៀមទាំងអស់គ្នាទៅមួយស្របក់ ចៅចិត្រក៏ចាប់និយាយឡើងជាមុនថា "អើ! យុននារី លោកឪពុកបានជ្រាបរឿងរ៉ាវរបស់យើងខ្លះដែរឬនៅឡើយទេ?"

នារី "មិនទាន់ជ្រាបទេ"។

ចិត្រ "បើលោកជ្រាប មុខជាលោកធ្វើទោសបំបរបង់ដូចម្ដេចមិនដឹងទេ បងព្រួយចិត្តណាស់!"

នារី "រឿងនេះខ្ញុំដឹងមិនដល់ទេ ព្រោះលោកមិនដែលពូនិយាយដូចម្ដេចសោះឡើយ"។

ចៅចិត្រ និយាយដោយទឹកមុខស្រពោនថា "ប្រសិនបើលោកជ្រាបមុខជាដេញបងឱ្យចេញពីផ្ទះនេះមិនខាន"។

នារីសម្លក់ដាក់ទៅចិត្រម្ដងទៀតហើយនិយាយ "ឆ្មើមសម្ដីបងឯងណាស់ បងចិត្រ លោក ពុកមិនមែនចិត្តអាក្រក់ដល់ម្ល៉េះ ទេ លោកចា ស់ទុំហើយ តែងតែស្គាល់ឫទ្ធិ អំណាច សេចក្ដីស្នេហាច្បាស់លាស់ជាងក្មេងៗទៅទៀត"។

ចិត្រ "ឯបងជាមនុស្សកំសត់ទុគ៌ត ឥតទ្រព្យសម្បត្តិ ទាំងកំព្រីកំព្រាផង មានតែជីវិតនិង រាងកាយប៉ុណ្ណោះ"។

នារី "ប៉ុណ្ណឹងក៏ល្មមគ្រប់គ្រាន់ហើយ"។

ចិត្រ "គ្រប់គ្រាន់តែចំពោះអូននារីប៉ុណ្ណោះ"។

នារី "ទោះបីលោកពុក ក៏មិនត្រូវការអ្វីទៀតដែរ"។

ចិត្រ "ចុះប្អូន នារី ដឹងចិត្តលោកបានឬ?"។

នារី "ចាំ ដឹងខ្លះដែរ ធម្មតាឪពុក និ ង កូននៅជាមួយគ្នាយូរអង្វែងណាស់មក ហើយតែងតែដឹងគ្នាខ្លះមិនខាន កុំថាគ្រាន់តែដឹងចិត្តលោកឪពុកម្នាក់ឡើយសូម្បីតែ ..."។

"ចិត្តរបស់បង ប្អូននារី ក៏ដឹងទាំងអស់ដែរ" ចៅចិត្រនិយាយបញ្ចប់ប្រយោគ។

នារី សម្លក់ហើយថា "ដឹងខ្លួនទេ បង ប៉ុនកុហកលេខមួយ?"

ចិត្រ "បងកុហកប្អូនដូចម្ដេច? (ធ្វើមុខដូចជាឆ្ងល់)"។

នារី "កុំធ្វើពើឡើយ លោកពូកូនសិស្សសាលាវត្ត"។

ចិត្រ "ក៏បងរៀនសាលាវត្តមែននេះណ៎ា!"

នារី "ចុះសាលាវត្ត គេមានរៀនដល់ប្រវត្តិពង្សាវ តាលោក ភូមិសាស្ត្រ វិទ្យាសាស្ត្រទំនើប ថ្មីដែរឬ?"

ចិត្រ "ទេ" ឆ្លើយធ្វើមុខព្រងើយ។

នារី "នាងផ្ដួនពាក្យថា តែខ្ញុំបានឃើញសៀវភៅអស់នេះនៅក្នុងបន្ទប់របស់បងឯងហើយ មានស៊ីញ៉េឈ្មោះបងឯងជាភាសាបារាំងផង"។

ចៅចិត្រ មិនឆ្លើយគ្រាន់តែញញឹម។

នារី "ប៉ិនកូតដូចសព្វដង នេះនែ! បងចិត្រ! ចុះកាលណាបងឯងចោលនិស្ស័យរឹងរូសចេញ បើនៅតែកុហកខ្ញុំទៀត ខ្ញុំនឹងខឹងច្រើនតែម្តង"។

ចៅចិត្រ ខិតចូលទៅកាន់តែជិតហើ យថា "ប្អូននារី ហ៊ានខឹងនឹងសង្សារ កំសត់បានឬ?"

"មិនជឿនឹងលមើលក៏បាន នារី អាចនឹងស្អប់ប៉ុនគ្នានឹងស្រឡាញ់ក៏បាន"។

ចៅចិត្រ សើចយ៉ាងសប្បាយចិត្តហើយថា "បងក៏ដឹងថាប្អូននារី មិនស្អប់បងទេ"។

នារី "ចុះហេតុអី?"

ចិត្រ "ក៏ប្អូននារី ប្រាប់ថាស្រឡាញ់បងដែរមែនទេ?"

នារី លូកដៃមួលក្ដៅចៅចិត្រ ទាល់គេស្រែក ទើបនាយចិត្រ អោបក្រសោប ដៃនារីហើយពោលថា "ម្តងនេះបងលែងកុហកប្អូនទៀតហើយ ត្បិតគ្រប់យ៉ាងគ្រប់ ប្រការ យើងបានដឹងគ្នាច្បាស់លាស់ហើយ មែនទេប្អូននារី?"

នាងសម្លឹងមើលមុខគេដោយមេត្រីចិត្ត ហើយផ្លាស់និយាយពីរឿងផ្សេងៗថា "អេ៎! បងចិត្រ ឥឡូវនេះត្បូងរបស់យើងដូចម្តេចខ្លះ?"

ចៅចិត្រ ឆ្លើយថា "ឥឡូវចម្រើនឡើងច្រើន អណ្តូ ងត្បូងទិសខាងកើត ជីកបានត្បូងទឹកជម្មតាជាងដប់គ្រាប់ អណ្តូ ងខាងលិចជីកបានត្បូងទឹកយ៉ាងល្អ៦ទៅ៧គ្រាប់ ឥឡូវត្បូង ទាំងអស់របស់យើងមានចំនួនជាង ២០០គ្រាប់ បើគិតទៅមានតម្លៃជាង ១ម៉ឺនរៀល"។

ក្រមុំកម្លោះទាំងពីរ និយាយសំណេះសំណាលសារសងគ្នាទៅវិញទៅមក យ៉ាងក្សេមក្សាន្ត សឹងពោរពេញដោយសេចក្តីស្នេ ហាក្នុងគ្រានោះ គេឥតនឹកនាអំពី សេចក្តីលំបាកក្នុងការចិញ្ចឹមជីវិតបន្តិចឡើយ គិតតែសប្បាយរីករាយក្នុង ការផ្តេកផ្តិត សម្រួលកាយសម្រួលចិត្តទៅតាមព្រះហឫទ័យ នៃព្រះ កាមទេពជាម្ចាស់ដែលទ្រង់មានឫទ្ធិជាពន្លឹកលើដួងចិត្ត នៃក្រមុំកម្លោះទាំងឡាយក្នុងលោកិយនេះ។

## វគ្គទី៦ គេហដ្ឋានរតនសម្បត្តិត្រូវចោរប្លន់

នៅក្នុងថ្ងៃមួយនោះ ជាវេលារសៀលម៉ោងប្រហែល ៤ នាងនារីនិងចៅចិត្រ កំពុងអង្គុយធ្វើបញ្ជីត្បូងនៅក្នុងបន្ទប់ធ្វើការ នាងនារី ផ្ដើមនិយាយឡើងថា "តាំងពី បង ចិត្រ មកនៅ ធ្វើការជាជំនួយលោកឪពុកកាលណា កិច្ចការក៏ ចម្រើនឡើងច្រើនជាងពីដើម" នាងនិយាយដោយសុចរិត ហើយ នឹងចាប់និយាយតទៅទៀត ស្រាប់តែឮសូរ សម្លេងរថយន្តមួយមកចតនៅមុខផ្ទះរតនសម្បត្តិ ចៅចិត្រក៏ស្ទុះក្រោកឡើងទៅមើលតាមចន្លោះបង្អួច ហើយត្រឡប់ មកអង្គុយកន្លែងដើមវិញ។

នារី "បងចិត្រអ្នកណាមកហ្នឹង?"

ចិត្រ "បាឡាត់ស្រុកសង្កែ តែម្នាក់ទៀតបងមិនស្គាល់"។

នារី "អេ៎! គេមករកអ្វី? ចុះបងចិត្រ មិនទៅទទួលភ្ញៀវជំនួសលោកឪពុកផង"

ចៅចិត្រ ក្រោកឡើងដើរចេញនាំនាងនារី ឱ្យដើរតាមទៅផង ឯលោកបាឡាត់ ឈរ យ៉ាងអង់អាចនៅខាងមុខផ្ទះជាមួយនឹងបុរសម្នាក់ទៀត មានពងមាំខ្មៅ សក់ក្រញាញ់ ភ្នែកក្រលួង ចៅចិត្រដើរចូលទៅសួរយ៉ាងសុភាព "ទានប្រោស លោកអញ្ជើញមករកអ្នកណា?"

តែលោក បាឡាត់ គ្រាន់តែញាក់មុខ ហើយងាកទៅទទួលសំពះនាងនារី ដែលឈរពីក្រោយ ចៅចិត្ររួសរាយប្រស្រ័យនឹងនាងដោយឥតរវល់នឹងចៅចិត្រ ដែលឈរជ្រងោ នៅចំពីមុខនោះឡើយ។

បាឡាត់ "លោកឪពុកនៅទេ ឃុននារី?"

នារី "ចាំនៅ! មើលទៅលោកប្រហែលជានៅក្នុងបន្ទប់មើលសៀវភៅខាងលើ ចុះលោក បាឡាត់មានធុរៈអ្វី?"

បាឡាត់ "បាទ មានខ្លះដែរ គឺខ្ញុំបាទ នាំថៅកែផាន់មកទិញត្បូងដើម្បីយកទៅលក់ឯព្រៃនគរ" លោកបាឡាត់ តបហើយខំញញឹមឱ្យស្រស់តែត្រឡប់ទៅជា ទាស់ភ្នែករបស់ ចៅចិត្រជាបំផុត។

នាងនារី ញញឹមទទួលដោយកិរិយាទន់ភ្លន់ ហើយនិយាយថា "អញ្ជើញ លោកឡើងទៅខាងលើ ឱ្យជួបនឹងប៉ានិយាយថ្លៃគ្នាចុះ" ថាហើយ នាងក៏ដើរនាំមុខ ភ្ញៀវឡើងទៅលើផ្ទះថ្នាក់លើ ជួបនឹងលោកហ្លួង កំពុងដេកមើលសៀវភៅនៅលើកៅអីផ្ដោ លោកក៏ក្រោក

ឡើងនិយាយរាក់ទាក់ដោយសេចក្ដីស្និទ្ធស្នាលថា "អា! លោក បាឡាត់ ឬ ? អញ្ជើញ! អញ្ជើញមកខាងនេះ ចុះលោកមានធុរៈអ្វី?"

បាឡាត់ "ខ្ញុំបាទនាំថៅកែ ផាន់ មកទិ ញត្បូង" លោកបាឡាត់ឆ្លើយព្រមទាំងទាញកៅអី មួយ ឱ្យថៅកែផាន់ អង្គុយខ្លួនឯងក៏អង្គុយលើកៅអីមួយក្បែរខាង នាងនារី ឯថៅចិត្រឈរឃ្លាតឆ្ងាយពីនោះបន្តិច ដ្បិតមិនទាន់ទុកចិត្តមនុស្សចំណូល ថ្មី រាងធំ ភ្នែកក្រឡោត ដែលឈ្មោះថា ថៅកែផាន់ នោះសោះ។

ហ្គួងរតនសម្បត្តិងាកទៅខាងថៅកែផាន់ហើយសួរថា "ថៅកែត្រូវការទិញត្បូងបែបណា?"

ផាន់ "ខ្ញុំបាទតោងសុំពិនិត្យមើលសិន បើត្រូវចិត្តខ្ញុំបាទ នឹងនិយាយថ្លៃទិញយកទៅលក់ឯព្រៃនគរ"។

ហ្គួង "បាទបានថៅកែវេលានោះ ត្បូងមានច្រើនពណ៌ផ្សេងៗ ទឹកល្អទាំងអស់" ហើយលោកហ្គួង ងាកទៅខាងថៅចិត្រ ប្រាប់ថា "ចិត្រ ទៅយកត្បូងមក ឱ្យថៅ កែពិនិត្យមើលបន្តិចមើល!"។

ថៅចិត្រ ដើរចូលទៅក្នុងបន្ទប់បាត់ទៅមួយស្របក់ត្រឡប់មកវិញ កាន់ហឹបត្បូង ដែលឆ្នៃហើយ ២-៣ ហឹប យកទៅដាក់លើតុ ហើយបើកបង្ហាញថៅកែ ផាន់។

ថៅកែផាន់ និងលោកបាឡាត់ បើកភ្នែកគ្រលួងកាលដែលបានឃើញត្បូងពណ៌ផ្សេងៗក្នុងហឹបនេះមានចំនួនដល់ទៅជាង ២០០គ្រាប់ ថៅកែផាន់ ចាប់លើក ឡើងពិនិត្យមើលដោយប្រុងប្រយ័ត្ន ហើយដា ក់ទៅវិញនិយាយថា "ត្បូងអស់នេះ ទឹក ល្អមែនប្រហែលជា មានតម្លៃច្រើន?"

លោកហ្គួង គ្រវីក្បាលហើយថា "មិនសូវជាថ្លៃប៉ុន្មានទេ មានតម្លៃថោកជាងឯព្រៃនគរច្រើន"។

រួចថៅកែ ផាន់ ចាប់មួយគ្រាប់ លើកឡើងមើលម្ដងទៀត ហើយសួរថ្លៃថា "ទានប្រោស មួយគ្រាប់នេះតម្លៃប៉ុន្មានទៅ?"

ហ្គួង "យ៉ាងនេះទឹកល្អច្រើន ១ក្រាត់ ថ្លៃ ២០០រៀល ក្នុង ១គ្រាប់នេះ ប្រហែល ជា ៤ក្រាត់"។

ផាន់ "ទានប្រោស ថ្លៃបន្តិច បើចុះបន្តិចទៅទៀតបានទេ?"

ហ្ជួង "មិនជាអ្វីទេ បើថៅកែត្រូវការក៏ចុះជូនឱ្យបានខ្លះ ដោយសេចក្តីរាប់អានគ្នា"។

ផាន់ "ចុះថ្លៃប៉ុន្មាន?"

លោកហ្ជួងចាប់ត្បូងនោះមកពិនិត្យមើលម្តងទៀតហើយថា "បែបនេះចុះជូនបាន ១ក្រាត់ ២០រៀល"។

ថៅកែ ផាន់ មើលមុខលោកបាឡាត់ ជាទំនងសូមឱ្យជួយគិតគូរតថ្លៃផង។

ឯលោកបាឡាត់ ញាក់មុខប្រាប់ថា "គួរសមហើយថៅកែ ព្រោះត្បូងបែបនេះ មិនងាយរក ទេក្នុងវេលានេះ"។

ថៅកែក៏ញញឹមឃើញធ្មេញស្ញេញ ហើយនិយាយតថ្លៃនឹងហ្ជួងថា "រឿងនេះទុកជាស្រេចទៅចុះ តែវេលានេះ ខ្ញុំបាទមិនបានយ កប្រាក់មកទេ ដល់ព្រឹកស្អែក ខ្ញុំ បាទនឹងយកប្រាក់មកជូន ហើយទទួលត្បូងទៅផង មើលទៅប្រហែលជាត្រូវការ ចំនួនច្រើនគ្រាប់ផង"

ហ្ជួង "បាទបាន! អង្កាលក៏បាន ខ្ញុំនៅផ្ទះជាដរាប បើអញ្ជើញមកគង់តែជួបខ្ញុំជានិច្ច"។

ថៅកែ ផាន់ និយាយដោយឱន លំទោន "សូមអរគុណ តែខ្ញុំបាទសូម ឱ្យលោកមេត្តាបន្តិច ដ្បិតខ្ញុំបាទមិន ដែលឃើញរបៀបជីកត្បូងសោះ សូមលោកបើក ឱកាសឱ្យខ្ញុំបាទទៅមើលបានឬទេ?"

លោកហ្ជួងសើចហើយថា "បាទបាន! ថៅកែខ្ញុំមិនកំណាញ់ទេ មានអណ្តូង ត្បូងនៅក្បែរ ៗផ្ទះនេះក៏មាន នៅខាងក្រោយផ្ទះនេះឯង អញ្ជើញទៅមើលបានតាមត្រូវការ"។

លោកហ្ជួងក៏ក្រោកចេញពីកៅអីហើយថា "អញ្ជើញមកតាមខ្ញុំ ថៅចិត្រ ទៅជាមួយផង"។

ថៅចិត្រ មិនចង់ចេញចោលពីនាងនារីឡើយ គេក្រឡេកមើលបា ឡាត់ស្រុកនោះដោយកិរិយាមិនទុកចិត្តសោះ ហើយសួរទៅថា "សូមទោស លោកមិន អញ្ជើញ ទៅមើលទេឬ?"

លោកបាឡាត់ គ្រវីក្បាលហើយថា "មិនទៅទេ ធ្លាប់មើលរាប់រយដងហើយ"

ឯនាងនារី ក្រោកឡើងប្រុងនឹងដើរតាមថៅចិត្រ ទៅដោយនាង ដឹងចិត្តរបស់គូស្រករនាង យ៉ាងច្បាស់ តែបាឡាត់ស្រុកឃាត់នាងថា "ប្រញាប់អញ្ជើញទៅណា យុននារី ទុក ខ្ញុំបាទឱ្យអង្គុយផក់តែម្នាក់ឯងឬអី?"

នាងនារីបែរចេញមកញញឹមតាមទំនៀមទាំងមិនដោះសារថាអ្វី ក៏ដាក់គូថ អង្គុយលើកៅអីដដែល ដោយទឹកក្រែងចិត្តក្មៀវហើយសួរថា "លោកបាឡាត់មានរឿងអ្វីនិយាយ នឹងខ្ញុំឬ?"

កាលបាឡាត់ស្រុក នោះឃើញថៅចិត្រ ចេញ ផុតទ្វារទៅហើយក៏លើកកៅអីចូលមកជិតនាងនារី ហើយក៏ញញឹមប៉ប្រឹម រួចនិយាយថា "រឿងរបស់ខ្ញុំមានច្រើនណាស់"។

"មានរឿងអ្វីខ្លះ អញ្ជើញមានប្រសាសន៍ទៅចុះ ខ្ញុំនឹងចាំស្ដាប់"។

បាឡាត់ស្រុក សម្លឹងមើល នាងនារី ដោយទឹកមុខ ចម្លែកហើយនិយាយតិចៗ ស្ទើរតែទៅជាខ្សឹបថា "យុននារី ខ្ញុំមានរឿងសំខាន់ណាស់ដែលត្រូវនិយាយផ្ទាល់ខ្លួន យុន!"។

នាងនារី អង្គុយនៅតែស្ងៀ ម លោកបាឡាត់ ក៏និយាយតទៅថា "ជារឿងសំខាន់ស្មើជីវិតរបស់ខ្ញុំតែម្ដង ត្បិតជីវិតខ្ញុំរងកម្មយូរណាស់មកហើយ!"

ទើបនាងនារីដឹងខ្លួនថា បាឡាត់ នោះ និយាយបែចង់ខ្លួននាងហើយ តែធ្វើជា មិនដឹងរឿងរ៉ាវអ្វី នៅតែស្ងៀមដូចប្រក្រតី។

បាឡាត់ "យុននារី"។

នារី "ចាំ!"

បាឡាត់ "មេត្តាជួយសង្គ្រោះខ្ញុំបាទផងបានទេ?"

នារី "ចុះនឹងឱ្យជួយលោកបាឡាត់ដូចម្ដេចខ្លះ?"

បាឡាត់ "បើយុនស្ម័គ្រជួយមែន មុខជាបានផលជាប្រាកដ"។

នារី "លោកបាឡាត់ មិនទាន់ប្រាប់រឿងឱ្យខ្ញុំដឹងថាត្រូវឱ្យខ្ញុំជួយដូចម្ដេច?"

បាឡាត់ "គង់តែនឹងប្រាប់យុន ឥឡូវនេះហើយ តែ យុន ត្រូវធ្វើសញ្ញាថា បើ សម្ដីដែលខ្ញុំនិយាយទៅនេះមិនជាទីគាប់ចិត្តទេ សូមយុន ត្រាប្រណីកុំបីប្រកាន់ខឹងឡើយ"។

នារី "ចាំ! ខ្ញុំមិនខឹងនឹងលោកបាឡាត់ផ្ដេសផ្ដាសទេ"។

បាឡាត់ ខិតចូលទៅជិតនាងនារី ហើយនិយាយស្ទើរតែខ្សឹបថា "ខ្ញុំបាទ ស្រឡាញ់ ឃុន ណាស់! ឃុននារី"

នាងនារី ចង់ចិញ្ចើមទាំងសងខាងភ្លាម។

បាឡាត់ មើលមុខនាងនារី ហើយថា "ប្លែកណាស់ឬឃុននារី?"

នារី ញាក់មុខ ហើយថា "ខ្ញុំប្លែកណាស់តែម្ដង!"

បាឡាត់ "ឃុន ឃើញសេចក្ដីមេត្រីស្នេហារបស់ខ្ញុំបាទជាការចម្លែកណាស់ ទៅឬ?"

នារី "ទេ! លោក បាឡាត់ ខ្ញុំនឹកធ្ងល់ ត្បិត មិនធ្លាប់នឹកនាថា លោកបាឡាត់ ចង់ចង មេត្រីស្រឡាញ់ស្រីដូចជាខ្ញុំនេះឡើយ"។

បាឡាត់ "តែខ្ញុំបាទវិញឥតនឹកធ្ងល់បន្តិចក្នុងការមកចងមេត្រីនឹងស្រីដូចរូបឃុនដែល មានលក្ខណៈល្អគ្រប់បែបយ៉ាង"

ថាហើយ ក៏ឈោងដៃចាប់ដៃនាង តែនាងរលាស់ដៃចេញទៅ។

នារី "ខ្លួនខ្ញុំឥតមានអ្វីល្អទេ លោកបាឡាត់"

លោកបាឡាត់ សើចហ៊ឹះៗ ហើយ ថា "កុំនិយាយបន្ទាបបន្ទុះខ្លួនឡើយ ឃុន មុនខ្ញុំនឹង មក និយាយជាមួយនឹងឃុន ខ្ញុំបាទគិតហើយគិតទៀតជាច្រើនត្រឡប់ នៅទីបំផុតក៏ដាច់ចិត្ត មកនិយាយនឹង ឃុន"។

នារី "ចុះលោកដាច់ចិត្តយ៉ាងម្ដេច?"

បាឡាត់ "ដាច់ចិត្តថាត្រូវមកជម្រាបឱ្យឃុនបានជ្រាប ថាខ្ញុំបាទស្រឡាញ់ ឃុន ជា សេចក្ដីស្រឡាញ់ពិតប្រាកដ ដ៏បរិសុទ្ធចេញពីបេះដូងរបស់ខ្ញុំបាទ ចុះខាង ឃុន តើអាច តបាន ឬទេថា ឃុន ក៏ស្រឡាញ់ខ្ញុំបាទខ្លះដែរ?"

លោក បាឡាត់ និយាយយ៉ាងទន់ភ្លន់ ពិរោះស្ដាប់ តែនាងនារី នៅតែយល់ថា ចៅចិត្ត របស់នាងនិយាយពិរោះជាងនេះទៅទៀត ទើបនាងឆ្លើយទៅវិញថា "រឿងនេះ ខ្ញុំតប លោក បាឡាត់មិនបានទេ"។

លោកបាឡាត់ បើកភ្នែកធំហើយថា "ព្រោះហេតុអ្វីបានជាតបពាក្យខ្ញុំបាទមិនបាន?"

នារី "ព្រោះខ្ញុំមិនស្រឡាញ់លោកបាឡាត់ទេ"

បាឡាត់ "ចុះហេតុអីមិនស្រឡាញ់ខ្ញុំសោះ" សួរនាងនារី ដោយ សម្តីរឹងៗ ជាងមុនបន្តិចៗ

នារី "មិនបាច់តបទេ លោកបាឡាត់ ការសំខាន់គឺថាមិនមាន ចិត្តស្រឡាញ់លោកបាឡាត់ ត្រឹមប៉ុណ្ណោះក៏ល្មមហើយ"ៗ

បាឡាត់ "ពុទ្ធោ យុននារី! យុន នឹងសម្លាប់ដោយឥតចិត្តអាណិតអាសូរសោះឡើយឬ?"

នាងនារី មិនតបៗ

បាឡាត់ "យុន កំពុងតែទំលុះទំលាយបំផ្លាញបំណងល្អ និងសេចក្តី មេត្រីស្នេហាដ៏សុចរិត ស្មោះត្រង់ របស់ខ្ញុំបាទក្នុងខណៈនេះហើយឬ?"

នារី "មិនមែនដូច្នេះទេ លោកបាឡាត់ ស្ត្រីដទៃទៀតដែលល្អជាង គ្រាន់ បើជាងក៏មានគគោក ម៉េចក៏លោកមិនស្រឡាញ់?"

បាឡាត់ "ខ្ញុំបាទ សូមផ្ញើជីវិតចំពោះយុន តែមួយប៉ុណ្ណោះ"

នារី "បើលោក បាឡាត់ នៅតែប្រកាន់ដូច្នោះគង់តែឃ្លាងទាំងអស់មិនបានអ្វីឡើយ"ៗ លោកបាឡាត់ ទាល់ច្រក ក៏ក្រោកដើរវិលវល់តែក្នុងបន្ទប់នោះ ត្រិះរិះរកសម្តីនិយាយ នាងនារី ដើរទៅឯបង្អួចចោលភ្នែក កក្រឡេកមើលទៅឯក្រោយផ្ទះ ចាំមើល ផ្លូវចៅចិត្រ របស់ នាងដោយនឹករំខានចិត្តនឹង បាឡាត់ កម្ទោះនេះជាពន់ពេកៗ

ឯលោក បាឡាត់ នោះក៏ដើរទៅឈរពាំងពីខាងមុខនាង ហើយនិយាយថា " ខ្ញុំដឹងហើយ ហេតុអ្វីបាន យុន មិនស្រឡាញ់ខ្ញុំ"ៗ

ឯនាងនារី ឈរនៅតែស្ងៀម ត្បិតនាងមិនត្រូវការស្តាប់សម្តីវាចាបាឡាត់នោះឡើយៗ

បាឡាត់ "យុន មិនស្រឡាញ់ខ្ញុំ ព្រោះ យុន មានតួមនុស្សដែល យុន ស្រឡាញ់រួចទៅហើយមែនឬទេ?" និយាយសើចដោយកិរិយាចំអកចំទយៗ

នារី ងាកខ្វាប់មកមួយរំពេច ខឹ ងណាស់ដែលគេនិយាយមិនក្រែងចិត្តនាងសោះឡើយ ហើយនិយាយចេញទៅជា "ប្រយ័ត្នលោកបាឡាត់មនុស្សដែលលោកថានោះគឺនរណា? កុំប្រើសម្តីឈ្វានពានមកលើខ្ញុំខ្លាំងពេកណា!"ៗ

លោកបាឡាត់ កាន់តែសើចខ្លាំងឡើងទៀតហើយថា "ខ្ញុំមិនឈ្វានពានបង្អាច់យុន អ្វីទេ គ្រាន់តែនិយាយថា យុន មានគូស្រករបស់ យុន រួចទៅហើយ ខ្ញុំនឹងប្រាប់ឈ្មោះឥឡូវ ក៏បាន"។

នារី "នរណាហ៊ឹះ" នាងសួរទាំងខឹង។

បាឡាត់ "គឺចៅចិត្រ នោះឯង ! មែន ចៅចិត្រវាក្មេងកម្លោះរូបស្រស់ សម្តីផ្អែម តែវាទីទ័ល ក្រដូចមនុស្សសុំទានគេ មែនទេ!" (ថាហើយក៏សើចក្អាកក្អាយ)។

នារី "លោកអួតខ្លួនវិសេសវិសាលយ៉ាងណាបានជាហ៊ាននិយាយ សង្កត់សង្កិន បន្តុះ បង្អាប់គេយ៉ាងនេះ បើទុកជាគេទីទ័លក្រក៏ទីទ័លតែទ្រព្យសម្បត្តិប្រាក់ មាស តែគុណ សម្បត្តិសុខភាពរៀបរយជាសុភាពបុរស ជាកូនប្រុសមែន ៗ នោះចៅ ចិត្រ មានសព្វគ្រប់ ឯខ្លួនលោកមានតែប្រាក់មាសមែនហើយ លោកអាចទិញដូរ របស់អ្វីបានតាមត្រូវការ តែ លោកមិនអាចយកប្រាក់មកទិញសេចក្តីស្នេហារបស់ខ្ញុំ បានទេ! លោកមានប្រាក់មាស ដែល ចៅចិត្រគ្មាន តែរបស់ដែលចៅចិត្រមាន លោកមិនមានសោះឡើយមែនឬទេ!"

បាឡាត់ "ចុះខ្ញុំមានអ្វី? នៅខ្វះអ្វីទៀត?"

នារី "សុភាពបុរស និងសភាវៈជាកូនប្រុស"។

បាឡាត់ "ក៏នេះមិនមែនកូនប្រុសទេឬ?"

នាងនារី សើចចំអក ឱ្យហើយវាចា "ត្រូវហើយ តែលោកបាឡាត់ គ្រាន់តែមាន រាងកាយ ជាកូនប្រុស តែចិត្តរបស់លោកបាឡាត់ ខ្លាចលើសស្រីទៅទៀតមែនទេ?"

បាឡាត់ "ខ្លាចលើសស្រីទៅទៀត" និយាយផ្ទួនពាក្យ ហើយសួ រទៅទាំងខឹងថា "ចុះហេតុ អ្វីក៏យុន ហ៊ាននិយាយប្រមាថខ្ញុំដូច្នេះ?"

នារី "ខ្ញុំឥតមាននិយាយប្រមាថខាតទានអ្វីលោកទេ តែនិយាយតាមត្រង់ទេតើ លោក ភ្លេចហើយឬ កាលចោរប្លន់នៅ កណ្តាលព្រៃ អ្នកណាហ៊ានចេញទៅតទល់ ជាមួយចោរ? ហើយអ្នកណារត់ទៅពួនយកតែព្រះអាយុនៅក្រោមរថយន្ត?"

បាឡាត់ "ខណៈនោះវាគ្មានកាំភ្លើងនៅនឹងខ្លួនខ្ញុំទេ យុន ក៏ដឹងស្រាប់ហើយ"

នារី សើចហើយថា "បើទុកជាមាន ក៏មិនហ៊ានបាញ់ដែរ មនុស្សកម្សា ចបែបនេះ តែរត់បាតជើងសញ្ជ្រាតឱ្យរួចខ្លួនប៉ុណ្ណោះ!"

លោកបាឡាត់ កាលត្រូវ សម្ដីស្រីប្រមាថមើលងាយដូច្នេះ ក៏បើកភ្នែក ក្រឡោតប្រឡោត ខឹងជាខ្លាំង រួចចាប់ដៃនាង នារី ទាំងពីរច្របាច់ណែនហើយប្រាប់ថា "ឈប់និយាយទៀត ខ្ញុំនឹងសងសឹកអំនួតឃុនឥឡូវនេះឯង"

នាង នារី ខំរលាស់ចេញជាប្រញាប់ តែលោកបាឡាត់កាន់តែច្របាច់ ខ្លាំងឡើងទៀត ហើយស្រវាអោបនាងផង

នារី "លែងខ្ញុំ! លោកបាឡាត់ លោកមា នអំណាចដូចម្ដេចបានហ៊ានធ្វើដូច្នេះ ហ៊ឺះ !" (នារី ស្រែកឡើង)។

បាឡាត់ "មិនអួតទេ តែហ៊ានធ្វើ ព្រោះស្រឡាញ់ទេតើ! ឱ្យខ្ញុំថើបដោយស្រួលទៅវិញ" ហើយខំប្រអោប នារីណែន នាងនារី ក៏ខំបម្រះពេញកម្លាំង ទៅជាចំបាប់ប្រចាប់គ្នាអឹកធឹកឡើងទាល់តែទ្វារបន្ទប់របើក ចេញលេចរាងកាយ ថៅចិត្រ ស្ទុះ បាញ់ត្រង់សំដៅទៅលោក បាឡាត់ ចាប់កន្ត្រាក់លោក បាឡាត់ នោះចេញ លោកបាឡាត់ ភ្ញាក់ចំណាប់មិនបានការពារខ្លួន ទើបត្រូវថៅចិត្រដាល់ដួលផ្ងាចផ្ង្រាង នៅក្នុងបន្ទប់នោះឯង។

ចិត្រ "អាក្រក់អីម្ល៉េះ អ្នកបាទនេះ !" ថៅចិត្រ គំរាមខាំធ្មេញ ប្រុងនឹងលោតទៅថែមទៀត តែនាង នារី ចាប់ដៃទាន់ ហើយហាមថា "ប៉ុណ្ណឹងបានហើយ ចិត្រកុំថែមទៀត"។

លោកបាឡាត់ ស្ទុះក្រោកឡើងប្រុងលោតមកសងសឹក វិញ ស្រាប់តែ ហួង រតនសម្បត្តិ និងថៅកែផាន់ ដើរចូលមកក្នុ ងបន្ទប់នេះ ទើបលោកបាឡាត់ នោះទប់ ង៉ក់ លោកហួង ងាកទៅមើលមុខថៅចិត្រ ហើយបែរមកមើលមុខលោកបាឡាត់ ដោយ លោកមានសេចក្ដីឆ្ងើងឆ្ងល់ណាស់ទើបលោកសួរថា "កើតរឿងអី ថៅចិត្រ ទើបមានសូអឹក ធឹកស្ទើរ តែនឹងធ្លាយជញ្ជាំងផ្ទះ?"

ថៅចិត្រមិនឆ្លើយ ស្រាប់តែនារី ស្ទុះទៅអោបឪពុក ហើយថា "ប៉ា លោក បាឡាត់នោះអាក្រក់ណាស់"។

ហួង "វាម៉េច លោកបាឡាត់ធ្វើអី?" (លោកហួងសួរកូន)

នារី "ចំបាប់ខ្ញុំ គ្រោះល្អបាន ថៅចិត្រ ចូ លមកទាន់កុំអី!" ថាហើយនាងយំខ្សឹបខ្សួលយ៉ាង គ្មាន់គ្នាញ់ក្នុងចិត្តជាទីបំផុត។

លោកហ្ជូង ទទួលស្តាប់ ពាក្យកូនទើបដើរចូលទៅជិតលោកបាឡាត់នោះ ហើយនិយាយថា "ហេតុអី ក៏លោកហ៊ានធ្វើអំពើប្រឡោងខាងដោយឥតអៀនខ្មាស់ដូច្នេះ ខ្ញុំបាទសេពគប់នឹងលោក ដោយជឿ ទុកចិត្តថាលោកជាមនុស្សល្អជាកល្យាណមិត្តរបស់ខ្ញុំ ឥឡូវលោកបែរជាតបស្នងសងគុណខ្ញុំដោយសកម្មភាពដូច្នេះ នេះល្មម ឈប់សេពគប់រាប់រកគ្នាពីថ្ងៃនេះតទៅ"។

លោកបាឡាត់និយាយសម្ដីទន់ទៅរក ហ្ជូងរតនសម្បត្តិថា "ខ្ញុំបាទ បានជា ខុសទៅហើយ សូមលោកអត់ទោសឱ្យម្ដងចុះ"។

លោកហ្ជូង ធ្វើជាសើចសោះកក្រោះ ហើយថា "លោកបាឡាត់ បានដឹងថា ខ្លួនខុសនោះ វាហួសវេលាទៅហើយ តែណ្ហើយចុះ ខ្ញុំ មិនប្រកាន់ទោសពៃរ៍អ្វីទេ ត្រង់ដែលលោកមកធ្វើល្មើសលើខ្ញុំជាទម្ងន់ក្នុងគ្រានេះ ខ្ញុំអត់ទោស ឱ្យ តែយើងត្រូវលែង ស្គាល់រាប់អាន គ្នាទៅទៀត ដ្បិតអំពើដែលលោកបានធ្វើនេះវាអាក្រក់អបល័ក្ខណ៍គួរអោម៉ាស់មុខណាស់ តែកាលបើលោកដឹងខ្លួនថាខុស នុះន៎ ! ទ្វារចេញ សមគួរតែ លោកដើរចេញទៅ កុំបីចូល មកវិញទៀតឱ្យសោះ! លោកហ្ជូងថាហើយ ក៏បែរចេញទៅរកថៅកែផាន់ហើយប្រាប់ ថា "ខ្ញុំនឹកស្ដាយណាស់ ក្នុងព្រឹត្តិការណ៍ដែល កើតឡើង អម្បាញ់មិញនេះ"។

ថៅកែ ផា ន់ មិននិយាយថាដូចម្ដេច ដើរសំដៅ ទៅរកលោកបាឡាត់ ទះស្មាតិចៗ ហើយថា "ទៅលោកបាឡាត់ កុំបីតូ ចចិត្តទោមនស្សអ្វី! ព្រោះអំពើដែលលោកបានធ្វើមកនេះ ជាការខុសពិត" ហើយក៏ដឹកដៃលោក បាឡាត់។ លោកបាឡាត់អោន មុខដើរចេញតាមទ្វារនោះទៅ។ ខាងឯលោកហ្ជូ ង ក៏មិនបានប្ដឹងផ្ដល់ដែលជាការត រឿងរ៉ាវឱ្យវែងឆ្ងាយតទៅទៀត ដោយលោកនឹកថាជាគ្រោះថ្នាក់រ បស់លោក និងបុត្រីរបស់លោកទើបស្ទេះ រឿងនេះទុកត្រឹមប៉ុណ្ណោះ។

វេលាព្រលប់ចូលយប់សន្ធ្យា ព្រះចន្ទ្ររះឡើងពីបូព៌ាទិស យ៉ាងត្រចះត្រចង់ ព្រឹត្តិការណ៍ ដែលកើតឡើងពីពេលរសៀល មិនទាន់រលុបបាត់ពីខួរក្បាលរបស់ថៅចិត្រ។ វេលានោះ ថៅចិត្រ កំពុងអង្គុយបណ្ដោតចិត្តទៅតាមអារម្មណ៍ ដែលគិតនឹក នៅនារបៀងផ្ទះ ចោល ភ្នែកក្រឡេកមើលទៅលើមេឃ ឃើ ញពពកមួយដុំធំកំពុង អណ្ដែត្រសែត

ទៅទិសខាងកើត ស្ដាប់ សម្លេងស្ទឹកឈើឮសូរប្រាវៗ ដែលត្រូវខ្យល់ បក់ៗ សុនខ នៅខាង ផ្ទះជិតខាង ក៏ព្រុសគឹកកង ហើយស្រែកលូយ៉ាងលន្លង់លន្លោចៗ

ចៅចិត្រ ក៏ចាប់ភ្លឹកនឹកដល់ឪពុក ដែលអនិច្ចកម្មទៅហាក់ដូចជានៅថ្មីៗ នឹក ឡើង វេលាណាទឹកភ្នែកក៏ហូរសស្រាក់មកដោយមិនដឹងខ្លួនប្រាណ ហើយនឹករលឹក ដល់បណ្ដាំ របស់ឪពុក មុនដែលបានលះបង់ លោកនេះទៅ ចៅចិត្រ គិតឃើញថាខ្លួន របស់ខ្លួនឯង ពិតៗ ខំតាំងខ្លួនប្រាណឡើងមកនេះ គិតទៅគិតមកគំនិត ចៅចិត្រ ជាប់នៅទើលើរូប នាងនារីទាំងអស់ នាងនារីតែមួយដែលអាចជួយញ៉ាំងជីវិតរបស់គេ ឱ្យស្រស់បស់ ផូរផង់ ទៅមុខ ប្រសិនបើបែរ ជាមិនសម្រេចដូចបំណង ជីវិតរបស់ចៅចិត្រ ស្ទើរតែទៅជាសោះ សូន្យឥតរីករាយឡើយ តែគេជឿជាក់ក្នុងសេចក្ដីមេត្រី ស្នេហារវាងនារី និងខ្លួនគេជាទី បំផុត នឹកដល់ត្រង់ណេះ ចៅចិត្រក៏ញញឹមប៉ប្រឹមតែម្នាក់ ឯង ហើយគេក្រោកឡើងដើរ ចូលក្នុងបន្ទប់ ប្រះខ្លួនដេកលើពូកខ្នាតតូច ដែលនាងនារីដេរ ឱ្យដោយដៃរបស់នាង ទម្លាក់ មុងទាញភួយមកដណ្ដប់ ប្រុងស្មារតីនឹងដេកឱ្យលក់សប្បាយៗ

អកាសនោះវេលាយប់ជ្រៅទៅ នៅស្រុកបប៉ៃលិនត្រជាក់ ខ្លាំងបន្តិច ផ្ទៃមេឃស្រឡះ ប្រាសចាកពពក ដួងចន្ទ្រហាក់ដូចជាបណ្ដែតនៅលើកំពូលភ្នំបប៉ៃលិន បញ្ចាំងពន្លឺ សស្អាត សាចចូលតាមចន្លោះបង្អួចមានខ្យល់រំភើយៗ បក់ចូលមក ប៉ះនឹង ខ្សែមុងរវិចៗ សូរស័ព្ទឆ្កែព្រុសនិងសូរលូនៅតែឮមិនដាច់សម្លេង។ ចៅចិត្រដេក សម្លឹងមើលដួងចន្ទ្រ ហើយធ្មេចភ្នែកជិតតែនឹងដេកលក់ទៅហើយ។

ប៉ុង! ប៉ុង! សូរកាំភ្លើងលាន់ឡើងនៅក្បែរខាងបរិវេណផ្ទះ ដូចជាដាស់ ចៅចិត្រ ដែលជិត លក់ ឱ្យភ្ញាក់ឡើងវិញ ហើ យគេបានស្ទុះក្រោកឡើងយ៉ាងប្រញាប់ប្រញាល់អន្ទុយ ចាំស្ដាប់ឱ្យជាក់ច្បាស់ តើមានហេតុអ្វីកើតឡើង ? ភ្នែកសម្លឹងមើលកាំភ្លើងដែលព្យួរនៅ នឹងជញ្ជាំងខាងក្បាលដំណេក ជារបស់ដែលហួងរតនសម្បត្តិ ឱ្យទុកបង្ការអន្តរាយ ស្ងប់ ស្ងាត់ទៅមួយស្របក់ៗ ប៉ុង ! ប៉ុង! ប៉ុង! ប៉ុង! សូរក៏លាន់ឮឡើង ទៀតជាច្រើនណាត់ៗ ចៅចិត្រ ក៏ស្ទុះក្រោ កឡើងចាប់កាំភ្លើងស្ទុះចុះពីផ្ទះមកស្រាប់ តែឃើញភ្លើងភ្លឺរន្ទាលអស់ ទាំងភូមិ ទើបរត់ទៅផ្ទះពួ កកម្មករ ក៏ឃើញពួកកម្មកររួមផ្ដុំ គ្នា ខ្លះកាន់កាំភ្លើង ខ្លះកាន់លំ ពែង ខ្លះកាន់ដាវប្រុងខ្លួនជាស្រេច សូរកាំភ្លើងលាន់ឮច្រើនទៀតជាច្រើនណាត់ ព្រមទាំង

សូរហ៊ោរបស់ពួកចោរយ៉ាងអឺកធឹកបន្តិច ស្រាប់ តែឮសូរស្រែកអេះៗនៅលើផ្ទះធំ ចៅ ចិត្រ ចាំច្បាស់ថាជាសម្លេងរបស់ហ្លួង។

"អាពួកនេះអាក្រក់ណាស់ វាឃើញផ្ទះណាមានទ្រព្យសម្បត្តិវាតែង នាំបក្សពួកវាចូលប្លន់" នេះជាសម្លេងតាសុន អ្នកបររថយន្តឮល្វើយៗ មកតាមខ្យល់។

ចៅចិត្រ ដឹងប្រាកដជាមានពួកចោរចូលប្លន់ ក៏នាំពួកកម្ម ករ ចេញ ទៅសំដៅផ្ទះធំយ៉ាងរួសរាន់ ក៏ស្រាប់តែឃើញពួកចោរជាច្រើន កំពុងប្រវាតោងរបងភូមិ ឡើងចូលមកក្នុងភូមិសឹងមានអាវុធគ្រប់ដៃ ហើយក៏នាំពួកកម្មករទៅប្រយុទ្ធនឹងពួកចោរ យ៉ាងម៉ឺងម៉ាត់។

ការតស៊ូរវាងពួកចោរ និង ពួកកម្មករសុទ្ធតែមានអាវុធគ្រប់ដៃទាំងសងខាង កាន់តែខ្លាំងឡើងៗ ដល់ថ្នា ក់ប្រឡូកគ្នាមិនគិតស្តាយជីវិតរៀងខ្លួន។ ឯចៅចិត្រ អែប នឹងដើមឈើមួយដើម ជាទីកំបាំងលើកកាំភ្លើងបាញ់តំរង់ចោរម្នាក់ ដួលផ្ងារទៅដោយ គ្រាប់កាំភ្លើងមួយគ្រាប់ដំបូង ១គ្រាប់ទៀត ត្រូវចោរម្នាក់ទៀតកាន់ដាវ នៅដៃទាំងពីរ ដួលទៅទៀត ខណៈនោះសូរស្រែកហ៊ោ សូរកាំភ្លើង សូរថ្ងូររបស់អ្នក ដែលត្រូវរបួស ក៏លាន់ឮកងរំពងទៅទាំងភូមិ។

ចៅចិត្រ ទុកបណ្តោយ ឱ្យពួកកម្មករតទល់នឹងពួកចោរនៅខាងក្រោយ ខ្លួនឯងដោះដៃស្ទុះរត់ឡើងទៅលើផ្ទះធំ គេបានឮសូរ សម្លេងតស៊ូយ៉ាងអឺកធឹកនៅ បន្ទប់ទទួលភ្ញៀវ ក៏ ស្ទុះភ្លែតចូលទៅស្រាប់តែឃើ ញចោរ មាឌធំខ្មៅគំរឹលម្នាក់ ចាប់ ក្រវាត់លោកហ្លួង ដួលឮសូរគ្រាំងនៅកណ្តាលល្វែងបន្ទប់នោះឯង។

ចៅចិត្រ ស្រែកឡើងថា "អាផាន់ អាជាចៅកែចោរឬ? អារនាំពួកចោរមកប្លន់ឬ?"

អាផាន់ ជាមហាចោរចិត្តទមិឡ ខាំ មាត់សំញេញធ្មេញសស្វាចដាយក្សា តប ទៅថា "អើអញ! នេះអញត្រលប់មកសងសឹកអាវិញឱ្យទាន់ចិត្តហើយ យកត្បូងទាំង អស់របស់ចៅហ្វាយអាទៅផង"។

ចៅចិត្រ ខាំធ្មេញក្រឹត ហើយលើកកាំភ្លើងតម្រង់ ហើយនិយាយថា "អានេះ មិនយកទេឬ" ហើយបាញ់ប៉ុង សំដៅដើមទ្រូងមហាចោរមួយណាត់ តែមហាចោរវៃចំណាប់គ្រាប់កាំភ្លើងត្រូវតែចុងសក់ធុះជញ្ជាំងទៅ ហើយវាស្ទុះភ្លែតដាល់ខ្លួនចៅ ចិត្រ ប៉ះយ៉ាងខ្លាំង ចៅចិត្រ ភ្ញាត់ចំណាប់ដួលផ្ងាចផ្គ្រាំង កាំភ្លើងរបូតទៅនៅកៀន ជញ្ជាំង តែចៅចិត្រ ក៏វៃ ចំណាប់

ម្ទីម្នាក្រោកឡើងស្ទុះភ្ញែតដាក់មហាចោរវិញមួយដៃដំបូងត្រូវថ្គាមក្បែរគុម្ពត្រចៀក ញាំង មហាចោរឱ្យទ្រេតថយធ្លាទៅម្ខាង ចៅចិត្រ ស្ទុះ ទៅដាល់មួយដៃថែមទៀត តែបែរជា ត្រូវ មហាចោរវាត់មួយដៃ ត្រូវខាងលើត្របកភ្នែក ខាងឆ្វេង រាងកាយតូចស្តើង របស់ចៅ ចិត្រ ក៏វិលខ្វាល់ទៅប៉ះនឹងជញ្ជាំងផ្ទះ មហាចោរ ស្ទុះមកនឹងថែមយ៉ាងពេញទំ ហឹងដែរ តែ ចៅចិត្រ គេចផុតទៅបន្តិច ទើប ធ្វើឱ្យមួយដៃលើកក្រោយយ៉ាងដំណំរបស់មហាចោរនេះ ត្រូវជញ្ជាំងផ្ទះឮសូរគ្រាំង ស្ទើ របែកធ្លាយចេញទៅ។ មហាចោររលាស់ដៃ ជាប្រញាប់ ក៏ស្រាប់តែប៉ះនឹងកណ្តាប់ ដៃរបស់ចៅចិត្រ យ៉ាងធ្ងន់ត្រង់បបូរមាត់ចេញឈាមខ្លាយ តែ មហាចោរចិត្តមុតគ្រាន់តែទ្រេតទៅបន្តិច ក៏ស្ទុះចូលមកដាក់ចៅចិត្រវិញ។ ចៅចិត្រ តោងថយក្រោយពីរបីជំហានដោយនឹកស្ញើបនឹងកណ្តាប់ដៃយក្សរបស់មហាចោរ ដែលអាច ផ្តួលមនុស្ស ធម្មតាត្រឹមមួយដៃ ៗប៉ុណ្ណោះ។ មហាចោរទាត់ផាំង សំដៅ កញ្ចឹងកចៅចិត្រ។ ចៅចិត្រ គេ ចផុតទើបគេតបទៅវិញនឹងកៅអីមួយនៅក្នុងបន្ទប់នោះ មហាចោរលើកដៃ កាត់ កៅអីបាក់ប្រាវ ហើយមហាចោរស្ទុះចូលមកទៀតដូ ចជាក្របីព្រៃ។ ចៅចិត្រ ថយទៅប៉ះ ជញ្ជាំងស្រាប់តែដើងទៅជាន់លើកាំភ្លើងទើបប្រញាប់ចាប់កាំភ្លើងឡើងផ្តួងលើស្មា ហើយ កេះកៃសំដៅដើមទ្រូងមហាចោរដែលស្ទុះក្រទីក្រទាចូលមកទៀត ប៉ុ ង! បាត់ផ្សែងរាងកាយ សម្បើមដូចក្របីព្រៃនៃមហាចោរ ដួលគ្រេងដេកស្តូកស្តឹង នៅ ក្នុងបន្ទប់នោះឯង។ លុះចៅចិត្រ ឃើញម ហាចោរអស់ឫទ្ធិអំណាចនឹងក្រោកមកស៊ូបានទៀត ទើបងាក ទៅ ពិនិត្យមើលលោកហ្លួងរតនសម្បត្តិ ដែលដេកស្រប៉ាបក្នុងបន្ទប់ នោះដែរ លើកក្បាល ដាក់ លើភ្លៅហើយចាប់អង្រួន លោកហ្លួ ងក៏បើកភ្នែកឡើងហើយសួរខ្សាវៗយ៉ាងអស់កម្លាំងថា "អាផាន់ ទៅណាហើយ?"

ចិត្រ "ស្លាប់ហើយទានប្រោស ព្រះតេជព្រះគុណល្មមមានកម្លាំងក្រោក អង្គុយបាន ឬទេ?"

ហ្លួង "ល្មមអង្គុយបាន ខ្លួនខ្ញុំមិនជាអ្វីទេ គ្រាន់តែអស់កម្លាំងណាស់ អាឆ្កួតនេះ វាចាប់ ឯង បោកស្ទើរប្រេកាច់!"។

ហ្លួងរតនសម្បត្តិ និយាយមិនទាន់ផុតពា ក្យស្រាប់តែឮសម្លេងស្រីស្រែកឡើងយ៉ាង ខ្លាំង ហ្លួងរតនសម្បត្តិ បើកភ្នែកក្រឡោត ចាំច្បាស់ជាសម្លេង នារី បុត្រីរបស់ លោកក៏ត្រូវពួក

ចោរចូលលុកលុយដែរៗ ឯចៅចិត្រខ្លួនឯងអស់កម្លាំងជិតដួលទៅហើយ គ្រាន់តែឮ សម្លេង នោះស្រែកឡើង ក៏កើតកម្លាំងម៉ឺងម៉ាត់ដូចតោឡើង កមួយរំពេចទើបគេស្ទុះលោត ឡើងទៅបន្ទប់ថ្នាក់លើចូលដល់ដំណេកនារីមួយរំពេច ស្រាប់តែឃើញបុរសកម្ទោះ កំពុង ចំបាប់ប្រវាយប្រតប់នឹងនាងនារី ចៅចិត្រ ស្ទុះក្ដៀ ត ចាប់កន្ទ្រាក់រាងកាយបុរសនោះ ចេញ បានដោយងាកមកឯរបៀង មិនដូចកាលតស៊ូ នឹងមហាចោរនោះឡើយៗ

ចៅចិត្រ ស្រែកគំរាមថា "អាបាឡាត់ អាហ៊ានពុះពារចូលដល់ទីនេះឬ?"

បាឡាត់ "អាចិត្រ អញនឹងបញ្ជូនវិញ្ញានរបស់អាឯងទៅឋាននរកឥឡូវនេះឯង " បាឡាត់ ស្រែកគំរាមតបមកវិញហើយថា ប់ហូតកាំបិតស្នៀតលើកចាក់សំដៅដើមទ្រូង ចៅចិត្រ ចៅចិត្រ ក៏គេចផុតខុយទៅ ទើបគេជូនមួយកណ្ដាប់ដៃសំដៅចំត្របក ភ្នែកបាឡាត់ ទុច្ចរិត តែមួយដៃ ក៏ដួលស្រប៉ា បនៅទីនោះឯងៗ នាងនារីស្រែកភ្ញាត់ សម្លេងដោយសេចក្ដី ភិតភ័យស្រឡាំងកាំងៗ

ចៅចិត្រ ស្ទុះទៅបីនាងនារី ចូលទៅក្នុងបន្ទប់ហើយថា "ខ្ញុំនឹងកប្បិលវាឱ្យ ស្រេចឥឡូវ នេះឯង" ថាហើយចៅចិត្រ ត្រ ឡប់ទៅវិញជាប្រញាប់ ឯបាឡាត់ នោះខំ ទប់ទល់អាត្មា ក្រោកឡើងផេងផាងដូចកល ត្រូវមន្តសណ្ដំរបស់ហនុមានៗ ចៅ ចិត្រ ស្ទុះក្ដៀតចាប់កអាវ បាឡាត់ ទុច្ចរិតនោះលើកឡើង ស្ទួយហើយគំរាមថា "នេះសម្រាប់ នាងនារី ហើយដាក់ មួយដៃយ៉ាងធ្ងន់ត្រង់ចង្កាបាឡាត់ទុច្ចរិតនោះ ក៏ដួលផ្ងារចង្រ្កាង ទៅទៀតរួចចាប់ក្បាល ស្ទួយឡើងទៀត ហើយស្រែកថា "នេះសម្រាប់អញ" ហើយដាក់មួយដៃចំបំពង់ករាងកាយ របស់បាឡាត់ទុច្ចរិតក៏ប្រាសចាកវិញ្ញាណ ព្រមទាំងដាក់ មួយជើងយ៉ាងដំណំ រាងអសុក ក៏អណ្ដែតធ្លាក់ចុះមកលើដីឮសូរគ្រាំង ជាអវសានលែជីវិតរបស់បាឡាត់ ទុច្ចរិតចិត្តអាក្រក់ នោះៗ

កាលមហាចោរជាធំទាំងពីរនាក់ស្លាប់ហើយ ឯពួកចោរ ជាបរិវារក៏បែកខ្ញាត់ខ្ញាយ រត់ចូលព្រៃអស់ទៅៗ ខណៈដែលពួកកម្មករដេញពួកចោររត់ ខ្ញាត់ខ្ញាយចូលព្រៃនោះទៅ ពួកកងក្រវែលក៏មកដល់ ហើយជួយដេញពួកចោរខាងក្រោយពួកកម្មករទៅដែរ តែឥតចាប់ បាន ចោរម្នាក់សោះ វៀរតែពួកចោរដែលត្រូវរបួសជាទម្ងន់ ដេកនៅក្នុងភូមិនោះ តែ ប៉ុណ្ណោះៗ

ដល់ព្រឹកឡើង ហ្លួងរតនសម្បត្តិ ចាត់ ឱ្យមេធាវីប្តឹង ក្រសួងរាជការតាមច្បាប់ អំពីហេតុចោរកម្មដែលកើតឡើងក្នុងយប់នេះសព្វគ្រប់។

**វគ្គទី៧ អវសាន**

ព្រឹកឡើងហ្លួងរតនសម្បត្តិ បានហៅពួកកម្មករទាំងអស់មកប្រជុំគ្នា ហើយបានជប់លៀង អាហារភោជនដើម្បី សម្តែងសេចក្តីត្រេកអរ ចំពោះកម្មករដែលមាន ចិត្តស្មោះត្រង់ជួយការពារយ៉ាងម៉ឺងម៉ាត់លុះត្រាតែមានជ័យជំនះពួកចោរ ហើយ លោកអនុញ្ញាតឱ្យពួកកម្មករទាំងអស់ឈប់សម្រាកធ្វើការមានកំណត់៣ថ្ងៃ។ ក្រោយ ពេលដែលពួកកម្មករនាំគ្នាលាលោកហ្លួងទៅសម្រាករាងកាយដ្បិតសុទ្ធតែអត់ងងុយនឹងនឿយហត់អស់កម្លាំងទាំងអស់គ្នា។ លោកហ្លួង ក៏ទៅ សម្រាករាងកាយដែរ ហើ យលោករំពឹងគិតដល់គុណបំណាច់ផ្សេងៗ និងសេ ចក្តីស្មោះត្រង់របស់ចៅចិត្រ ដោយ សព្វគ្រប់ទៅ ក៏ឃើញថាគេមានមេត្រីចិត្តស្មោះត្រង់ ស៊ូយកជីវិតខ្លួនមកប្តូរដើម្បី ជួយជីវិតលោក និងជីវិត បុត្រលោកពីរគ្រាមកហើយ សុទ្ធតែអាសន្នធំៗ។ មួយទៀតលោកជ្រាបថា សេចក្តីស្និទ្ធស្នាល រវាងបុត្រីលោក នឹងរូបចៅចិត្រនោះសោតទៀត លោកក៏បានដឹងច្បាស់ថា មិនអាច នឹងបម្រាស់ពង្រ៉ាត់ឱ្យដាច់គ្នាបានទេ លោកហ្លួង គិតមកដល់ត្រឹមនេះ ទើបហៅ បុត្រីលោកឱ្យទៅហៅចៅចិត្រមក នឹងនិយាយការសំខាន់មួយ។

ចៅចិត្រក៏ដើរចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ ខណៈនោះហ្លួងរតនសម្បត្តិ កំពុង អង្គុយផ្អែក លើកៅអីមួយធំ ចៅចិត្រ ក៏ដើរចូលទៅដោយសេចក្តីគោរពហើយ ជម្រាបថា "ទានប្រោស ខ្ញុំបាទមកហើយ"។ ឯនាងនារី ក៏ឈរអែបស្តាប់នៅខាងមាត់ទ្វារបន្ទប់។

ខណៈនោះ នាយចិត្រ ភ័យផង អរផង នឹកភ័យក្រែងលោកបានដឹងរឿងរបស់ខ្លួននឹងនាងនារី ហើយនឹងបណ្តេញខ្លួនចេញពីផ្ទះនោះទៅ នឹកអរក្រែងលោក ត្រេកអរនឹងការតទល់យ៉ាងម៉ឺងម៉ាត់ លុះត្រាតែផ្តាច់ជីវិតមហាចោរបងដល់ទៅពីរនាក់កាលពីយប់មិញនេះ ទើបគេខំប្រឹងកាត់ចិត្ត និយាយសួរទៅលោកវិញទៀតថា "រឿងអ្វីទានប្រោស?"

លោកហ្លួង គ្រហែមតិចៗ ហើយថា "រឿងសេចក្តីគាប់គួរនឹងគុណបំណាច់អ្នកឯងហ្នឹងណ៎ា"។

ចៅចិត្រ ឮពាក្យនេះ បានធូរចិត្ត ដូចគេលើកភ្នំចេញពីទ្រូង។ លោកហ្លួង និយាយដោយទឹកសម្តីចេញទៅដោយសេចក្តីមេត្តាករុណាថា "ខ្ញុំត្រូវតែតបគុណ អ្នកឯងខ្លះឮទេ?"។ ចិត្រ "មិនបាច់ទេទានប្រោស ខ្ញុំបាទបានធ្វើការគ្រប់យ៉ាងនេះ មិនបានប្រាថ្នាការតបស្នងអំពីព្រះតេជព្រះគុណសោះឡើយ ក្រៅ ពីសេចក្តីមេត្តាករុណា ដូចព្រះ តេជព្រះគុណសង្គ្រោះដល់ខ្ញុំបាទដល់សព្វថ្ងៃនេះ ក៏ល្មមគ្រប់គ្រាន់ហើយ"។

ហ្លួង "មិនល្មមទេ ចៅចិត្រ ត្បិត អ្នកឯងយកជីវិតខ្លួនប្តូរ ស្ទើរតែមិនរស់ពីរបី គ្រាមកហើយ! លោកបង្អង់មួយស្របក់ ហើយលាន់ សម្តីថា "ណ្ហើយចុះ! ចូរនិយាយ តាមត្រង់ មកតើឯងត្រូវការអ្វីខ្លះ?"

ចិត្រ "ទានប្រោស! ខ្ញុំឥតត្រូវការអ្វីទេ ខ្ញុំ បាទជាកូនឈ្នួលរបស់ព្រះតេជព្រះគុណ អំពើ ដែលខ្ញុំបាទបានធ្វើទៅទាំងប៉ុន្មានសុ ទ្ធតែធ្វើដោយសេចក្តីកតញ្ញូកតវេទី ចំពោះព្រះតេជព្រះគុណ ឥតត្រូវការបំណាច់រង្វាន់អ្វីឡើយ"។

លោកហ្លួងលើកដៃហាម "មិនបាច់និយាយវេះវាងឱ្យវែងសេចក្តីទេ ខ្ញុំដឹងថាអ្នកឯងនិយាយមិនត្រង់មែនទេ?"

ចៅចិត្រ ខំប្រឹងកាត់ចិត្តកាត់ថ្លើម និយាយតបដោយ សម្លេងដាប់ៗ "ខ្ញុំបាទ ខ្ញុំបាទ... សូមជំ...ជម្រាប..."

លោកហ្លួង និយាយកាត់ឡើងថា "ប៉ុណ្ណឹងចុះ ខ្ញុំដឹងហើយថាអ្នកឯងត្រូវការអ្វី ខ្ញុំអាចទាយចិត្តត្រូវទាំងអស់ ណ្ហើយចុះខ្ញុំ ឱ្យគ្រប់យ៉ាងតាមត្រូវការ" ដល់ត្រង់ណោះ លោក អោនខ្សឹប នឹងត្រចៀកនាយចិត្រ ប្រាប់ថា "នោះហ្ន៎! ដែលអ្នកឯងត្រូវការចង់ បានស្មើដោយជីវិតមែនទេ?" លោកលើកដៃចង្អុលទៅមាត់ទ្វារ។

ចៅចិត្រ ងើងឆ្ងាងទៅមួយស្របក់ ស្ទើរ តែមិនជឿត្រចៀកខ្លួនឯងថាខ្លួនបានឮអម្បាញ់មិញនេះ កាលបានឮស្មារតីក៏អោនក្រាបនៅចំពោះមុខលោកហ្លួង ថ្លែងពាក្យអរគុណច្រើនជាអនេកដោយបិតិត្រេកអរដ៏លើសលប់ តែគេមិនអាចឮពាក្យពេចន៍ដែលចៅចិត្រ និយាយថាដូចម្តេចឡើយក្នុងខណៈនោះ។

លុះបានឫក្សពារវេលាល្អតាមឬក្សហោរាសាស្ត្រទើប ហ្លួងរតនសម្បត្តិ ចាត់ចែងរៀបមង្គលការអាពាហ៍ពិពាហ៍រវាងនាងក្រមុំនារី បុត្រីលោកជាគូនឹងចៅចិត្រ។ នៅឱកាស

នោះលោកបានអញ្ជើញអ្នកមុខអ្នកការទាំងអ្នករាជការ អ្នកជំនួញទាំង ជាតិខ្មែរ ជាតិ ភូមា ចិន យួន និង បារាំង សឹងមាន ចំនួនណែនណាន់តាន់តាប់ ហើយ លោកបានចែកមត៌ក ឱ្យគូស្វាមីភរិយាថ្មី ជាងពាក់កណ្ដាល ទ្រព្យសម្បត្តិរបស់លោក ក្រៅពីនេះ លោកនៅមាន ក្មួយតូចៗពីរបីនាក់ទៀត សុទ្ធតែកំព្រាឪពុកម្ដាយទាំងអស់ ដែលលោក ត្រូវថែរក្សាទំនុកបម្រុងតទៀត ហើយលោកត្រូវចែកមត៌កឱ្យកូនកំព្រាទាំងនោះតាមសមគួរផង។

លុះអំណើសកាលតមក គូស្វាមីភរិយាទាំ ងពីរនាក់ ក៏បាន នៅរួបរួមគ្នាជាសុខក្សេមក្សាន្ត ត្រាតែកើតកូន ពូនជាចៅ តវង្សត្រកូលរៀងទៅហោង។

***ចប់ដោយបរិបូណ៌***